# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


## វិទ្យាស្ថានជាតិអប់រំ

National Institute of Education


## និក្ខេបបទ

# ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា

## ករណីសិក្សាៈ ខេត្តតាកែវ

## Condition of Teaching English Language in Primary School

## Case Study: Takeo Province


ដោយ/By

**ង៉ែត រ៉ាវុធ**

NGET RAVUTH


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦

ឯកទេសៈ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៧ - ២០១៩


ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា

Supported by Cambodia International Education Support Foundation ( CIESF )

# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា

# ករណីសិក្សាៈ ខេត្តតាកែវ

## Condition of Teaching English Language in Primary School

## Case Study: Takeo Province


ដោយ/ By

**ង៉ែត រ៉ាវុធ**

NGET RAVUTH


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៧ - ២០១៩**

**សាស្ត្រាចារ្យដឹកនាំៈ បណ្ឌិត នួន វីរ៉ា**

**សាស្ត្រាចារ្យដឹកនាំរងៈ ម៉ៅ សារឿន**


**ឧបត្ថម្ភដោយៈ មូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា**

Supported by Cambodia International Education Support Foundation ( CIESF )

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៤៧២៩ **អយក.** ?ស

**(ការសម្ងាត់)**

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត ឃួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត សិន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

## សេចក្តីប្រកាសអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើង " **ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា** " សម្រាប់បំពេញលក្ខខណ្ឌ សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺជាស្នាដៃផ្ទាល់ខ្លួនរបស់ខ្ញុំបាទទាំងស្រុង។ស្នាដៃនេះ ពុំបានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ ឬនៅសាកលវិទ្យាល័យណា ឬនៅគ្រឹះស្ថានអប់រំណាមួយនៅឡើយទេ។ រាល់សេចក្តីដកស្រង់ និងខ្លឹមសារដែលបានប្រើប្រាស់នៅក្នុងអត្ថបទស្រាវជ្រាវនេះគឺទទួលបានការអនុញ្ញាតពីសំណាក់អ្នកនិពន្ធ និងមានចុះបញ្ជីឯកសារយោងត្រឹមត្រូវ។ និក្ខេបបទស្រាវជ្រាវនេះ ពិតជាចងក្រងដោយខ្ញុំបាទពិតប្រាដកមែន។

ថ្ងៃព្រហស្បតិ៍ ០៧ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០

**ហត្ថលេខាបេក្ខជន**

**ខែ៉ត វ៉ាឌុធ**

# លិខិតបញ្ជាក់

បណ្ឌិត **នួន ទីរ៉ា** ជាសាស្ត្រាចារ្យដឹកនាំ
លោក **ម៉ៅ សារឿន** ជាសាស្ត្រាចារ្យដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **ខៃត រ៉ាឌុច** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ " **ស្ថានភាពនៃការបង្រៀនភាសារអង់គ្លេសនៅសាលាបឋមសិក្សា** " ពិតប្រាកដមែន។

ថ្ងៃព្រហស្បតិ៍ ០៧ រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០

.......................................
**បណ្ឌិត នួន ទីរ៉ា**
នាយករងវិទ្យាស្ថានជាតិអប់រំ

.....................................
**ម៉ៅ សារឿន**
ប្រធានដេប៉ាតឺម៉ង់អប់រំ

# មាតិកា


សេចក្តីប្រកាសអះអាងរបស់បេក្ខជន....................i
លិខិតបញ្ជាក់....................ii
បញ្ជីតារាង....................vii
បញ្ជីក្រាហ្វិក....................viii
សេចក្តីថ្លែងអំណរគុណ....................x
មូលន័យសង្ខេប....................xi
ABSTRACT....................xiv
**ជំពូកទី១៖ សេចក្តីផ្តើម**....................២
១.១ សាវតា....................២
១.២ បញ្ហានៃការស្រាវជ្រាវ....................៩
១.៣ គោលបំណងនៃការស្រាវជ្រាវ....................១០
១.៤ សំណួរស្រាវជ្រាវ....................១១
១.៦ វិសាលភាព និងដែនកំណត់នៃស្រាវជ្រាវ....................១២
១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ....................១២
**ជំពូកទី២៖ ការរំលឹកទ្រឹស្តី**....................១៦
២.១ ឥទ្ធិពលនៃការអប់រំភាសាអង់គ្លេសក្នុងប្រទេសកម្ពុជា....................១៦
២.២ គោលបំណងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា....................២០
២.៣ កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់កម្រិតបឋមសិក្សាថ្នាក់ទី៤ -៥ និងទី៦ . ២១

២.៣.១ លទ្ធផលសិក្សារំពឹងទុកនៃការបង្រៀនជំនាញទាំងបួននៅកម្រិតបឋមសិក្សា ថ្នាក់ទី៤ - ៥ និង ទី៦ ........ ២២
២.៣.២. សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា ........ ២៦
២.៣.៣. លទ្ធផលរំពឹងទុកសម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៤ ........ ២៧
២.៣.៤. លទ្ធផលរំពឹងទុកសម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៥ ........ ២៨
២.៣.៥. លទ្ធផលរំពឹងទុកសម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៦ ........ ២៨
២.៣.៦ របាយមុខវិជ្ជា និងម៉ោងសិក្សាភាសាអង់គ្លេសនៅសាលាបឋមសិក្សា ........ ២៩
២.៣.៧ របៀបទូទៅនៃការរៀនភាសារបស់កុមារដើម្បីទទួលបានជំនាញភាសាអង់គ្លេស ៣០
២.៣.៨ ជំនាញនិងចំណេះដឹងរបស់គ្រូបង្រៀនក្នុងការបង្រៀនភាសាអង់គ្លេស ........ ៣៦
២.៣.៩ វិធីសាស្ត្របង្រៀននិងរៀនជំនាញភាសាអង់គ្លេស ........ ៤១
២.៣.៩.១ សំណេរលើខ្នង ( Back Writing) ........ ៤២
២.៣.៩.២ ល្បែងបោះបាល់ (Ball Game) ........ ៤២
២.៣.៩.៣ សណ្ឋានពាក្យ (Body Shapes) ........ ៤៣
២.៣.៩.៤ ល្បងប្រាជ្ញាពាក្យ ( Cross Word) ........ ៤៣
២.៣.៩.៥ លុប និងចងចាំ (Erase and Remember): ........ ៤៤
២.៣.៩.៦ ពាក្យអាថ៌កំបាំង (Hidden Words) ........ ៤៤
២.៣.៩.៧ ពាក្យ និងប្រយោគដែលមានអក្សរមិនត្រូវតាមលំដាប់ Jumbled Words and Sentences ........ ៤៤
២.៣.៩.៨ ការសម្តែងខ្លោន (Dramatization) ........ ៤៥
២.៣.៩.៩ វិធីនិទស្សន៍ (Demonstration Method) ........ ៤៥

២.៣.៩.១០ វិធីសាស្ត្រចោទសំណួរ ( Questioning)....................................................៤៦
២.៣.៩.១១ វិធីបែបស្រាវជ្រាវ Discovery method of teaching ....................................៤៦
២.៣.៩.១២ វិធីបែបគំរោង (Project Method)............................................................៤៦
២.៣.៩.១៣ វិធីឧទ្ទេស ( Lecture Method )..................................................................៤៧
២.៣.៩.១៤ វិធីបែបចលនា (Total Physical Response)...............................................៤៧
២.៣.៩.១៥ វិធីត្រាប់ភាសា (The Audio – Lingual Method) ........................................៤៧
២.៣.៩.១៦ ការច្រៀង ឬចំរៀង (Singing or Songs) ..................................................៤៨
២.៣.៩.១៧ ការនិទានរឿង (Story-telling) ..................................................................៤៨
២.៣.៩.១៨ តួរសំដែង Role-play..................................................................................៤៨
២.៣.១០ ការវាយតម្លៃលើលទ្ធផលសិក្សាភាសាអង់គ្លេសរបស់សិស្សនៅបឋមសិក្សា ... ៤៩
២.៣.១០.១ ការវាយតម្លៃតាមដំណាក់កាល................................................................ ៤៩
២.៣.១០.២ ការវាយតម្លៃបូកសរុប ........................................................................... ៤៩
ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ ..........................................................................៥១
៣.១ ដំណើរការនៃការសិក្សាស្រាវជ្រាវ.....................................................................៥១
៣.២ ឧបករណ៍ស្រាវជ្រាវ ..........................................................................................៥២
៣.៣ កម្រងសំណួរ.....................................................................................................៥២
៣.៣.១ កម្រងសំណួរសម្រាប់នាយក ........................................................................ ៥៣
៣.៣.២ កម្រងសំណួរគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ ......................... ៥៤
៣.៣.៣ កម្រងសំណួរសម្រាប់សិស្សានុសិស្សថ្នាក់ទី៤ ទី៥ និងទី៦ ............................. ៥៤

៣.៤ តំបន់គោលដៅ  ក្រុមគោលដៅ និងសំណាក ........................................................ ៥៥

៣.៤.១  ព័ត៌មានសាលាបឋមសិក្សា...................................................................................... ៥៥

៣.៤.២ ព័ត៌មានអ្នកចូលរួម............................................................................................... ៥៦

៣.៤.៣ ព័ត៌មានលំអិតរបស់នាយក និងនាយករង........................................................... ៥៦

៣.៤.៤   ព័ត៌មានលំអិតរបស់គ្រូ ........................................................................................ ៥៧

៣.៤.៥ ព័ត៌មានលំអិតរបស់សិស្ស......................................................................................... ៥៨

៣.៥ ដំណើរការនៃការប្រមូលទិន្នន័យ ................................................................................ ៥៩

៣.៦ វិធីសាស្ត្រវិភាគទិន្នន័យ.................................................................................................. ៦០

**ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវនិងការពិភាក្សា** ..................................................... ៦២

៤. ១. គណៈគ្រប់គ្រងសាលា.................................................................................................. ៦២

៤.១.១ ការអនុវត្តន៍សៀវភៅសិក្សាគោល ............................................................................ ៦២

៤.១.១.២ សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលានីមួយៗ ...................... ៦២

៤.១.១.៣ ការចែកសៀវភៅសិក្សាគោលភាសាអង់គ្លេស............................................... ៦៣

៤.១.១.៤ កម្រិតយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេស ....... ៦៤

៤.១.២ ការអនុវត្តន៍ម៉ោងសិក្សា.............................................................................................. ៦៥

៤.២ គ្រូបង្រៀនភាសាអង់គ្លេស ........................................................................................... ៦៦

៤.២.១ ការអនុវត្តន៍សៀវភៅសិក្សាគោល.............................................................................. ៦៦

៤.២.១.១ ការយល់ដឹងរបស់គ្រូចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេស.................. ៦៦

៤.២.១.២ ការយល់ដឹងរបស់គ្រូចំពោះឯកសារជំនួយការរៀននិងការបង្រៀន ................ ៦៧

៤.២.១.៣ ការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស.៦៨
៤.២.២ ការអនុវត្តន៍ម៉ោងសិក្សា ........................................................................ ៦៩
៤.២.២.១ ម៉ោងបង្រៀនសៀវភៅសិក្សាគោលក្នុងមួយសប្តាហ៍.................................. ៦៩
៤.២.២.២ បួនចំណុចក្នុងមួយមេរៀនដែលចំណុចនីមួយៗមានរយៈពេលដប់នាទី .........៧០
៤.២.២.៣ រយៈពេលបង្រៀនក្នុងមួយមេរៀន ៤០នាទី.............................................៧០
៤.២.៣ ការវាយតម្លៃសមត្ថភាពទាំងបួនរបស់សិស្ស ............................................ ៧១
៤.២.៣.១ ការវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស.................................................. ៧១
៤.២.៣.២ វិធីសាស្ត្រវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស.......................................... ៧២
៤.២.៣.៣ ការវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស..............................................៧៣
៤.២.៣.៤ វិធីសាស្ត្រវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស.......................................៧៤
៤.២.៣.៥ ការវាយតម្លៃសមត្ថភាពអានរបស់សិស្ស....................................................៧៥
៤.២.៣.៦ វិធីសាស្ត្រវាយតម្លៃសមត្ថភាពអានរបស់សិស្ស ........................................... ៧៦
៤.២.៣.៧ ការវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស............................................... ៧៧
៤.២.៣.៨ វិធីសាស្ត្រវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស........................................ ៧៨
៤.២.៤ ការអនុវត្តន៍វិធីសាស្ត្របង្រៀន .......................................................................៧៩
៤.៣ សិស្សានុសិស្ស............................................................................................. ៨២
៤.៣.១ ការអនុវត្តន៍សៀវភៅសិក្សាគោល ................................................................ ៨២
៤.៣.១.១ ការអនុវត្តន៍បង្រៀនមុខវិជ្ជាភាសាអង់គ្លេស ................................................ ៨២
៤.៣.១.២ ចំណង់ចំណូលចិត្តរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស........................ ៨៣

៤.៣.២ ម៉ោងរៀនភាសាអង់គ្លេសក្នុងមួយសប្តាហ៍.......................................................៨៤

៤.៣.២.១ វត្តមានរបស់គ្រូក្នុងការមកបង្រៀន...................................................................៨៥

៤.៣.២.២ ការប្រឡងប្រចាំខែ និងឆមាស.........................................................................៨៦

៤.៣.២.៣ ពិន្ទុសរុបសម្រាប់មុខវិជ្ជាភាសាអង់គ្លេស ១០ពិន្ទុ ............................................៨៦

៤.៣.៣ វិធីសាស្រ្តអនុវត្តក្នុងសៀវភៅសិក្សាគោលភាសាអង់គ្លេស ................................ ៨៧

ជំពូកទី៥៖  សេចក្តីសន្និដ្ឋាន និង សំណូមពរ...................................................................៩២

**៥.១ សេចក្តីសន្និដ្ឋាន**.........................................................................................................៩២

៥.២ សំណូមពរ ......................................................................................................... ៩៣

៥.៣ អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែម ............................................................. ៩៤

ឧបសម្ព័ន្ធទី១............................................................................................................... ៩៩

ឧបសម្ព័ន្ធទី២............................................................................................................ ១០៤

ឧបសម្ព័ន្ធទី៣ ........................................................................................................... ១០៨

# បញ្ជីតារាង

តារាងទី៖១. បម្រែបម្រួលនៃការអប់រំភាសាបរទេសក្នុងប្រទេសកម្ពុជា ( Vira,2002)......១៧

តារាងទី២៖ របាយម៉ោងមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១ដល់ថ្នាក់ទី៦..........................២៩

តារាង 0៣៖ អ្នកចូលរួមការស្រាវជ្រាវ.......................................................................៥៥

តារាង០៤៖ ព័ត៌មានសាលាបឋមសិក្សា....................................................................៥៥

តារាង 0៥៖ ព័ត៌មានលំអិតរបស់នាយក និងនាយករង ...............................................៥៦

តារាង 0៦៖ ព័ត៌មានលំអិតរបស់គ្រូ .........................................................................៥៧

តារាងទី0៧៖ ព័ត៌មានលំអិតរបស់សិស្ស....................................................................៥៨

តារាងទី០៨៖ ការអនុវត្តន៍វិធីសាស្រ្តបង្រៀនភាសាអង់គ្លេសរបស់លោកគ្រូអ្នកគ្រូ ......៦៤

តារាងទី០៩៖ ទស្សនៈរបស់នាយកលើការប្រើប្រាស់ម៉ោងសិក្សា ................................៧៩

តារាងទី១០៖ការអនុវត្តន៍វិធីសាស្រ្តបង្រៀនផ្សេងៗ............................................... ..៨៧

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី០១៖ ចំនួនសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលានីមួយៗ ......៦២

ក្រាហ្វិកទី០២៖ ការចែកសៀវភៅសិក្សាគោលភាសាអង់គ្លេស ....................................៦២

ក្រាហ្វិកទី០៣៖ កម្រិតយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅសិក្សាគោលភាសា អង់គ្លេស.......................................................................................................៦៣

ក្រាហ្វិកទី០៤៖ ការយល់ដឹងរបស់គ្រូចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេស.........៦៥

ក្រាហ្វិកទី០៥៖ ការយល់ដឹងរបស់គ្រូចំពោះឯកសារជំនួយការរៀននិងការបង្រៀន .......៦៦

ក្រាហ្វិកទី០៦៖ ការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសា អង់គ្លេស.......................................................................................................៦៧

ក្រាហ្វិកទី០៧៖ ម៉ោងបង្រៀនសៀវភៅសិក្សាគោលក្នុងមួយសប្តាហ៍ ...........................៦៨

ក្រាហ្វិកទី០៨៖ បួនចំណុចក្នុងមួយមេរៀនដែលចំណុចនីមួយៗមាន រយៈពេលដប់នាទី ..........................................................................................៦៩

ក្រាហ្វិកទី៩៖ រយៈពេលបង្រៀនក្នុងមួយមេរៀន ៤០នាទី ............................................៧០

ក្រាហ្វិកទី១០៖ ការវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស ..........................................៧១

ក្រាហ្វិកទី១១៖ វិធីសាស្ត្រការវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស .............................៧២

ក្រាហ្វិកទី១២៖ ការវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស.......................................៧៣

ក្រាហ្វិកទី១៣៖ វិធីសាស្ត្រការវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស.........................៧៤

ក្រាហ្វិកទី១៤៖ ការវាយតម្លៃសមត្ថភាពអានរបស់សិស្ស.............................................៧៥

ក្រាហ្វិកទី១៥៖ វិធីសាស្ត្រការវាយតម្លៃសមត្ថភាពអានរបស់សិស្ស...............................៧៦

ក្រាហ្វិកទី១៦៖ ការវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស .......................................៧៧

ក្រាហ្វិកទី១៧៖ វិធីសាស្ត្រការវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស........................៧៨

ក្រាហ្វិកទី១៨៖ ការអនុវត្តន៍ម៉ោងមុខវិជ្ជាភាសាអង់គ្លេស..........................................៨២

ក្រាហ្វិកទី១៩៖ ចំណាប់ចំណូលចិត្តរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស ..............៨៣

ក្រាហ្វិកទី២០៖ ម៉ោងរៀនភាសាអង់គ្លេសក្នុងមួយសប្តាហ៍..........................................៨៤

ក្រាហ្វិកទី២១៖ វត្តមានរបស់គ្រូក្នុងការមកបង្រៀន ................................................ ..៨៥

ក្រាហ្វិកទី២២៖ ការប្រឡងប្រចាំខែនិងឆមាស ........................................................ ..៨៦

ក្រាហ្វិកទី២៣៖ ពិន្ទុសរុបសម្រាប់មុខវិជ្ជាភាសាអង់គ្លេស ១០ពិន្ទុ.............................. ..៨៦

# សេចក្តីថ្លែងអំណរគុណ

ជាបឋម ខ្ញុំបាទសូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតដល់វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជននិងកីឡា និងអង្គការមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា Cambodia International Education Support Foundation ( CIESF) ដែលបានរៀបចំនិងផ្តល់អាហាររូបករណ៍ដល់ខ្ញុំបាទ បានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។

ទន្ទឹមនឹងនេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុត ចំពោះគណៈគ្រប់គ្រងបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងសាស្ត្រាចារ្យទាំងអស់ដែលបានចំណាយពេលដ៏មមាញឹក និងពេលវេលាដែលមានតម្លៃបំផុតមកបង្ហាត់បង្រៀន និងពន្យល់គ្រប់មេរៀនដល់យើងខ្ញុំទាំងអស់គ្នាដោយមិនគិតពីការនឿយហត់ឡើយ។ ជាពិសេស ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះលោកសាស្ត្រាចារ្យ **បណ្ឌិត នូវ ទីរ៉ា** និង **លោក ម៉ៅ សារឿន** ដែលបានលះបង់ទាំងកម្លាំងកាយកម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃដើម្បីផ្តល់ដើម្បីពន្យល់ណែនាំខ្ញុំបាទគ្រប់ជំហាន និងគ្រប់ដំណាក់កាល រួមទាំងមតិយោបល់និងទស្សនៈទានល្អៗ ទើបធ្វើឱ្យការស្រាវជ្រាវរបស់ខ្ញុំ នាពេលនេះទទួលបានជោគជ័យនិងដោយភាពរលូនជាទីបំផុត។ ជាមួយគ្នានេះដែរ ខ្ញុំបាទសូមថ្លែងអំណរគុណដល់មិត្តរួមថ្នាក់រួមជំនាន់ទី៦ ទាំងអស់ដែលតែងតែផ្តល់ជាកម្លាំងចិត្តតាមរយៈការចែករំលែកជាចំណេះដឹងបទពិសោធ ក៏ដូចជាព័ត៌មានពាក់ព័ន្ធផ្សេងៗដល់រូបខ្ញុំបាទ ដើម្បីឱ្យការស្រាវជ្រាវរបស់ខ្ញុំកាន់តែមានភាពងាយស្រួល។

ជាទីបញ្ចប់ ខ្ញុំបាទសូមប្រសិទ្ធិពរជ័យ សិរីសួស្តី ជូនចំពោះឯកឧត្តម លោកសាស្ត្រាចារ្យ និងមិត្តរួមថ្នាក់ទាំងអស់សូមឱ្យមានសុខភាពល្អបរិបូណ៌កម្លាំងពលំមាំមួនទទួលបានជោគជ័យគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ៖ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លាងឃ្លាតឡើយ ។

សូមអរគុណ!

# មូលន័យសង្ខេប

មុខវិជ្ជាភាសាអង់គ្លេស ជាមុខវិជ្ជាមួយដ៏សំខាន់ដូចជាមុខវិជ្ជាដទៃទៀតដែរ ដែលដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការរួមចំណែកក្នុងការពង្រឹងគុណភាពអប់រំ ហើយក៏តម្រូវឱ្យគ្រូបង្រៀននៅគ្រប់កម្រិតនៅតាមគ្រឹះស្ថានសិក្សា មានចំណេះដឹងលើភាសាអង់គ្លេសនេះ ក្នុងគោលបំណងដើម្បីអភិវឌ្ឍវិជ្ជាជីវៈ និងលើកកម្ពស់គុណវុឌ្ឍគ្រូបង្រៀន។ ស្របជាមួយគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវកម្មវិធីបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សាទូទាំងប្រទេសនៅកម្ពុជាក្នុងឆ្នាំ២០១២ រួមទាំងដាក់ចេញនូវសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦ ( English Grade 4 ,5 and 6)កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សា ថ្នាក់ទី៤ ទី៥ ទី៦( English Curriculum For Primary School Grade4,5 and 6)ដែលបានបង្កើតឡើងដោយ គណៈកម្មាធិការសម្រាប់អភិវឌ្ឍភាសាអង់គ្លេសនៅសាលារៀនកម្ពុជា(The Committee for Developing English Language in Cambodia Schools) និងអមជាមួយ ឯកសារណែនាំគ្រូប្រើប្រាស់សៀវភៅភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ ដើម្បីឱ្យសិស្សនៅតាមកម្រិតថ្នាក់នីមួយៗនៅបឋមសិក្សា មានចំណេះដឹងមូលដ្ឋាន ដោយផ្តើមចេញសញ្ញាណដំបូងនៃភាសាអង់គ្លេសដែលជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងសមត្ថភាពលើការស្តាប់ ការអាន ការនិយាយ និងការសរសេរ ជាពិសេស ឱ្យសិស្សមានមូលដ្ឋានគ្រឹះនៃភាសាអង់គ្លេស ដូចជា ស្រៈ ព្យញ្ជនៈ ពាក្យ ល្បះងាយៗ និងអត្ថបទខ្លីៗក្នុងបរិបទគ្រួសារ។ កន្លងមកនេះ គ្រូបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា ពុំទាន់សម្រេចបាននូវលទ្ធផលល្អក្នុងបង្រៀនភាសាអង់គ្លេសនៅឡើយទេ ពីព្រោះពួកគេនៅខ្វះវិធីសាស្រ្តនានាក្នុងការផ្តល់ចំណេះដឹងតាមរយៈការបង្រៀន ជាកត្តាដែលបណ្តាលឱ្យសិស្សពុំទទួលបានជោគជ័យនៅក្នុងការការរៀនសូត្ររបស់ពួកគេ ហើយនាំឱ្យពួកគេមានគុណវិបត្តិច្រើនក្នុងដំណើរការសិក្សារៀនសូត្រ និងអាចបណ្តាលប៉ះពាល់ដល់ប្រព័ន្ធអប់រំមួយផ្នែក ហើយប្រាកដជានាំឱ្យប៉ះពាល់កំណើនប្រជាជាតិនៃប្រទេសជាតិ។ គោលបំណងសំខាន់នៃការសិក្សាគឺដើម្បី ១) សិក្សាពីកត្តារួមចំណែកក្នុងការអនុវត្តន៍ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស ថ្នាក់ទី៤ ទី៥ និង ទី៦នៅកម្រិតសាលាបឋមសិក្សារដ្ឋប្រកបដោយប្រសិទ្ធភាព។ ២) រកឱ្យឃើញពីវិធីសាស្រ្តដែលគ្រូអនុវត្តក្នុងការបង្រៀនសៀវភៅសិក្សាគោលភាសាអង់គ្លេស។ការសិក្សាស្រាវជ្រាវនេះធ្វើឡើងដោយប្រើប្រាស់កម្រងសំណួរ

។ ការសិក្សាស្រាវជ្រាវបានផ្តោតរួម ទៅលើសាលាបឋមសិក្សារដ្ឋសរុបចំនួន៩ដែលស្ថិតនៅក្នុង ស្រុកត្រាំកក់ចំនួន៣ ស្រុកសំរោងចំនួន៣ និងក្រុងដូនកែវចំនួន៣ ក្នុងខេត្តតាកែវ។ សំណាកដែលបានចូលរួមមាននាយក/នាយករងសរុបចំនួន៩នាក់ ស្រី២នាក់ ក្នុងនោះដែរ នាយកចំនួន៥នាក់ និងនាយករងចំនួន៤នាក់ ។ គ្រូបង្រៀនភាសាអង់គ្លេសចំនួន ២៤នាក់ ស្រី ៦នាក់ ក្នុងនោះដែរ គ្រូថ្នាក់ទី៤ ចំនួន៩នាក់ គ្រូថ្នាក់ទី៥ ចំនួន៧នាក់ និងគ្រូថ្នាក់ទី៦ ចំនួន៨នាក់។ សិស្សានុសិស្សសរុប ១៧៨នាក់ ស្រី ១១៥នាក់ ក្នុងនោះដែរ សិស្សថ្នាក់ទី៤ ចំនួន៧៥ នាក់ ថ្នាក់ទី៥ ចំនួន ៤០នាក់ ថ្នាក់ទី៦ចំនួន៦៣នាក់។ ការស្រាវជ្រាវធ្វើឡើងតាមបែបបរិមាណវិស័យ។ រាល់ទិន្នន័យដែលបានប្រមូល ត្រូវបានយកមកបញ្ចូលនឹងវិភាគតាមរយៈការប្រើស្ថិតិពណ៌នា( Descriptive Statistics) ដូចជា ការរកភាគរយ( Percentages) និងប្រេកង់ ( Frequencies) ។ ការសិក្សាស្រាវជ្រាវនឹងជួយជំរុញឱ្យការអនុវត្តន៍ការប្រើប្រាស់ សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅសាលាបឋមសិក្សា ប្រកបដោយគុណភាព និងបង្ហាញពីវិធីសាស្ត្រនានា ប្រកបដោយប្រសិទ្ធភាពក្នុងការអនុវត្តន៍ក្នុងសៀវភៅសិក្សាគោលថ្នាក់ទី៤ទី៥និងទី៦។ ការសិក្សាស្រាវជ្រាវនេះ បានរកឃើញថា កត្តាអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស មួយចំនួនមិនទាន់បានជោគជ័យ ដោយសារតែ ចំនួនសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលាមិនទាន់មានគ្រប់គ្រាន់ ការយល់ដឹងរបស់គ្រូចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេស (ច្បាស់ ៥៤.២% ដឹងតិចតួច២០.៨% និងដឹងមិនច្បាស់២៥.៥%) ។ការយល់ដឹងរបស់គ្រូចំពោះឯកសារជំនួយការរៀននិងការបង្រៀន(ច្បាស់ ៣៧.៥% ដឹងតិចតួច ៣៣.៣% និងដឹងមិនច្បាស់ ២៩.២%) ។ ការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស (ច្បាស់ ២៧.២% តិចតួច ២៥% មិនច្បាស់២៩.២% មិនដឹង៨.៣%) ការអនុវត្តន៍ម៉ោងបង្រៀនមិនស្មើគ្នា និង ការអនុវត្តន៍ការបង្រៀនមេរៀនលើចំណុចនីមួយៗ( A,B,C...)មិនស្មើគ្នា។ ការវាយតម្លៃសមត្ថភាពជំនាញទាំងបួន រួមមាន តាមដំណាក់ បូកសរុប តំណាក់និងបូកសរុបខុសៗគ្នាតាមសប្តាហ៍។ វិធីសាស្ត្រដែលមានប្រសិទ្ធភាព ផ្ទុយទៅវិញ គ្រូពុំសូវអនុវត្ត ដូចជា គ្រូចំនួន ១៦.៧% បានអនុវត្តវិធី (ALM=(Audio-Lingual Method) និង គ្រូចំនួន៣៣.៣% បានអនុវត្តវិធី (TPR= Total Physical Response)។ ការសិក្សាស្រាវជ្រាវ សូមផ្តល់អនុសាសន៍ឱ្យគ្រូបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សាស្វែងយល់បន្ថែមទៀតទៅលើការអនុវត្តន៍កម្មវិធី

សិក្សាលម្អិត ឯកសារជំនួយការរៀននិងការបង្រៀនលើសៀវភៅសិក្សាគោល និងពង្រឹងទៅវិធីសាស្រ្តបង្រៀនឱ្យបានសម្បូរបែបទៅតាមបរិបទនៃមេរៀននីមួយៗ ហើយការស្រាវជ្រាវនេះ នឹងជួយឱ្យគ្រូកាន់តែល្អប្រសើរឡើងចំពោះការអនុវត្តន៍សៀវភៅសិក្សាគោលភាសាអង់គ្លេស។ ការសិក្សានេះបានសន្មត់ថា សិស្ស និងគ្រូពិតជាសម្រេចបានគោលដៅតែមួយទៅលើការបង្រៀននិងរៀនពោលគឺសិស្សមានសមត្ថភាពលើជំនាញទាំងបួន និងគ្រូបង្រៀនប្រកបដោយគុណភាពឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកទៅតាមកម្រិតថ្នាក់។

ABSTRACT

English subject is as important as other subjects, which plays a crucial part in enhancing the quality of education thereby requiring all teachers at all educational institution levels have a better knowledge of English in the pursuit of empowering teacher professional standards and teacher qualifications. In the meantime, Ministry of Education Youth and Sport has put in practice nationwide English program for primary school grade 4,5 and 6 since 2012, together with English text book grade 4,5 and 6 accompanying by English curriculum framework for primary school grade 4,5 and 6, developed by The Committee for Developing English Language in Cambodia Schools plus with text book manual grade 4,5 and 6 in order that students at each level in primary schools have basic knowledge on the following topics: the alphabet; vowels; relevant vocabularies; grammar structures; short texts about the members of the family, especially to develop proficiency in listening, speaking, reading and writing skills, students must receive instruction in all these four elements. Since then Primary school English teachers have not yet achieved good teaching outcome because a range of teaching methods are not effectively fit in the classroom so that students do not achieve success criterias in lesson, and enables them to have academic barrier which both negatively affects the partial education system and the national growth of country. The objectives of study therefore were to find out 1) What main contributed factors which enable English primary school teachers to effectively use English text book grade 4, 5 and 6. 2) To examine methods of teaching English language skills in primary schools in Takeo. The study was carried out using descriptive designs. The target population was 9 public primary schools. The researcher used simple random sampling technique to sample a total of 5 directors and 4 deputy directors among them ,there were two females; a total of 24 teachers of English language among them, there were 6 females: there were 9 English teachers grade 4, 7 English teachers grade 5, and 8 English teachers grade 6 in 9 public primary schools in Takeo province; a total of 178 primary school pupils there were 115 females among them: 75 pupils grade 4, 40 pupils grade 5, and 63 pupils grade 6. The set of directors, English primary teachers, and pupil questionnaires were manipulated as research instruments. Quantitative data was collected. Data was computed and analyzed by the use of descriptive statistics such as use of percentages and frequencies. The study will effectively promote the consolidation of English text book grade 4, 5, and 6 strengthen the implementation and integrate the potential and applicable methods of teaching in the English text books. The study also found out ineffective factors involve in English textbook implementation such as the shortage of the textbook in school, the gap of teacher competence on textbook application (clearly known 54.2%, less known 20.8%, and unknown 25.5%) the gape of teacher competence on teaching and learning manuals (clearly known 37.5%, less known 33.3 %, and unknown 29.2 %), the gape of teacher comprehension on English primary curriculum framework (clearly known 27.2%, less known 25%, and unknown 29.2%) uneven teaching schedule hour and time limit of each point in the lesson (A,B,C) ,inequivalent assessment of the four strands: speaking, listening, speaking, and writing skills ( summative, formative, and half of summative and formative), ineffective teaching methods. This study recommended that all the primary teachers of English have to improve their better competency level on English textbook and curriculum. In addition, this study will upgrade high competence, knowledge and experience on the effective text book application. This study assumed that the teachers and pupils achieved the common teaching and learning input/output leads effectively to the successful outcome of basic communicative competence in the above four strands in line with expected teaching and learning outcome set in curriculum.

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

ជំពូកនេះនិយាយពីសាវតា បញ្ហាស្រាវជ្រាវ គោលបំណងស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការសិក្សា វិសាលភាពនិងដែនកំណត់ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ និងកាលបរិច្ឆេទនៃការស្រាវជ្រាវ។

## ១.១ សាវតា

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា តាមរយៈកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៦នៃរដ្ឋសភា បានកំណត់ដាក់ចេញនូវគោលដៅជាយុទ្ធសាស្ត្រ គោលនយោបាយធំៗជាអាទិភាពគោលនយោបាយអភិវឌ្ឍតាមវិស័យ និងវិធានការជាក់ស្តែងជាអាទិភាពសម្រាប់អភិវឌ្ឍចាប់ពីឆ្នាំ២០១៩ទៅ ដែលជាត្រីវិស័យ សម្រាប់តម្រង់ទិសសកម្មភាពរបស់រាជរដ្ឋាភិបាល ក្នុងការបំពេញភារកិច្ចសម្រាប់បម្រើជាតិ និងអភិវឌ្ឍប្រទេសកម្ពុជាទាំងមូល។ ទន្ទឹមនឹងនេះដែរ ដើម្បីឆ្លើយតបទៅនឹងការជំរុញការអភិវឌ្ឍន៍ប្រទេសនៅក្នុងដំណាក់កាលថ្មីនេះ រាជរដ្ឋាភិបាលបានកំណត់យក គោលដៅយុត្តិសាស្ត្រ៤ និងវិស័យអាទិភាព៤ ជាការប្តេជ្ញាចិត្តក្នុងការបន្តអនុវត្ត យុទ្ធសាស្ត្រចតុកោណនៅក្នុងដំណាក់កាលទីបួននេះ។ តាមស្ថានភាពជាក់ស្តែង ប្រទេសកម្ពុជាបានកំពុងបោះជំហានទៅរកវឌ្ឍនភាពនៃការអភិវឌ្ឍន៍ប្រកបដោយ កាឡានុវត្តភាព ទាំងកំណើនសេដ្ឋកិច្ច និងស្ថេរភាពនយោបាយ ប្រមុខរាជរដ្ឋាភិបាលក្នុងនីតិកាលទី៦នៃរដ្ឋសភា បានបន្តអនុវត្តផែនការយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលបានចាត់ទុកការពង្រឹងគុណភាពវិស័យអប់រំ ជាកម្លាំងស្នូលដ៏សំខាន់និងជាវិស័យអាទិភាពបំផុតក្នុងចំណោមវិស័យនានា ដើម្បីរួមចំណែកក្នុងការកសាងប្រទេសប្រកបដោយចីរភាព។ លើសពីនេះទៅទៀត ប្រមុខរាជរដ្ឋាភិបាល បានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិរយៈពេលវែង ដែលមានមហិច្ឆតា ប្រែក្លាយពីប្រទេសកសិកម្មទៅប្រទេសឧស្សាហកម្មនៅឆ្នាំ២០២៥ និងក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ហើយក្លាយទៅជាប្រទេសអភិវឌ្ឍនាឆ្នាំ២០៥០។ ស្របជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលបានដាក់ចេញនូវយុទ្ធសាស្ត្រចំបងៗជាច្រើនបន្ថែមទៀតក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ធ្វើឱ្យមានកំណើនសេដ្ឋកិច្ច ដូច

ជាការកាត់បន្ថយនូវភាពក្រីក្រ តាមរយៈការធ្វើកំណែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យ រួមទាំងវិស័យអប់រំផងដែរ។

នៅក្នុងនោះដែរ យើងឃើញថា វិស័យអប់រំ គឺជាវិស័យអាទិភាពបំផុតដែលស្ថិតនៅក្នុងចតុកោណទីមួយ នៅក្នុងការអភិវឌ្ឍន៍ប្រទេស។ ដើម្បីរួមចំណែកដ៏ធំក្នុងយុទ្ធសាស្ត្រចតុកោណរបស់ប្រមុខរដ្ឋាភិបាល ក្រសួងអប់រំ យុវជននិងកីឡា បានខិតខំប្រឹងប្រែងពង្រឹងវិស័យអប់រំ តាមរយៈការធ្វើកំណែទម្រង់វិស័យអប់រំជាលំដាប់ ដោយដាក់ចេញនូវវិធានការកំណែទម្រង់១៥ ចំណុច ដោយឈរលើមូលដ្ឋានសសរស្តម្ភ៥ ដើម្បីធានានូវគុណភាពអប់រំប្រកបដោយចីរភាព និងពង្រឹងនូវគុណវុឌ្ឍមន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ទាំងការងារគ្រប់គ្រង និងភាពជាអ្នកដឹកនាំអប់រំ ក្នុងគោលដៅរួម កសាងធនធានមនុស្សជាកម្លាំងចលករមួយចាំបាច់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ។ គោលដៅនៅក្នុងសាលារៀនចំណេះទូទៅ គឺការកសាងធនធានមនុស្សឱ្យក្លាយជាពលរដ្ឋពេញលេញ ដែលប្រកបដោយវិជ្ជាសម្បទា សីលសម្បទា និងចរិយាសម្បទា ហើយត្រូវបានធានាថា សិស្សអាចយកចំណេះជំនាញទៅប្រើប្រាស់ដោយឆ្លើយតបទៅទីផ្សារការងារបច្ចុប្បន្នពិតប្រាកដប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។ដើម្បីសម្រេចឱ្យបាននូវគោលដៅនេះ ក្រសួងអប់រំ យុវជននិងកីឡា បានអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលជាបន្តបន្ទាប់។ទន្ទឹមនឹងនេះដែរ ក្រសួងអប់រំបានដាក់បញ្ចូលមុខភាសាអង់គ្លេសសម្រាប់បឋមសិក្សាចំណេះទូទៅចាប់ពីថ្នាក់ទី៤ រហូតដល់ថ្នាក់ទី៦។ ដោយយោងទៅលើមាត្រាទី៦៧ នៃរដ្ឋធម្មនុញ្ញប្រទេសកម្ពុជាបានចែងថា រដ្ឋបានកំពុងធ្វើការអនុម័តកម្មវិធីអប់រំ ដោយយោងទៅលើគោលការណ៍នៃគរុកោសល្យសម័យទំនើប ដែលបានរួមបញ្ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេសដែលត្រូវបានលើកកម្ពស់និងពង្រីកតាមរយៈការបង្រៀន។ ច្បាប់អប់រំកម្ពុជាឆ្នាំ២០០៧ បានលើកឡើងថា ភាសាបរទេសគឺភាសាអន្តរជាតិដែលត្រូវបានចាត់ទុកថា ជាមុខវិជ្ជាពិសេសមួយសម្រាប់កម្មវិធីអប់រំមូលដ្ឋានគ្រឹះនៃការអប់រំចំណេះដឹងទូទៅ ដែលឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស។ គោលនយោបាយសម្រាប់ការអភិវឌ្ឍន៍កម្មវិធីសិក្សាឆ្នាំ២០០៥-២០០៩ របស់ក្រសួងអប់រំ យុវជននិងកីឡា បានបញ្ជាក់បន្ថែមយ៉ាងច្បាស់ទៀតថា គោលនយោបាយកម្មវិធីសិក្សានេះ ឆ្លើយតបទៅនឹងតម្រូវការសាកលភាវូបនីយកម្ម តំបន់ភាវូបនីយកម្ម និងបុគ្គល

នីយកម្ម។ គោលនយោបាយនឹងរួមចំណែកផ្តល់ឱកាសទទួលបាននូវការអប់រំមូលដ្ឋាន ដោយសមធម៌ និងពង្រឹងពង្រីកជាមួយស្ថាប័នដៃគូរទាំងរដ្ឋ និងឯកជនដើម្បីធានាឱ្យការអប់រំទទួលបាននូវគុណភាពខ្ពស់ និងបង្កើនគណនេយ្យភាពក្នុងការអភិវឌ្ឍស្តង់ដានៅកម្រិតសាលារៀនបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ មានគោលនយោបាយ២ដែលឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤(SDG4) ដូចខាងក្រោម៖

- គោលនយោបាយទី១៖ ធានាឱ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាប័ន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។
- គោលនយោបាយទី២៖ ធានាភាពសក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់។

ការបង្រៀនភាសាអង់គ្លេស គឺជាអាទិភាពមួយដែលក្រសួងបានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សានៅ បឋមសិក្សាថ្នាក់ទី៤ទី៥ និងទី៦ និងលើកទឹកចិត្តឱ្យសាលារៀនទាំងអស់ផ្តល់ការបង្រៀនភាសាអង់គ្លេសដល់សិស្សានុសិស្ស នៅបឋមសិក្សាដោយផ្អែកលើការប្រើប្រាស់ធនធានងាយៗអាចរកបាននៅតាមមូលដ្ឋានរស់នៅនិងនៅតាមសាលារៀន ដោយមិនចាំបាច់ពឹងផ្អែកទាំងស្រុងលើធនធានរបស់ក្រសួងអប់រំ។ ដើម្បីជួយសម្រួលដល់ការបង្រៀន នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានកសាងនូវឯកសារជំនួយនានាសម្រាប់ការប្រើប្រាស់របស់គ្រូ ទទួលការរ៉ាប់រងដោយគម្រោងលើកម្ពស់គុណភាពអប់រំ (Enhancing Education Quality Project) ដែលស្ថិតក្រោមការឧបត្ថម្ភជំនួយរបស់ធនាគាអភិវឌ្ឍអាស៊ី ( Asian Development Bank) និង រួមសហការជាមួយអង្គការអ្នកស្ម័គ្រចិត្តបម្រើការនៅបរទេស (VSO) ភ្នាក់ងារភីស ខ័ស កម្ពុជា (Peace Corps: Cambodia) និង British Council ។

ស្របទៅតាមបរិបទសាកលភាវូបនីយកម្ម ភាសាអង់គ្លេសគឺជាភាសាសកលលោក។ បើយោងទៅលើ Genesse [1](1994) និយាយថា " ភាសាអង់គ្លេស បានក្លាយទៅជាភាសាយាន្តមានលក្ខណៈជាអន្តរជាតិ ហើយកំពុងតែដើរតួនាទីកាន់តែសំខាន់ឡើងនៅក្នុងជីវិតរស់នៅ និងជីវិតការងារប្រចាំថ្ងៃរបស់មនុស្ស ដោយផ្ដើមពី វិទ្យាសាស្ត្រនយោបាយ សេដ្ឋកិច្ច តំហែទាំសុខាភិបាល រហូតដល់ ការអប់រំ និងការងារកម្សាន្តផ្សេងៗ"។ កត្តារួមចំណែកទាំងអស់នេះ ធ្វើឱ្យការដាក់បញ្ចូលការបង្រៀននិងរៀនភាសាអង់គ្លេសនេះ កាន់តែសំខាន់នៅក្នុងប្រព័ន្ធអប់រំទូរទាំងប្រទេស។ ក្នុងនោះដែរ ប្រទេសកម្ពុជាក៏បានប្រើប្រាស់ភាសាអង់គ្លេសជាភាសាបរទេស យ៉ាងសំខាន់ផងដែរនៅក្នុងកម្មវិធីសិក្សា។ ស្របគ្នាទៅនឹងការកំណត់និយមន័យរបស់វចនានុក្រមកម្រិតខ្ពស់របស់Oxford, សិស្សអន្តរជាតិបោះពុម្ពឆ្នាំ(2010) (Oxford Advanced Learner Dictionary, International Student Edition (2010) បានកំណត់និយមន័យថា ភាសាគឺជាប្រព័ន្ធនៃការប្រាស្រ័យទាក់ទងក្នុងការនិយាយ និងការសរសេរដែលត្រូវបានប្រើប្រាស់ដោយមនុស្សនៃប្រទេស ឬតំបន់ជាក់លាក់មួយ។ រីឯភាសាអង់គ្លេស គឺភាសាចម្បងដែលត្រូវបានប្រើសម្រាប់ការទំនាក់ទំនងនៅក្នុងសាលារៀន។ ភាពស្ទាត់ជំនាញនៃភាសាគឺជាគន្លឹះក្នុងការលើកកម្ពស់ការយល់ដឹង ការបកស្រាយនិងការវិភាគរបស់សិស្សជាពិសេសនៅពេលអាន និងឆ្លើយសំណួរនៅក្នុងការប្រឡង ហើយវាទាក់ទងទៅនឹងមុខវិជ្ជាផ្សេងៗទៀតផងដែរ។ ភាសាអង់គ្លេស គឺមានសារៈសំខាន់ណាស់នៅក្នុងថ្នាក់បឋមសិក្សាទាំងអស់នៅគ្រប់សាលាទាំងអស់។ Goodson និងPeter[2] (1990) បានបង្ហាញថាការបង្រៀនមុខវិជ្ជាភាសាអង់គ្លេសជាមូលដ្ឋានគ្រឹះ នៃការអនុវត្តលើមុខវិជ្ជាផ្សេងទៀត។ ស្របគ្នាទៅនឹងគោលគំនិតរបស់ក្រសួងអប់រំ យុវជននិងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណោះទូទៅពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដើម្បីផ្ដល់ឱកាសឱ្យសិស្សជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសម្រាប់ជាគ្រឹះ សម្រាប់បន្តការសិក្សានៅមធ្យមសិក្សា នឹងដើម្បីឱ្យសិស្សានុសិស្សទទួលបាននូវជំនាញភាសាដែលមានលក្ខណៈគ្រប់គ្រាន់ ដែលអាចឱ្យពួកគេទំនាក់ទំនងគ្នាយ៉ាងស្ទាត់ជំនាញ។ Murray[3] (1966) សង្កេតឃើញថា ភាសាគឺជាឧបករណ៍ដ៏សំខាន់មួយសម្រាប់កំណត់ពី

---

[1] Geneses, F. (1994) *Integrating Language and Content Lessons from Immersion*; MC Grill University.

2 Goodson and Peters (1990) *Bringing English to Order,* vii-xv London, New York: Holt Rernhert and Winston Inc.,

3 Murray, S. (1966) Skills in Reading. Toronto: McGraw Hill.

របៀបដែលកុមាររៀននិងគិត ព្រោះរាល់ការបញ្ចេញគំនិត ត្រូវបានបញ្ជូនតាមរយៈពាក្យ។ Adagi [4](1997) បញ្ជាក់ថា ភាសាដើរតួនាទីជាឧបករណ៍មួយសម្រាប់លើកកម្ពស់ឯកភាពជាតិ។ ភាសាអង់គ្លេស ជាភាសាយាន ហើយត្រូវបានគេប្រើយ៉ាងទូលំទូលាយនៅក្នុងបណ្តាប្រទេសផ្សេងៗ ដូច្នេះហើយ ចំពោះកុមារ ភាសាអង់គ្លេសមានសារៈសំខាន់ណាស់សម្រាប់កុមារនៅបឋមសិក្សាដែលរៀនភាសាអង់គ្លេស ដូច្នេះពួកគេមិនត្រឹមតែប្រើប្រាស់វាសម្រាប់ការប្រឡងទេ ប៉ុន្តែថែមទាំង ផ្តល់ឱកាសឱ្យពួកគេត្រៀមរៀបចំខ្លួនរបស់ពួកគេផងដែរ សម្រាប់ជាបុគ្គលជាផ្នែកមួយនៃសហគមន៍អន្តរជាតិ។ សមាគមការនិយាយភាសាអាមេរិក American Speech Language Hearing Association (2014) យល់ស្របថា ក្មេងៗអាចរៀនភាសាអង់គ្លេសនៅសាលារៀនជាលើកដំបូង ហើយកុមារទាំងនេះ មានពេលវេលាកាន់តែងាយស្រួលរៀនភាសាទីពីរនេះ ផ្ទុយទៅវិញ ការអនុវត្តន៍សម្រាប់ការរៀនភាសារបស់មនុស្សពេញវ័យ ការរៀនភាសាមួយនេះបើប្រៀបធៀបទៅនឹងកុមារតូចៗ កុមារទាំងអស់នោះ បានរៀនបានលឿនជាង។វចនានុក្រម Oxford Advanced Learners (2010) បញ្ជាក់ថា វាត្រូវការពេលយូរដើម្បីរៀននិយាយភាសា។ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយសិស្សឱ្យទទួលនិងប្រើប្រាស់ជំនាញភាសា និងគ្រូឧស្សាហ៍ណែនាំឬនិយាយជាភាសាអង់គ្លេសទៅកូនសិស្សនៅក្នុងថ្នាក់។ Chondhury [5](2014) យល់ស្របថា វាជាទំនួលខុសត្រូវរបស់គ្រូបង្រៀនភាសាអង់គ្លេសទាំងអស់គ្នាត្រូវជួយសិស្សឱ្យចេះអភិវឌ្ឍសមត្ថភាពនិយាយនិងសរសេរឱ្យបានល្អ។ ដូច្នេះ គ្រូបង្រៀន គឺជាមនុស្សសំខាន់ក្នុងការជួយ និងអភិវឌ្ឍសមត្ថភាពភាសាកុមារ។ Sereti [6](ឆ្នាំ1993) អះអាងថា កិច្ចការនៃការធ្វើឱ្យសិស្សបង្ហាញពីសមត្ថភាពរបស់ពួកគេបានទាំងសមត្ថភាពនិយាយនិងសមត្ថភាពសរសេរ គឺស្ថិតនៅលើទំនួលខុសត្រូវរបស់គ្រូ។ គ្រូបង្រៀនភាសា គឺអាចផ្តល់ឱ្យសិស្សនូវបទពិសោធន៍ដែលជំរុញឱ្យមានទទួលចំណេះដឹង និងការប្រើប្រាស់ជំនាញភាសាអង់គ្លេស។ គ្រូដែលមានសមត្ថភាព (ចំណេះដឹង និងជំនាញ),មានលក្ខណៈសម្បត្តិមុខវិជ្ជាជីវៈធ្វើឱ្យកុមាររៀនបានភាសាលឿន។ Chondhury (2014) បានចង្អុលបង្ហាញថា គ្រូបង្រៀនត្រូវតែមានបទពិសោធនិងការបណ្តុះបណ្តាលដែលអាចឱ្យពួកគេយល់និងអនុវត្តនៃភាពចម្រុះនៃគ្រាមភាសា។ គ្រូបង្រៀន

4 Adagi, O. (1997) Status of Education in Kenya Indicators for Planning and Policy Formulation, Nairobi: Institute of Policy Analysis and Research (IPAR.).

5 Chondhury, A.S. (2014) *Classroom Role of English Teachers. The Innovative:* on line.

6 *Sereti, J.R. (1993) Large Teaching Methodologies for Large Classes, English A cross the Curriculum in Difficult Circumstances) "Proceedings of the Conference on English across the Curriculum: Kenya Context, Nairobi: British Council.*

អាចបង្កើនភាសាកុមារ ដោយលើកទឹកចិត្តសិស្សឱ្យនិយាយអំពីព្រឹត្តិការណ៍ ឬវត្ថុដែលធ្វើឱ្យពួកគេចាប់អារម្មណ៍។ គ្រូបង្រៀនអាចសម្រេចបាននូវចំណុចនេះដោយអនុញ្ញាត ឱ្យកុមារពិភាក្សាបទពិសោធន៍របស់ពួកគេតាមរយៈការសម្តែងភាពយន្ត និទានកថា ការនិទានរឿង និងការជជែកវែកញែក។ នេះត្រូវបានគេហៅថាការបង្រៀនតាមរយៈការធ្វើឱ្យសិស្សបន្សុំាទៅនិងភាសា។ ការបង្រៀនតាមរយៈការធ្វើឱ្យសិស្ស បន្សុំាទៅនឹងភាសាអនុញ្ញាតឱ្យអ្នករៀនប្រើប្រាស់ជំនាញភាសាអង់គ្លេស។ MOE (2001) យល់ស្របថាសិស្សានុសិស្ស រៀនភាសាលឿនជាងមុន នៅពេលពួកគេត្រូវបានបន្សុំាទៅនឹងជំនាញទាំងបួន។ អាចនិយាយបន្ថែមទៀតថា នៅពេលបង្រៀនជំនាញភាសាអង់គ្លេស គ្រូមិនគួរបង្រៀនជំនាញភាសាបួននៅដាច់ពីគ្នានោះទេ។ ការធ្វើឱ្យកុមារសុំាទៅនឹងជំនាញទាំងបួននៃភាសា ជួយបង្កើនជំនាញទទួលបានភាសារបស់កុមារ។កុមារត្រូវការលើកទឹកចិត្តឱ្យស្តាប់អ្នកដទៃទៀត មុនពេលពួកគេចូលរួមនៅក្នុងការសន្ទនា។ គ្រូត្រូវលើកទឹកចិត្តឱ្យកុមារនិយាយអំពីព្រឹត្តិការណ៍ ឬវត្ថុដែលពួកគេចាប់អារម្មណ៍ នេះបានធ្វើអោយប្រសើរឡើង នូវភាពស្ទាត់ជំនាញនៃការនិយាយរបស់ពួកគេ។ សុន្ទរកថា គឺជាវិធីសាស្ត្រលឿនបំផុត ជាទូទៅ ត្រូវបានប្រើប្រាស់នៃការទំនាក់ទំនងរវាងមនុស្ស។ ជាមួយនឹងការនិយាយ កុមារត្រូវបានបង្រៀនអំពីរបៀបស្តាប់។ ក្មេងតែងតែមិនស្តាប់ដោយយកចិត្តទុកដាក់នៅក្នុងថ្នាក់ ពីព្រោះថាកុមារមួយចំនួនងាយទទួលរងការរំខានដោយការរំញោចខាងក្រៅ និងមិនអានរៀនបាន ។ មិនមានការប្រាស្រ័យទាក់ទងដ៏សំខាន់ណាមួយបានធ្វើឡើងដោយមិនប្រើជំនាញក្នុងការស្តាប់ និងនិយាយទេ ព្រោះទាំងពីរជំនាញនេះត្រូវបាន បំពេញបន្ថែមគ្នាទៅវិញទៅមក។ MOE (2001) បញ្ជាក់ថា ការនិយាយនិងការស្តាប់គឺជាមូលដ្ឋានគ្រឹះសម្រាប់រៀនភាសា។ Popp (ឆ្នាំ1996) បានអះអាងថា គ្រូបង្រៀនដែលចាត់ទុកការស្តាប់និងនិយាយជាឧបករណ៍សម្រាប់ការសិក្សារួមបញ្ចូលក្នុងការរៀន និងការអនុវត្តន៍ជំនាញទាំងនេះដោយសារពួកគេជឿជាក់ថា សមត្ថភាពក្នុងការនិយាយ និងស្តាប់មានប្រសិទ្ធភាពជួយដល់ការសិក្សាទាំងអស់។ សិស្សដែលចេះនិយាយមិនស្ទាត់ជំនាញ ឬនិយាយមិនបានត្រឹមត្រូវ អាចក្លាយទៅជាអ្នកនិយាយមិនសូវល្អ ហើយជាលទ្ធផលពួកគេទទួលបានបរាជ័យក្នុងការប្រាស្រ័យទំនាក់ទំនង និងធ្វើអន្តរកម្មជាមួយអ្នកដទៃ។ វាជាការសំខាន់ក្នុងការកត់សម្គាល់ជំនាញភាសាដទៃទៀតដូចជា ការអាន និងការសរសេរអាចអភិវឌ្ឍបាន លុះត្រាតែ កុមារទទួលបានការរៀនសូត្រនៅសាលារៀន។ វាគួរតែត្រូវបាន

កត់សម្គាល់ថា ការអប់រំសម័យទំនើបត្រូវផ្តោតលើសមត្ថភាពអាន និងសរសេរ។ យោងទៅតាម MOE (2001) គ្រឹះនៃអក្ខរកម្មទាំងអស់គឺក្នុងការស្តាប់ និងការនិយាយ។ តួនាទីរបស់មាតាបិតា ក្នុងការអភិវឌ្ឍភាសារបស់កុមារមិនត្រូវមើលរំលងទេ។ ឪពុកម្តាយបានផ្តល់នូវធាតុចូល និងធ្វើជាគំរូជាភាសាទីមួយរបស់កុមារ។ ឪពុកម្តាយ និងគ្រូអង់គ្លេសត្រូវការផ្តល់ឱ្យអ្នកសិក្សានូវគំរូដ៏ល្អបំផុតនៃភាសាអង់គ្លេស។ ប៉ុន្តែ អ្នកទាំងពីរ ត្រូវនិយាយភាសារបស់ពួកគេឱ្យបានត្រឹមត្រូវជាមុនសិន ក្នុងករណីដែលពួកគេប្រើប្រាស់ភាសាដែលធ្វើឱ្យមានកំហុសឆ្គង អាចធ្វើឱ្យពួកគេមានកំហុសដូចយើងដែរ។ សមាគមសុន្ទរកថារបស់អាមេរិក ( American Speech Language Association) (2014) បញ្ជាក់ថា ឪពុកម្តាយជាមនុស្សសំខាន់ អ្នកផ្តល់ការថែទាំផ្តល់នូវគំរូភាសាដ៏រឹងមាំ។ អាចបន្ថែមទៀតថា ប្រសិនបើអ្នកមិនអាចប្រើភាសាបានល្អ អ្នកមិនគួរបង្រៀនវាទេ។ ការពង្រឹងភាសារបស់កុមារ គឺមានសារៈសំខាន់ក្នុងការបង្កើនការរៀនភាសាចំពោះកុមារ។ ម្តាយម្នាក់ដែលសរសើរ និងឆ្លើយតបទៅនឹងអ្វីដែលកុមារនិយាយថាធ្វើឱ្យក្មេងរៀនលឿន។ Quist (ឆ្នាំ 2000) បានអះអាងថា ការកោតសរសើរពីទេពកោសល្យ និងលើកទឹកចិត្ត គឺវិធីសាស្ត្រដែលអាចត្រូវបានប្រើដើម្បីលើកទឹកចិត្ត អារម្មណ៍នៃទំនុកចិត្ត និងសមិទ្ធផល ហើយក៏កែលម្អផងដែរនូវឥរិយាបថនិងការផ្លាស់ប្តូរឥរិយាបថរបស់កុមារ។ គ្រូបង្រៀនត្រូវសរសើរដល់អ្នករៀនម្នាក់ៗដោយញញឹម និងនិយាយទៅកាន់ពួកគេក្នុងលក្ខណៈមិត្តភាព។ នេះជាវិធីមួយ ដែលគ្រូបង្រៀនធ្វើឱ្យសិស្សរបស់ខ្លួនដឹងថា ខ្លួនពិតជាឱ្យតម្លៃការចូលរួម និងការរួមវិភាគទានរបស់ពួកគេ។ នៅពេលបង្រៀនមុខវិជ្ជា គ្រូបង្រៀនគ្រូ អាចបង្ហាញប្រធានបទក្នុងលក្ខណៈជំរុញនិងគួរឱ្យចាប់អារម្មណ៍ដល់អ្នកសិក្សា ដើម្បីលើកកម្ពស់ការសិក្សា។ កុមារដែលត្រូវបានរំញោចនៅក្នុងដំណើរការនៃការរៀន គឺមានថាមពលដើម្បីផ្លាស់ទីទៅមុខក្នុងសកម្មភាពដែលកុមារកំពុងរៀន។ Ngaroga (ឆ្នាំ2007) បានទទូចថា ការប្រែប្រួលរំញោច គឺជាសកម្មភាពរបស់គ្រូបង្រៀនដែលជួនកាលត្រូវបានគេគ្រោងទុក និងពេលខ្លះស្របពេលគ្នា spontaneous ដែលអភិវឌ្ឍនិងបង្កើនកម្រិតនៃការយកចិត្តទុកដាក់របស់សិស្សក្នុងអំឡុងពេលនៃមេរៀននេះ ក្នុងគោលបំណងរួមគឺដើម្បីឱ្យសិស្សយកចិត្តទុកដាក់លើមេរៀន។ វាជាតួនាទីរបស់គ្រូបង្រៀន ក្នុងការបង្កើតបរិយាកាសថ្នាក់រៀនល្អសម្រាប់សិស្សដើម្បីចូលរួមបានទាំងអស់គ្នាក្នុងដំណើរការបង្រៀន និងរៀន។ ការពង្រឹង គឺជាយុទ្ធសាស្ត្រលើកទឹកចិត្តមួយគ្រូបង្រៀនប្រើដើម្បីពង្រឹងទម្លាប់ ឬអាកប្បកិរិយារបស់អ្នករៀន។ ការប្រើភាសាកាយសម្បទាឧទាហរណ៍៖ ដូចជា ការងក់ក្បាល ញញឹម ទះដៃ ការអង្អែលខ្នង

កុមារ គឺជាវិធីពង្រឹងដែលគ្រូបង្រៀនបានប្រើនៅក្នុងថ្នាក់ ដើម្បីផ្តល់ការធានាសម្រាប់អ្នកសិក្សាដែលគាត់ពួកគេស្ថិតនៅលើគន្លងត្រឹមត្រូវ។ វិធីទាំងនេះ ក៏ជួយអភិវឌ្ឍទំនុកចិត្ត និងរូបភាពខ្លួនឯងជាវិជ្ជមានចំពោះកុមារ។ បរិយាកាសសាលារៀនមានសារៈសំខាន់ សម្រាប់ការអភិវឌ្ឍន៍ភាសាអង់គ្លេសរបស់កុមារឱ្យមានភាពស្ទាត់ជំនាញនៃភាសា។ បរិស្ថានបានផ្តល់ភាពគាំទ្រ និងជំរុញការអភិវឌ្ឍន៍ភាសារបស់អ្នកសិក្សា។

## ១.២ បញ្ហានៃការស្រាវជ្រាវ

ការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេស នៅសាលាបឋមសិក្សាចំណោះទូទៅមួយចំនួននៅមានបញ្ហាប្រឈមនូវឡើយ។ ដោយយោងទៅលើ Barasa [7](2005) បញ្ជាក់ថាអសមត្ថភាព ក្នុងការប្រើប្រាស់ភាសាអង់គ្លេសក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពនឹងនាំមកនូវផលវិបាកដល់ការរៀនសូត្ររបស់ពួកគេ ក៏ដូចជាសង្គមការងាររបស់ពួកគេផងដែរនៅថ្ងៃអនាគត។ ដូច្នេះហើយ កម្មវិធីសិក្សាភាសាអង់គ្លេសនៅសាលាបឋមសិក្សានៅប្រទេសកម្ពុជា បានដាក់ក្តីសង្ឃឹមយ៉ាងខ្ពស់ទៅលើការបង្រៀនភាសាអង់គ្លេសរបស់គ្រូប៉ុន្តែកន្លងមកនេះ ការរៀនភាសាអង់គ្លេសរបស់សិស្ស និងការបង្រៀនរបស់គ្រូពុំសូវទទួលបាននូវលទ្ធផលគួរជាទីពេញចិត្តនូវឡើយទេ បើទោះបីជា សិស្សមួយចំនួនបានសិក្សាភាសាអង់គ្លេសបន្ថែម នៅមជ្ឈមភាសាឯកជនក្រៅប្រព័ន្ធក៏ដោយ ក៏ពួកគេពុំអាចមានសមត្ថភាពសរសេរ អាន និងនិយាយភាសាអង់គ្លេសបានល្អនូវឡើយទេ ពោលគឺលទ្ធផលនៃការរៀនភាសាអង់គ្លេសរបស់សិស្សពុំទាន់បានពេញលេញនូវឡើយ។ ឧបសគ្គដ៏ចម្បង គឺការខ្វះខាតសមត្ថភាពនៃការបង្រៀនភាសាអង់គ្លេសរបស់គ្រូ។ គ្រូបង្រៀនភាសាអង់គ្លេសនៅតាមសាលារៀន មិនបានបណ្តុះបណ្តាលជំនាញឯកទេសនៃបង្រៀនសិក្សាភាសាអង់គ្លេស ជាហេតុនាំឱ្យភាគច្រើននៃគ្រូបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា មានជំនាញភាសាចំណេះដឹងតិចតួច ហើយពុំសូវមានវិធីសាស្ត្រច្រើននៅក្នុងការបង្រៀនភាសាអង់គ្លេសឱ្យសិស្សឆាប់ទទួលបាន។ តាមស្ថានភាពជាក់ស្តែង គ្រូដែលកំពុងភាសាបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សាមានបញ្ហាប្រឈមដូចតទៅ៖ ១) សាលាបឋមសិក្សាមួយចំនួនអនុវត្តការបង្រៀនភាសាអង់គ្លេសដោយមិនអនុលោមតាមសៀវភៅសិក្សាគោល ឬ

[7] Barasa, L.P (2005) *English Language Teaching in Kenya: Policy, Training and Practice:* Eldoret: Moi University.

តាមបំណែងចែកកម្មវិធីសិក្សាទេ។ ២)គ្រូភាសាអង់គ្លេស មិនទាន់បានយល់ច្បាស់អំពីការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្ស និងការដាក់ពិន្ទុនៅក្នុងការប្រឡងភាសាអង់គ្លេសប្រចាំខែ ប្រចាំឆមាសនិងប្រចាំឆ្នាំ។ ៣) មុខវិជ្ជាភាសាអង់គ្លេស នៅតាមសាលាបឋមសិក្សាមួយចំនួន ពុំបានរៀបចំកាលវិភាគឱ្យបានត្រឹមត្រូវតាមម៉ោងកំណត់ ២ ម៉ោងក្នុងមួយសប្តាហ៍ទេ ផ្ទុយទៅវិញ សាលារៀនខ្លះបង្រៀនតែថ្ងៃព្រហស្បតិ៍ ហើយប្រើរយៈពេលតែមួយម៉ោងប៉ុណ្ណោះ។ ៤) នៅតាមសាលាបឋមសិក្សាមួយចំនួននៅខ្វះខាតធានធានគ្រូដែលមានសមត្ថភាពខាងផ្នែកភាសាអង់គ្លេស និងចំណេះដឹងរបស់គ្រូបង្រៀនភាសាអង់គ្លេសនៅមានដែនកំណត់ ធ្វើឱ្យការបង្រៀននៅមានការខ្វះចន្លោះ និងមិនគ្រប់ជ្រុងជ្រោយ។ ៥ )គ្រូមិនបានបង្រៀនមេរៀននីមួយៗតាមកាលកំណត់នៃកម្មវិធីសិក្សា ៦)នៅតាមសាលាបឋមសិក្សាមួយចំនួន មិនមានសៀវភៅសិក្សាគោលគ្រប់គ្រាន់សម្រាប់ចែកជូនសិស្ស ឱ្យសិស្សខ្ចីសម្រាប់អាននៅម៉ោងសិក្សានៅក្នុងថ្នាក់រៀន និងនៅផ្ទះ។ ៧) គ្រូមិនមានសមត្ថភាពក្នុងការប្រើប្រាស់វិធីសាស្រ្តផ្សេងៗ មិនមានសម្ភារៈបង្រៀន និងមិនប្រើប្រាស់ល្បែងសិក្សាផ្សេងៗដែលគួរជាទីចាប់អារម្មណ៍ ដើម្បីបម្រើឱ្យការបង្រៀន និងរៀនរបស់សិស្ស។នៅក្នុងថ្នាក់រៀន។

តាមស្ថានភាពជាក់ស្តែង ការអនុវត្តន៍ជាក់ស្តែង ការបង្រៀននៅតាមសាលារៀនបឋមសិក្សាចំណេះទូទៅមួយចំនួននាពេលបច្ចុប្បន្ន ការអនុវត្តន៍ហាក់បីដូចជាមិនទាន់បានឆ្លើយតមទាំងស្រុងទៅនឹង សេចក្តីណែនាំស្តីពីការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា របស់ក្រសួងអប់រំ ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៧ ក្នុងគោលបំណងដើម្បីផ្តល់ឱកាសឱ្យសិស្សបានសិក្សាជាមូលដ្ឋានតំបូងនៃភាសាអង់គ្លេស សម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ ជាលទ្ធផល ទើបធ្វើឱ្យមានការសិក្សាស្រាវជាវលើប្រធាន៖ "ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា" ដើម្បីឆ្លើយតបទៅការចង់បានរបស់ក្រសួងអប់រំ យុជននិងកីឡា។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ៖

១) សិក្សាពីកត្តារួមចំណែកក្នុងការអនុវត្តន៍ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ទី៥ និងទី៦(English Grade 4,5 and 6)នៅសាលាបឋមសិក្សាប្រកបដោយប្រសិទ្ធភាព។

២)រកឱ្យឃើញពីវិធីសាស្ត្រដែលគ្រូដែលអនុវត្តក្នុងការបង្រៀនសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ (English Grade 4, 5 and 6 ) ។

## ១.៤ សំណួរស្រាវជ្រាវ

ការសិក្សានេះមានបំណងជួយឱ្យគ្រូបង្រៀនភាសាអង់គ្លេស នៅសាលាបឋមសិក្សាយល់ច្បាស់ពីកត្តាអនុវត្តសៀវភៅសិក្សាគោលភាសាអង់គ្លេស និងវិធីសាស្ត្រដែលគ្រូអនុវត្តនៅក្នុងសៀវភៅសិក្សាគោលនីមួយៗ ដើម្បីជួយការបង្រៀនសម្រេចបានតាមការកំណត់ទុកក្នុងមេរៀន។ដើម្បីសម្រេចបាននូវគោលបំណងខាងលើ ការសិក្សាស្រាវជ្រាវបានផ្តោតលើសំណួរស្រាវជ្រាវដូចខាងក្រោម ៖

១) តើគ្រូអនុវត្តនូវកត្តាអ្វីខ្លះ ដើម្បីប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ (English Grade 4, 5 and 6 ) ប្រកបដោយប្រសិទ្ធភាព ?

២) តើវិធីសាស្ត្រអ្វីខ្លះ ដែលគ្រូអនុវត្តនៅក្នុងការបង្រៀនសៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ (English Grade 4, 5 and 6 )?

## ១.៥ សារៈសំខាន់នៃស្រាវជ្រាវ

ការសិក្សានេះ បង្ហាញពីសារៈសំខាន់នៃការអនុវត្តន៍ការប្រើប្រាស់សៀវភៅសិក្សាគោលនៅក្នុងដំណើរការបង្រៀននិងរៀនភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន និងបង្ហាញពីសារៈប្រយោជន៍នៃវិធីសាស្ត្រក្នុងការអនុវត្តន៍ក្នុងសៀវភៅសិក្សាគោល ថ្នាក់ទី៤ទី៥និងទី៦ ។ ការសិក្សានេះសង្ឃឹមថានឹងនាំមកនូវការយល់ដឹងដ៏សំខាន់ទៅលើការងារ ការអនុវត្តន៍ការបង្រៀនប្រកបដោយប្រសិទ្ធភាពហើយជាលទ្ធផលនឹងបានជួយអភិវឌ្ឍ ការយល់ដឹងកាន់តែច្រើន ។ លើសពីនេះទៀត ការសិក្សាស្រាវជ្រាវស្វែងរកការបង្កើតជំនួយអ្វីៗដែលគ្រូត្រូវការ និងជាសូចនាករដើម្បីគាំទ្រការបង្រៀនរបស់គ្រូបង្រៀនភាសាអង់គ្លេស ដែលតម្រូវឱ្យមានការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព និងរួមបញ្ចូលវិធីសាស្ត្របង្រៀនផ្សេងៗគ្នាទាក់ទងក្នុងថ្នាក់រៀន។ អ្នកសិក្សាស្រាវជ្រាវ រំពឹងថា ពីការសិក្សានេះនឹងផ្តល់ព័ត៌មានអំពីទិដ្ឋភាពជាក់ស្តែងនៃការបង្រៀនអង់គ្លេស ប្រកបដោយគរុកោសល្យនៅក្នុងថ្នាក់រៀននៅសាលាបឋមសិក្សា។ ម្យ៉ាងទៀត សារៈសំខាន់នៃការសិក្សាជ្រាវនេះ បង្ហាញពីការបង្រៀន

ភាសាអង់គ្លេសដែលមានប្រសិទ្ធភាពក្នុងថ្នាក់។ ហើយអាចធ្វើឱ្យការប្រើប្រាស់សៀវភៅគោលកាន់តែមានប្រសិទ្ធភាពជាមួយគ្រូបង្រៀនរួមអាជីប និងរួមឯកទេស ដើម្បីអភិវឌ្ឍចំណេះដឹងនៃការអនុវត្តន៍របស់ខ្លួនកាន់តែមានសក្តានុពលឡើង ការរកឃើញអាចបង្ហាញពីតំរូវការសំម្រាប់ការគាំទ្រលើដំណោះស្រាយការសិក្សារបស់សិស្ស ដើម្បីឆាប់ចាប់បានមេរៀនទទួលបានជំនាញភាសាអង់គ្លេសតាមរយៈវិធីសាស្រ្តយ៉ាងសម្បូរបែបរបស់គ្រូ ឬបម្រើឱ្យការបង្រៀន និងរៀនអង់គ្លេសឱ្យកាន់តែរឹងមាំថែមទៀតនិងកាន់តែយល់ដឹងស៊ីជម្រៅពីឥទ្ធិពលនៃភាសាអង់គ្លេស។ លើសពីនេះទៅទៀត ការសិក្សានេះ នឹងមានអត្ថប្រយោជន៍និងរួមចំណែកធ្វើឱ្យប្រព័ន្ធអប់រំកម្ពុជាកាន់តែមានសក្តានុពលឡើង ហើយមួយចំណែកទៀត វាជាការរួមចំណែកដ៏សំខាន់មួយសម្រាប់គ្រូបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា ដើម្បីសិក្សាស្វែងយល់បន្ថែមក្នុងគន្លងអាជីបរបស់ខ្លួន។

## ១.៦ វិសាលភាព និងដែនកំណត់នៃស្រាវជ្រាវ

ដើម្បីឱ្យដំណើរនៃការសិក្សាស្រាវជ្រាវនេះប្រព្រឹត្តបាន អ្នកសិក្សាស្រាវជ្រាវ បានជ្រើសរើសយក ខេត្តតាកែវ ជាទីកន្លែងករណីសិក្សា។ ក្នុងការប្រមូលទិន្នន័យវិភាគ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយកស្រុកចំនួន២និងក្រុងចំនួន១ រួមមាន ក្រុងដូនកែវ ស្រុកត្រាំកក់ និងស្រុកសំរោង។អ្នកស្រាវជ្រាវបានជ្រើសរើសយកសាលាបឋមសិក្សាសរុបចំនួន០៩ចេញពីក្រុងចំនួន១និងស្រុកចំនួន០២។ ក្រុងដូនកែវ៖ សាលាបឋមសិក្សាតាកែវក្រុង សាលាបឋមសិក្សាអនុវត្ត សាលាបឋមសិក្សាក្រចាប់។ ស្រុកត្រាំកក់៖ សាលាបឋមសិក្សាអង្គរុន សាលាបឋមសិក្សាអង្គមន្ត្រី សាលាបឋមសិក្សាអង្គស្វែង។ស្រុកសំរោង៖ សាលាបឋមសិក្សាអង្គប្រិយ៍ សាលាបឋមសិក្សាខ្សាច់សរ សាលាបឋមសិក្សាទួលទ្រា។ ក្រុមគោលដៅដែលត្រូវបានជ្រើសរើសដើម្បីឆ្លើយនឹងកម្រងសំណួរស្រាវជ្រាវរួមមានលោកគ្រូ អ្នកគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ទី៥និងទី៦ សរុប២៤នាក់ និងសិស្សានុសិស្សរៀនថ្នាក់ទី៤ ទី៥ និងទី៦ សរុប១៧៨នាក់ និងគណៈគ្រប់គ្រងសរុបចំនួន០៩នាក់។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដំណើរការស្រាវជ្រាវនេះត្រូវបានបែងចែកជាប្រាំជំពូកធំៗ។

- **ជំពូកទី១: សេចក្តីផ្តើម**

បង្ហាញពី សាវតានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិសាលភាព និង

ដែនកំណត់ និង រចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- **ជំពូកទី២: រំលឹកទ្រឹស្តី**

អ្នកស្រាវជ្រាវនឹងលើកយករាល់ទ្រឹស្តីទាំងឡាយណា ដែលពាក់ព័ន្ធនឹងចំណោទបញ្ហាស្រាវជ្រាវ ព្រមទាំងលើកយកសេចក្តីពន្យល់បន្ថែមរបស់អ្នកស្រាវជ្រាវទៅលើទ្រឹស្តីទាំងអស់នោះ ដើម្បីឱ្យកាន់តែច្បាស់លាស់ និងស៊ីជំរៅដោយមានឯកសារពិគ្រោះច្បាស់លាស់ត្រឹមត្រូវ។

- **ជំពូកទី៣: វិធីសាស្ត្រស្រាវជ្រាវ**

អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីវិធីសាស្ត្រស្រាវជ្រាវ និងគម្រោងស្រាវជ្រាវ ដែលបញ្ជាក់ពីអត្ថប្រយោជន៍នៃប្រធានបទ និងបង្ហាញពីទំនាក់ទំនងរវាងចំណុចនីមួយៗដែលបានចោទនៅក្នុងចំណោទបញ្ហាទៅជាមួយនិងប្រធានបទ។

- **ជំពូកទី៤: លទ្ធផលស្រាវជ្រាវ និងការវិភាគ**

អ្នកស្រាវជ្រាវលើកពីលក្ខណៈជាក់ស្តែងដែលបានធ្វើការស្រាវជ្រាវ និងវិភាគទៅលើចំណុចទាំងអស់ដែលបានអនុវត្តជាក់ស្តែងដើម្បីរកឱ្យឃើញថាតើវាដូចគ្នាទៅនឹងទ្រឹស្តីឬទេ គឺក្នុងគោលបំណងវិភាគរកឱ្យឃើញចំណុចខ្វះខាតដើម្បីកែលម្អបន្ថែមទៀត។

- **ជំពូកទី៥: សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

អ្នកស្រាវជ្រាវធ្វើការសន្និដ្ឋានលើគ្រប់ចំណុចទាំងអស់ដែលបានវិភាគ និងផ្តល់យោបល់ទៅលើចំណុចដែលត្រូវកែលម្អ និងចំណុចខ្វះខាតនានា។

## ១.៨ កាលបរិច្ឆេទនៃការស្រាវជ្រាវ

| ល.រ | ខ្លឹមសារ | កាលបរិច្ឆេទធ្វើបទបង្ហាញ |
|---|---|---|
| ១ | គម្រោងស្រាវជ្រាវ | ០១ មិថុនា ២០១៩ |
| ២ | បង្កើតឧបករណ៍ស្រាវជ្រាវ | ០៨ មិថុនា ២០១៩ |
| ៣ | ប្រមូលទិន្នន័យ | ១០ មិថុនាដល់ ៣១កក្កដា ២០១៩ |
| ៤ | សេចក្តីផ្តើម | ១០ សីហា ២០១៩ |
| ៥ | រំលឹកទ្រឹស្តី | ៣១ សីហា ២០១៩ |

| | | |
|---|---|---|
| ៦ | វិធីសាស្ត្រស្រាវជ្រាវ | ១៥ កញ្ញា ២០១៩ |
| ៧ | លទ្ធផលស្រាវជ្រាវ និងការពិភាក្សា | ០៥ តុលា ២០១៩ |
| ៨ | ការពារនិក្ខេបបទសាកល្បង | ១៩ តុលា ២០១៩ |
| ៩ | ការពារនិក្ខេបបទបញ្ចប់ការសិក្សា | ២៦ តុលា ២០១៩ |
| ១០ | ប្រគល់និក្ខេបបទបញ្ចប់ការសិក្សា | ៣០ វិច្ឆិកា ២០១៩ |

# ជំពូកទី២

# ការរំលឹកទ្រឹស្តី

# ជំពូកទី២៖ ការរំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ អ្នកស្រាវជ្រាវបានពិភាក្សាពីឥទ្ធិពលនៃការអប់រំភាសាអង់គ្លេសក្នុងប្រទេសកម្ពុជា គោលបំណងរួមមាន កម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់កម្រិតបឋមសិក្សាថ្នាក់ទី៤ ថ្នាក់ទី៥ និងថ្នាក់ទី៦ បរិបទកម្មវិធីសិក្សាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា លទ្ធផលសិក្សារំពឹងទុកតាមកម្រិតថ្នាក់នីមួយៗ ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ដល់ថ្នាក់ទី៦ ការអនុវត្តន៍ការប្រើប្រាស់ម៉ោងសិក្សា របៀបទូទៅនៃការរៀនភាសារបស់កុមារដើម្បីទទួលបានជំនាញភាសាអង់គ្លេស សមត្ថភាពចំណេះដឹងនិងជំនាញរបស់គ្រូនៅក្នុងការបង្រៀនភាសាអង់គ្លេស វិធីសាស្រ្តបង្រៀន និងរៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា ការប្រើប្រាស់សម្ភារៈបង្រៀននិងរៀនក្នុងការបង្រៀនជំនាញភាសាអង់គ្លេសនៅសាលាបឋមសិក្សា និងការវាយតម្លៃលទ្ធផលនៃការសិក្សារបស់សិស្សពីសំណាក់គ្រូភាសាអង់គ្លេសដែលកំពុងតែបង្រៀននៅសាលាបឋមសិក្សា។

## ២.១ ឥទ្ធិពលនៃការអប់រំភាសាអង់គ្លេសក្នុងប្រទេសកម្ពុជា

(Kirkpatric,2007). Richards (2003) លើកឡើងថា ភាសាអង់គ្លេសគឺជាភាសាយានរបស់ពិភពលោក។ ភាសាអង់គ្លេសត្រូវបានប្រើប្រាស់ជាមធ្យោបាយក្នុងការប្រាស្រ័យទំនាក់ទំនងរបស់មនុស្សទូទៅដែលមិនមានភាសាកំណើតរួមគ្នា។ ភាសាអង់គ្លេសគឺជាភាសាសាកលលោក ទំនាក់ទំនងអន្តរជាតិ ពាណិជ្ជកម្ម សេដ្ឋកិច្ច ប្រព័ន្ធផ្សព្វផ្សាយ និងវប្បធម៌ទំនើប។ ទោះបីភាសានេះ ត្រូវបានលើកឡើងក្នុងមធ្យោបាយផ្សេងៗគ្នាក៏ដោយ តែភាសានេះត្រូវបានគេកំណត់យកពាក្យរួមមួយគឺ អង់គ្លេសជាភាសាយាន ( English as a Lingua Franca )(ELF)។ បន្ទាប់មកទៀត Seidlhofer′s (2005) បានកំណត់ន័យថ្មីមួយទៀតទៅលើអត្ថន័យនៃអង់គ្លេសជាភាសាយាន( English as a Lingua Franca )ថាជាមធ្យោបាយសំដៅលើការទំនាក់ទំនងជាភាសាអង់គ្លេសរវាងអ្នកនិយាយដែលមិនមានភាសាកំណើតរួមគ្នាតែមួយ ដោយមើលឃើញការពិតថា អន្តរទំនាក់ទំនងនៃភាសាអង់គ្លេសជាភាសាយានស្ទើរតែកើតមាន ក្នុងចំណោមអ្នកនិយាយភាសាអង់គ្លេសដែលមិនមែនជាភាសាដើម។ Kachru (1985) បរិយាយថា ភាសាអង់គ្លេសជាភាសាពិភពលោក ក្នុងន័យនៃរង្វង់ចំនួនបី Three Circles) ។រង្វង់ខាងក្នុង(the Inner Circle) គឺសំដៅលើប្រទេសដែលភាសាអង់គ្លេសគឺ

ជាភាសាកំណើត ដូចជា ប្រទេសអង់គ្លេស សហរដ្ឋអាមេរិច អូស្រ្តាលី ជាដើម។ បន្ទាប់មក រង្វង់ក្រៅបន្ទាប់ ( the Outer Circle) សំដៅលើប្រទេសដែលប្រើប្រាស់ភាសាអង់គ្លេសជាភាសាផ្លូវការយ៉ាងទូលំទូលាយ ឬភាសាទីពីរ រួមមាន ប្រទេសឥណ្ឌា ប្រទេសនេស៊ីរីយ៉ា និងប្រទេសសិង្ហបុរី។ ចុងក្រោយនោះគឺ រង្វង់ពង្រីក ( the Expanding Circle) សំដៅទៅលើប្រទេសដែលរៀន ឬប្រើប្រាស់ភាសាអង់គ្លេសជាភាសាបរទេស។ប្រទេសកម្ពុជាជាផ្នែកនៃក្រុមដែលត្រូវបានគេចាត់ទុកក្រុមពង្រីក( the Expanding Circle) ដោយហេតុថា ភាសានេះ មិនត្រូវបាននិយាយជាភាសាជាតិ ឬភាសាផ្លូវការនៅឡើយទេ។ ជាធម្មតា នេះបានឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍នៃប្រវត្តិសាស្រ្តរបស់ប្រទេសកម្ពុជា( 1863-1953) និងប្រទេសមួយចំនួនទៀត ដូចជា ប្រទេសឡាវ និងប្រទេសវៀតណាម ដែលត្រូវបានស្ថិតនៅក្រោមអាណានិគមនៃប្រទេសបារាំង។ Vira (2002)ចាប់តាំងពីការទទួលឯករាជ្យនៅក្នុងឆ្នាំ ១៩៥៣ មានការប្រែប្រួល គួរឱ្យកត់សំគាល់ក្នុងជម្រើសនៃភាសាបរទេសដែលត្រូវបានយកមកបង្រៀននៅតាមសាលាអនុវិទ្យាល័យក្នុងប្រទេសកម្ពុជា។ ក្នុងទសវត្សឆ្នាំ ១៩៧០ ប្រទេសកម្ពុជាបានស្ថិតនៅក្រោមរបបគ្រប់គ្រងផ្តាច់ការរបស់ប៉ុលពត នៅពេលនោះដែរ មន្ត្រីរាជការ និងបញ្ញវ័ន្តខ្មែររាប់ពាន់នាក់ត្រូវបានគេសំលាប់ ហើយទីបំផុត ការអប់រំដែលត្រូវបានផ្តល់នៅតាមសាលារៀនគឺត្រូវបានផ្អាកឈប់ដំណើរការទាំងស្រុង។ ការអប់រំភាសាអង់គ្លេសគឺត្រូវបានចាប់ផ្តើមដំណើរការឡើងវិញត្រឹមឆ្នាំ ១៩៨៩។ Vira (2002) គឺជាភាសាវិទូវិទ្យាជនជាតិខ្មែរ( a Cambodian Applied Linguist) បានលើកឡើងពីការផ្លាស់ប្តូរសំខាន់ៗនៅក្នុងជម្រើសនៃភាសាបរទេសនៅក្នុងប្រទេសកម្ពុជាទាំងមូល។

តារាងទី១៖.បម្រែបម្រួលនៃការអប់រំភាសាបរទេសក្នុងប្រទេសកម្ពុជា ( Vira,2002)

| សម័យកាល ឬរបប | កំឡុងឆ្នាំ | ការអប់រំភាសាបរទេស |
|---|---|---|
| ១. ព្រះបាទនរោត្តននរោត្តមសីហានុជាប្រមុខរដ្ឋាភិបាល | ១៩៥៣-១៩៧០ | ភាសាបារាំងតែមួយប៉ុណ្ណោះ។ វាគឺជាភាសាផ្លូវការតែមួយមុខគត់ ត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីសិក្សាសាលារៀន។ វា |

| | | |
|---|---|---|
| | | ត្រូវបានប្រើគ្រប់វិស័យទាំងអស់ នៅក្នុងប្រទេសកម្ពុជាក្នុងពេលនោះ។ |
| ២.សាធារណៈរដ្ឋ លន់ ណល់ | ១៩៧០-១៩៧៥ | ភាសាបារាំង និងអង់គ្លេស៖ ដោយហេតុថា មានការពាក់ព័ន្ធជាមួយអាមេរិចកាំង ( នយោបាយនិងយោធាក្នុងសង្គ្រាមឥណ្ឌូចិន។ការរៀនភាសាអង់គ្លេសត្រូវបានគេលើកទឹកចិត្ត។ |
| ៣.កម្ពុជាប្រជាធិបតេយ្យ របស់ប៉ុល ពត | ១៩៧៦-១៩៧៩ | គ្មានភាសាបរទេស។ គ្មានការអប់រំ (ការរៀនការប្រើភាសាបរទេស ត្រូវបានហាមឃាត់ដាច់ខាត។ |
| ៤. ប្រធានសម្ដេច ហេង សំរិន និងសម័យកាលគោលនយោបាយអន្តរជាតិ | ១៩៧៩-១៩៨៦ | ភាសាវៀតណាម និងភាសារុស៊ី៖ភាសាទាំងពីរនេះ ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សាជាផ្លូវការ។ ភាសាបារាំង និងអង់គ្លេស ត្រូវបានហាមឃាត់ដាច់ខាតក្នុងករណី ឃើញរៀនភាសាទាំងនេះនឹងត្រូវដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ និងថែមទាំងត្រូវគេចាប់ដាក់ពន្ធនាគារ។ |
| | ១៩៨៩ - | ភាសាអង់គ្លេស និង ភាសាបារាំង |
| ៥.ការបោះឆ្នោត១៩៩៣ និងឆ្នាំជាបន្តបន្ទាប់មក | ១៩៩៣ | ភាសាអង់គ្លេស និង ភាសាបារាំង |

ប្រទេសកម្ពុជាសម័យបច្ចុប្បន្ន ភាសាអង់គ្លេសគឺជាភាសាដែលគេនិយមប្រើបំផុត។ វាគឺជាភាសាដែលគេប្រើបាស់នៅក្នុងធុរៈកិច្ចអន្តរជាតិ និងក្នុងវិស័យអប់រំ។ Clayton (2007) ចង្អុល

បង្ហាញថា មានព្រឹត្តិការណ៍នយោបាយចំនួនពីរ ដែលជាហេតុនៃការដាក់ចេញ និងបាន ជំរុញឱ្យមានការប្រើប្រាស់ភាសាអង់គ្លេសយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា៖

(១) សម័យកាលនៃអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា (១៩៩២-១៩៩៣) (The era of the United Nations Transitional Authority in Cambodia (UNTAC) (1992-1993)។ Yasushi Akashi បានដឹកនាំកងកម្លាំងអន្តរជាតិចំនួនពីរម៉ឺននាក់ ( ២០,០០០នាក់) មកកាន់ប្រទេសកម្ពុជាជាមួយក្រុមអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅប្រទេសកម្ពុជា។ បើទោះបីជា អង្គការសហប្រជាជាតិបង្កើតឡើងតម្រូវឱ្យប្រើភាសាបារាំង និងអង់គ្លេសក៏ដោយ តែភាសាអង់គ្លេសមានសក្តានុពលជាងគេបំផុតបើប្រៀបធៀបទៅភាសាបារាំង។ Clayton (2007) សង្កេតឃើញថា ជនជាតិកម្ពុជាសរុបច្រើនជាង ៦០០០នាក់ បានបម្រើការងារឱ្យអង្គការសហប្រជាជាតិ ក្នុងកំឡុងពេល បេសកម្មរយៈពេល ២ឆ្នាំ។ ហើយភាគច្រើនបំផុត ត្រូវការសញ្ញាបត្រជំនាញផ្នែកភាសាអង់គ្លេសដើម្បីបំពេញការងារ។ នេះគឺបង្ហាញពីសញ្ញានៃការគ្របដណ្តប់នៃភាសាអង់គ្លេសនៅក្នុងប្រទេសកម្ពុជា។

(២) ប្រទេសកម្ពុជាបានចូលជាសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ហៅកាត់ថា អាស៊ាន (១៩៩៩)( Cambodia's admission into the Association of Southeast Asian Nations (ASEAN) (1999)។ អាស៊ាន គឺជាអង្គការដែលមានអំណាចមួយដែលមានប្រទេសសមាជិកនៅក្នុងអាស៊ីអាគ្នេយ៍ ខុសគ្នាទៅនិងអង្គការអន្តរជាតិផ្សេងៗទៀត ដែលមានជំហរភាសាច្រើន។ ភាសាផ្លូវការរបស់រអាស៊ានតែមួយគត់គឺភាសាអង់គ្លេស។ហេតុដូច្នោះហើយ វាគឺជាកត្តាជំរុញដ៏ខ្លាំងសម្រាប់ប្រទេសកម្ពុជាដើម្បីអភិវឌ្ឍបុគ្គលិកលក្ខណៈនិយាយភាសាអង់គ្លេស។ Clayton (2007) បានលើកឡើងថា គោលនយោបាយភាសារបស់អាស៊ានបានដាក់ចេញក្នុងឆ្នាំ២០០០ បានដាក់សម្ពាធយ៉ាងខ្លាំងមកលើមន្ត្រីតំណាងក្រសួង អ្នកតំណាងប្រចាំប្រទេស គណៈប្រតិភូ ត្រូវតែចេះភាសាអង់គ្លេស។ ភាសាតម្រូវឱ្យពីសំណាក់អាស៊ានគឺមិនត្រឹមតែកំណត់ចំពោះវិទ្យាសាស្ត្រនយោបាយទេ សូម្បីតែវិស័យសេដ្ឋកិច្ច ជនជាតិកម្ពុជាត្រូវតែទំនាក់ទំនងជាអន្តរជាតិ គឺភាសាអង់គ្លេសជាជាងភាសាបារាំង។

ក្រសួងអប់រំ យុវជននិងកីឡា (Moeys) បានដឹងថាប្រជាជនគ្រប់ស្រទាប់វណ្ណៈ មានឆន្ទៈក្នុងការរៀនភាសាអង់គ្លេស ហើយមិនត្រូវបានធ្វើការពន្យាពេលណាមួយឡើយ។ ប៉ុន្តែការសិក្សាត្រូវបានចាប់ផ្តើមពីមូលដ្ឋានធនធានទាបបំផុត ដោយគ្មានកម្មវិធីសិក្សា គ្មានសៀវភៅសិក្សាគោលច្បាស់លាស់ ហើយគ្រូដែលមានសមត្ថភាពបង្រៀនភាសាអង់គ្លេសមានតិចតួច ( Pith,1996) ក្រសួងអប់រំបានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សាសាលាមធ្យមសិក្សារដ្ឋតាំងពីឆ្នាំ១៩៨៩ ( Vira, 2002)។ សព្វថ្ងៃ ភាសាអង់គ្លេសត្រូវបានប្រើប្រាស់សម្រាប់ការបង្រៀនជាភាសាបរទេសរយៈពេល ៣ឆ្នាំ នៅកម្រិតអនុវិទ្យាល័យ និង ៣ឆ្នាំទៀតនៅកម្រិតវិទ្យាល័យ។សិស្សទាំងអស់ត្រូវបានបង្រៀនភាសាអង់គ្លេសជាផ្លូវការរយៈពេល ៦ឆ្នាំមុនពេលពួកគេនឹងបានបញ្ចប់មធ្យមសិក្សាចំណោះទូទៅ។ សិស្សដែលមានកម្រិតជំនាញភាសាអង់គ្លេសកម្រិតខ្ពស់ពីវិទ្យាល័យមក ពួកគេមានឱកាសទទួលបាននូវភាពជោគជ័យជាងសិស្សឯទៀតនៅកម្រិតសាកលវិទ្យាល័យ។( Nith,2004)ដោយមើលឃើញនូវសារៈសំខាន់នៃមុខវិជ្ជាភាសាអង់គ្លេស រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បណ្ឌិត ហង់ ជួន ណារ៉ុន បានចុះហត្ថលេខាក្នុងស្មារតីទទួលខុសត្រូវខ្ពស់ លើសេចក្តីណែនាំស្តីពីការបង្រៀននិងរៀនមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សា ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៤ ដោយក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសនៅក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណោះទូទៅចាប់ពីថ្នាក់ទី៤ដល់ទីថ្នាក់ទី៦ ដើម្បីផ្តល់ឱកាស ឱ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសសម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។

## ២.២ គោលបំណងកម្មវិធីសិក្សាមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា

កម្មវិធីសិក្សាភាសាអង់គ្លេសសម្រាប់កម្រិតបឋមសិក្សាចំណោះដឹងទូទៅ មានគោលបំណងរួមចង់ឱ្យសិស្សានុសិស្សនៃប្រទេសកម្ពុជា ទទួលបាននូវបំណិន ក្នុងការប្រាស្រ័យទំនាក់ទនងជាភាសាអង់គ្លេសជាអន្តរជាតិក្នុងវិស័យផ្សេងៗដូចជា វប្បធម៌ វិទ្យាសាស្ត្រ បច្ចេកទេស ពាណិជ្ជកម្ម ឧស្សាហកម្ម និងទំនាក់ទំនងការទូតជាដើម ឬជាមូលដ្ឋានសម្រាប់សិស្សានុសិស្សបន្តការសិក្សានៅកម្រិតមធ្យមសិក្សា ឧត្តមសិក្សា បណ្តុះបណ្តាលមុខវិជ្ជាជីវៈ ជំនាញ ឬការចូលរួមក្នុងជីវភាពសង្គម។ មុខវិជ្ជាភាសាអង់គ្លេសគឺជាមុខវិជ្ជាមួយ

ដែលមានសារៈសំខាន់ដូចមុខវិជ្ជាផ្សេងៗដែរ ដែលរួមចំណែកក្នុងការបណ្តុះបណ្តាលសិស្សឱ្យមានទំនួលខុសត្រូវ មានមនសិការស្នេហាជាតិ ស្គាល់ពីសិទ្ធិ កាតព្វកិច្ច និងមានទំនាក់ទំនងជាមួយពិភពវប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេសទំនើប ដើម្បីរួមចំណែកឱ្យកាន់តែសកម្មបន្ថែមទៀតក្នុងការរួមអភិវឌ្ឍប្រទេសជាតិ។

ក្រសួងអប់រំ យុវជន និងកីឡា មានការជឿទុកចិត្តថា កម្មវិធីសិក្សាភាសាអង់គ្លេសដែលបានដាក់បញ្ចូលនៅកម្រិតបឋមសិក្សាចំណោះទូទៅនេះ បាននឹងកំពុងបម្រើឱ្យការកសាងធនធានមនុស្សនៅប្រទេសកម្ពុជាប្រកបដោយគុណភាព និងប្រសិទ្ធភាពដែលឆ្លើយតបទៅនឹងគោលនយោបាយអប់រំ និងគោលដៅអប់រំជាតិ[8]។

## ២.៣ កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់កម្រិតបឋមសិក្សាថ្នាក់ទី៤ -៥ និងទី៦

កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសដែលក្រសួងអប់រំ យុវជន និងកីឡា បានដាក់បញ្ចូលនៅក្នុងកម្មវិធីសិក្សានៅ បឋមសិក្សា ថ្នាក់ទី៤ ទី៥ និងទី៦ និងលើកទឹកចិត្តឱ្យសាលាបឋមសិក្សាចំណោះទូទៅទាំងអស់ផ្តល់ការបង្រៀនភាសាអង់គ្លេសដល់សិស្សានុសិស្ស ដោយផ្អែកលើការប្រើប្រាស់ធនធានងាយៗអាចរកបាននៅតាមមូលដ្ឋានរស់នៅ និងនៅតាមសាលារៀនដោយមិនចាំបាច់ពឹងផ្អែកទាំងស្រុងលើធនធានរបស់ក្រសួងអប់រំទេ។ ដើម្បីជួយសម្រួលដល់ការបង្រៀន ក្រសួងបានសហការជាមួយនាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សាបានកសាងនូវឯកសារជំនួយនានាសម្រាប់ការប្រើប្រាស់របស់គ្រូ ទទួលការរ៉ាប់រងដោយគម្រោងលើកម្ពស់គុណភាពអប់រំ (Enhancing Education Quality Project) ដែលស្ថិតក្រោមការឧបត្ថម្ភជំនួយរបស់ធនាគារអភិវឌ្ឍអាស៊ី ( Asian Development Bank) និង រួមសហការជាមួយអង្គការអ្នកស្ម័គ្រចិត្តបម្រើការនៅបរទេស (Volunteers Service Overseas) ភ្នាក់ងារភីស ខ័ស កម្ពុជា (Peace Corps: Cambodia) និង British Council ។

---

[8] ក្រសួងអប់រំ យុវជន និងកីឡា (២០១២): កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាកទី៤ ទី៥ និងទី៦ -បុព្វកថា

កម្មវិធីសិក្សានេះ បានរៀបចំសម្រាប់សាលាបឋមសិក្សាចំណេះទូទៅចាប់ពីកម្រិតថ្នាក់ទី៤ ដល់ទីថ្នាក់ទី៦ ដោយផ្តើមចេញពីសញ្ញាណតំបូងនៃភាសាអង់គ្លេសដែលជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងសមត្ថភាពលើការស្តាប់ ការអាន ការនិយាយ និងការសរសេរ។

ក្នុងកម្មវិធីនេះ មានបង្ហាញពីគោលបំណង លទ្ធផលសិក្សា ខ្លឹមសារ និងប្រធានបទសំខាន់ៗទៅតាមកម្រិតថ្នាក់នីមួយៗ ដូចជា ស្រៈ ព្យញ្ជនៈ ពាក្យ ល្បះងាយៗ និងអត្ថបទខ្លីៗក្នុងបរិបទគ្រួសារ សាលារៀន និងសហគមន៍ ពីតម្រូវការជាក់ស្តែងរបស់សិស្សានុសិស្ស។

ទន្ទឹមនឹងនេះដែរ គណៈកម្មការកម្មវិធីសិក្សា សង្ឃឹមថា កម្មវិធីសិក្សានេះ អាចប្រើប្រាស់សម្រាប់អភិវឌ្ឍសមត្ថភាពសិស្សនៅកម្រិតបឋមសិក្សាចំណេះទូទៅឱ្យមានសញ្ញាណតំបូងនៃការសិក្សាភាសាអង់គ្លេសដែលជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងសមត្ថភាពផ្នែកភាសាអង់គ្លេសបន្ត ទៅមធ្យមសិក្សា និងក្លាយទៅជាពលរដ្ឋពេញលេង និងមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សង្គម និងប្រទេសជាតិ[9]។

## ២.៣.១ លទ្ធផលសិក្សារំពឹងទុកនៃការបង្រៀនជំនាញទាំងបួននៅកម្រិតបឋមសិក្សា ថ្នាក់ទី៤ - ៥ និង ទី៦

### ២.៣.១.១ ជំនាញស្តាប់ និងជំនាញនិយាយ

ស្តង់ដានៃការស្តាប់ និងការនិយាយសម្រាប់ភាសាអង់គ្លេស បញ្ជាក់ពីសមត្ថភាពរបស់សិស្សយល់ច្បាស់ពីភាសាអង់គ្លេស ហើយនឹងអាចប្រើប្រាស់ភាសាតាមរយៈការនិយាយផ្ទាល់មាត់។ សិស្សប្រាកដជាក់ក្នុងការត្រៀមខ្លួនប្រើប្រាស់ភាសាអង់គ្លេសយ៉ាងមានប្រសិទ្ធភាព និងក្នុងបរិបទសិក្សា និងបរិបទសង្គម។ ជំនាញស្តាប់ និងជំនាញនិយាយផ្តល់នូវការបញ្ចូលគ្នាយ៉ាងសំខាន់បំផុតសម្រាប់មូលដ្ឋានគ្រឹះនៃការចាប់យកចំណេះដឹង ឬរៀនភាសាអង់គ្លេស នឹងជាផ្នែកដ៏សំខាន់សម្រាប់អភិវឌ្ឍជំនាញពីរបន្ថែមទៀត គឺជំនាញអាន និងជំនាញសរសេរភាសាអង់គ្លេស។ ដើម្បីអភិវឌ្ឍជំនាញ ស្តាប់ និយាយ អាន និងសរ

[9] ក្រសួងអប់រំ យុវជន និងកីឡា (២០១២): កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាកទី៤ ទី៥ និងទី៦ អារម្ភកថា

សេរ សិស្សទាំងអស់នៅកម្រិតបឋមសិក្សាត្រូវតែទទួលបានការបង្រៀននូវធាតុទាំងបួន។ ធាតុទាំងបួននេះរួមចំណែកក្នុងការបំពេញឱ្យគ្នាទៅវិញទៅមក[10]។ តាមរយៈការសិក្សាស្រាវជ្រាវរបស់ Davide Capperucci ជំនាញស្តាប់ គឺជាជំនាញភាសាតំបូងគេ ដែលសិស្សយល់ឃើញថាពិបាក។ បញ្ហានេះកើតឡើងជាញឹកញាប់ពិសេសនៅពេលដែលពួកគេគិតថាពួកគេត្រូវតែយល់គ្រប់ៗពាក្យដែលពួកគេបានស្តាប់ឮ។ ធាតុពិតគឺមិនដូច្នេះទេ សូម្បីតែភាសាកំណើតក៏មិនចាំបាច់ធ្វើដូច្នេះដែរ។ កិច្ចការងារត្រៀមទៅលើការងារស្តាប់គឺត្រូវបង្កើតឡើងដោយគ្រូ។ វាគឺមានសារៈសំខាន់ណាស់ដូច្នេះហើយ វាគឺត្រឹមត្រូវណាស់សម្រាប់គ្រូជាអ្នកកំណត់កម្រិតនៃការលំបាកនៃអត្ថបទស្តាប់។ មួយផ្នែកធំ អត្ថបទស្តាប់ប្រាកដជាមានពាក្យ រចនាសម្ព័ន្ធភាសាដែលសិស្សបានចេះរួចហើយ។ ក្រោយមក វាមានសារៈសំខាន់ណាស់សម្រាប់បង្ហាញប្រាប់បរិបទត្រួសៗទៅនិងអត្ថបទស្តាប់។ ទោះជាយ៉ាងណា ការពន្យល់ត្រូវតែជិតស្និតទៅនឹងបរិបទដែលសិស្សធ្លាប់មានបទពិសោធន៍ ឬអ្វីៗដែលពួកគេដឹង។ ភាពផ្សេងគ្នានៃស្ថានភាព ពិតមែន តែសិស្សអាចធ្លាប់បានឮ ថែមទាំងបានឃើញ ស្គាល់ទីកន្លែងច្បាស់ ទាក់ទងគ្នាទៅនិងចំណេះដឹងមានស្រាប់របស់សិស្ស ។ រាល់ការពន្យល់បរិបទ គឺផ្តោតតែសំខាន់លើអ្វីៗដែលមានក្នុងអត្ថបទស្តាប់។គ្រូសួរសំណួរសិស្សមួយចំនួនសិនស្របពេលជាមួយគ្នានេះដែរ គ្រូត្រួតពិនិត្យចម្លើយរបស់សិស្សព្រមទាំងកម្រិតនៃការយល់ដឹងដែលពួកគេចង្អុលបង្ហាញតាមរយៈការងាររបស់ខ្លួន។ សំណួររបស់គ្រូ ជួយឱ្យនឹកឃើញឡើងវិញនូវពាក្យស័ព្ទមួយចំនួន ដើម្បីយល់អត្ថន័យទូទៅនៃសកម្មភាពអត្ថបទស្តាប់[11]។ ដូចដែលបានបង្ហាញតាមរយៈការសិក្សាជាច្រើន[12] ជំនាញនិយាយគឺជាសមត្ថភាពបង្កើតឡើងតាមរយៈការនិយាយដែលជាប់ពាក់ព័ន្ធគ្នាយ៉ាងជិតស្និត ទៅនឹងសមត្ថភាពនៃការស្តាប់របស់សិស្ស ហើយនឹងសមត្ថភាពយល់ដឹង ដើម្បីឈានទៅរកទំនាក់ទំនងផ្ទាល់មាត់។នៅពេលពេលដែលគ្រូនិយាយភាសាអង់គ្លេសជាធម្មតា ប្រើប្រាស់ទំរង់ពាក្យ ឃ្លា ប្រយោគដែលសិស្សមិនទាន់បានចេះនៅឡើយទេ ដើម្បីពង្រឹងការនិយាយ វាគឺសំខាន់ណាស់

[10] English Language Curriculum for Cambodian Primary Schools Grades 4,5, and6 page 2-3
[11] R,ELLis, Task-based Language Teaching: sorting out the misunderstandings, in “ International Journal of Applied Linguistics”,19(3),2009,pp.226-249.
[12] K.M.Baily , Practical English Language Teaching: Speaking, New York, McGraw-Hill,2007; E. Grugeon, L .Hubbard, C. Smith: Teaching Listening and Speaking in Primary Schools.

សម្រាប់គ្រូត្រូវតែចងចាំថា សមត្ថភាពចំណេះដឹងរបស់សិស្សគឺស្ថិតនៅក្នុងបរិបទរបស់ខ្លួនគេឬទេ។ ហើយសុំស្នើជាបន្តបន្ទាប់រាល់សកម្មភាពនិយាយអាចធ្វើឡើងតាមរយៈការកំណត់វាក្យស័ព្ទ។ ដើម្បីជំនួយដល់ការឆាប់យល់របស់សិស្សគ្រូគួរតែប្រើប្រាស់ផ្ទាំងរូបភាព ផ្ទាំងគំនូរ បណ្ណពាក្យជាដើមនៅក្នុងបរិបទសកម្មភាពនិយាយ។ ការអភិវឌ្ឍសមត្ថភាពនិយាយ គឺជាញឹកញាប់គ្រូអនុញ្ញាតឱ្យសិស្សនិយាយបង្ហាញពីអ្វីៗតាមរយៈការប្រើប្រាស់ឃ្លា ប្រយោគ ដែលគេចេះដោយផ្ទាល់ ដោយមិនបារម្ភអំពីកំហុស តែគ្រូមានឱកាសក្នុងការកត់ត្រា រាល់ការបញ្ចេញសំលេង កំហុសនានា សម្រាប់ជាព័ត៌មានត្រឡប់បន្ទាប់ពីសកម្មភាពនិយាយបានបញ្ចប់ ព្រោះការកែតម្រូវស្របពេលនិយាយ វាអាចរាំងស្ទះសមត្ថភាពនិយាយរបស់សិស្ស។ សម្រាប់ហេតុផលមួយ សកម្មភាពនិយាយ គឺគួរតែស្ថិតនៅក្នុងជីវភាពជាក់ស្តែងរបស់សិស្សឱ្យបានកាន់តែច្រើន ដែលជាឱកាសពួកគេអាចទំនាក់ទំនងគ្នាតាមរយៈ សួរ និងឆ្លើយជាមួយគ្នាទៅវិញទៅមក។

### ២.៣.១.២ ជំនាញអាន

សម្រាប់សិស្សទាំងអស់ ការអភិវឌ្ឍន៍នៃជំនាញអានភាសាអង់គ្លេសផ្តើមចេញពីការយល់ដឹងដ៏រឹងមាំនៃទំនាក់ទំនងគ្នារវាងសូរសំលេងជាភាសាអង់គ្លេស និងស្គាល់ច្បាស់នូវឈ្មោះតួអក្សរនីមួយៗរវាងទំនាក់ទំនងភាសានិយាយ និងភាសាសរសេរ ។សម្រាប់អ្នករៀនភាសាអង់គ្លេស បញ្ញត្តិទាំងនេះ គឺត្រូវបានអភិវឌ្ឍមុនដំបូងគេ តាមរយៈការស្គាល់ និងការបញ្ចេញសូរសំឡេងភាសាអង់គ្លេស។ សិស្សចាំបាច់ត្រូវតែរៀននិងស្គាល់សំលេងទាំងអស់នេះសិន។ បន្ទាប់មកសិស្សឈានទៅរកផ្ទេរចំណេះទាំងនេះតាមរយៈអត្ថបទភាសាដែលត្រូវបានគេបោះពុម្ពឡើងតាមរយៈការបង្រៀនរបស់គ្រូ។ ខណៈពេលដែលសិស្សមានការអភិវឌ្ឍន៍ចំណេះដឹងនៃការឆ្លើយឆ្លងគ្នាហើយរវាងសូរសំលេង និងនិមិត្តសញ្ញានានា ពួកគេនឹងឈានឆ្ពោះទៅរកការអភិវឌ្ឍន៍ជំនាញពាក់ព័ន្ធការសិក្សាពីអត្ថន័យនៃពាក្យ តាមរយៈពាក្យបន្ថែមដើម បន្ថែមចុង ឬពាក្យឫសជាដើម។ ជំនាញអាន គឺជាផ្នែកមួយដ៏សំខាន់ ដែលផ្តល់ឱកាសឱ្យអ្នករៀនភាសាអង់គ្លេសចាប់បានវេយ្យាករណ៍ ពង្រីកវាក្យស័ព្ទ ទទួលបាននូវភាពស្ទាត់ជំនាញក្នុងការសរសេរអត្ថបទជាដើម ហើយវាពង្រឹងជំនាញនិយាយ ( Interactive Approaches to Second Language Reading) ការអានបានផ្តល់ឱ្យសិស្សជាមួយនូវប្រយោគ

គំរូ រចនាសម្ព័ន្ធវេយ្យាករណ៍ និងរចនាសម្ព័ន្ធភាសា ឬឃ្លា ល្បះស្រាប់ៗដើម្បីឱ្យសិស្សយកមកអនុវត្តតាម[13]។

ការអានក៏ដូចជាសកម្មភាពការស្ដាប់ដែរ សិស្សអាចធុនទ្រាន់នៅពេលខ្លះ ហើយមិនសូវចូលចិត្តដោយហេតុថា សិស្សមានអារម្មណ៍ថាមិនអាចយល់នូវអ្វីដែលគេបានអាន។វាសំខាន់ណាស់ត្រូវចងចាំថា វាមិនចាំបាច់ទេ សម្រាប់សិស្សនៅកម្រិតបឋមសិក្សាដែលត្រូវតែយល់គ្រប់ៗពាក្យនៃអត្ថបទអានទេ អ្វីដែលសំខាន់សម្រាប់ពួកគេគឺយល់អត្ថន័យទូទៅនៃអត្ថបទខ្លីនោះ។ បញ្ហាមួយទៀត គ្រូត្រូវស្វែករកព័ត៌មានណាដែលចាំបាច់សម្រាប់សិស្សឬសិស្សចូលចិត្ត។ ជំរុញទឹកចិត្តឱ្យពួកគេបានអាន ហើយរឹតតែសំខាន់ នៅពេលដែលគ្រូជ្រើសរើសអត្ថបទដែលសិស្សចូលរួម សប្បាយរីករាយ ហើយអាចជំរុញភាពចង់ចេះចង់ដឹងរបស់ពួកគេ ដូច្នេះហើយ ពួកគេត្រូវបានជំរុញទឹកចិត្តឱ្យអានដោយខ្លួនឯងផ្ទាល់។ ដូច្នេះក្នុងការជ្រើសរើសយកអត្ថបទ ត្រូវពិចារណា ការលំបាកនៃភាសា ជម្រើសល្អផ្ដោតលើការសប្បាយ និងការចាប់អារម្មណ៍ក្នុងការអាន[14]។

### ២.៣.១.៣ ជំនាញសរសេរ

ជំនាញសរសេរ អាចនាំឱ្យសិស្សឈានទៅរកការអភិវឌ្ឍន៍ភាសារបស់ពួកគេ។ ការរៀនអាន ជួយសម្រួលដល់ការសរសេរតាមរយៈការបង្កើននូវភាពចេះដឹងច្បាស់ជាមួយនិងការសរសេរ ប្រកបពាក្យបានត្រឹមត្រូវ និងការប្រើប្រាស់រចនាសម្ព័ន្ធប្រយោគបានត្រឹមត្រូវ។ ទោះបីជាយ៉ាងដូច្នេះក្ដី ការសរសេរ មិនចាំបាច់ទាល់តែសរសេរតាមរយៈការអានអំណានទាំងស្រុងនោះទេ។ សម្រាប់អ្នករៀនភាសាអង់គ្លេសដើម្បីអនុវត្តចំណេះដឹងនៃការប្រើប្រាស់រចនាសម្ព័ន្ធប្រយោគនិងភាសា ពួកគេត្រូវតែដាក់ចូលក្នុងការអនុវត្តន៍ជាក់ស្ដែងនូវអ្វីដែល

---

[13] ក្រសួងអប់រំ យុវជន និងកីឡា (២០១២): កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សាថ្នាក់ទី៤ ទី៥និងទី៦ ទំព័រទី២-៣

[14] P. Harris, Reading in the Primary School Year, Cengage Learning Australia, 2005; A. Van Kleech,(Ed.), Sharing Books and Stories to Promote Language and Literacy, San Diego (CA), Plural Publishing,2006.

ពួកគេបានកត់សំគាល់តាមរយៈការអានដោយផ្សារភ្ជាប់ទៅក្នុងប្រភេទសំណេរផ្សេងៗគ្នា[15]។

ក្មេងៗនឹងដំណើរការបន្តិចម្តងៗពីការចម្លងចាប់តាំងពីពាក្យមួយៗឬប្រយោគ រហូតឈានទៅសរសេរអត្ថបទខ្លីៗ ការបរិយាយអំពីមនុស្ស សត្វ រឿងខ្លីៗ អត្ថបទសន្ទនាខ្លីៗ អំពីស្ថានភាពដែលគេបានដឹងច្បាស់ គ្រួសារផ្ទះ សាលារៀន មិត្តភ័ក្ត អាហារ និងការកម្សាន្ត[16]។

នៅសាលាបឋមសិក្សា សិស្សភាគច្រើននៅតែមិនអាចបង្កើតអត្ថបទដោយខ្លួនឯងបាន។ វាចាំបាច់ណាស់ សម្រាប់គ្រូត្រូវតែលះបង់ពេលវេលាដើម្បីបង្កើនសកម្មភាពនេះជាមួយសិស្ស ដោយការចាប់ផ្តើមអត្ថបទគំរូដែលរៀបចំដោយគ្រូ។ គ្រូត្រូវតែផ្តាច់អត្ថបទជាផ្នែកតូចៗ រួចសិស្សចាប់ផ្តើមសរសេរបង្កើតឡើងវិញ។នៅដំណាក់កាលបន្ទាប់ នៅពេលដែលសិស្សយល់ច្បាស់បានពីគំរូ ពួកគេនឹងអាចបន្តសរសេរអត្ថបទមួយផ្សេងទៀតដែលស្រដៀងគ្នាដោយខ្លួនឯងបាន។ ជាដំបូង ចាប់ផ្តើមដោយការពង្រាងអត្ថបទជ្រើសរើសបន្ទាប់មក បង្កើតសំណួរសួរសិស្សអំពីតួរអង្គ តើហេតុការណ៍អ្វីខ្លះដែលត្រូវដាក់ក្នុងអត្ថបទរបៀបបង្កើតសាច់រឿងបន្តបន្ទាប់ និងរបៀបបញ្ចប់រឿងក្នុងអត្ថបទ។

## ២.៣.២. សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា

សៀវភៅសិក្សាគោលមុខវិជ្ជាភាសាអង់គ្លេស បង្កើតឡើងស្របទៅនិងបរិបទគ្រួសាររបស់សិស្ស(ផ្ទះរបស់សិស្ស) បរិបទភូមិសាស្រ្ត និងសង្គមនៃសិស្សកម្ពុជាភាគច្រើន។ ក្នុងបរិបទជុំវិញគ្រួសារដែលមានឪពុកម្តាយជាកសិករ និងជាអ្នកលក់ដូរនៅតាមហាងឬតូបតូចៗ។ ភាគច្រើន ពួកគេរស់នៅតាមទីជនបទ។ សម្រាប់ពីថ្នាក់ទី៤ ដល់ទី៦ មាន ៣៨ ជំពូក។ មួយជំពូកបង្រៀនសម្រាប់រយៈពេលមួយសប្តាហ៍តែពីរមេរៀនប៉ុណ្ណោះ។ មានការកំណត់

[15] English Language Curriculum for Cambodian Primary Schools Grades 4,5, and 6 page 3

[16] O.L. Pysarchyk, N.V. Yamshynska, The importance of integrating reading and writing for EFL teaching in "Advanced Education",3,2015, pp. 77-83

ម៉ោងច្បាស់លាស់នៅក្នុងមេរៀននីមួយៗ តាំងពីការចាប់ផ្តើមការបង្រៀនរហូតដល់បំណាច់ឆ្នាំសិក្សា រួមទាំងការវាយតម្លៃការសិក្សារបស់សិស្ស តាមរយៈការវាយតម្លៃតាមដំណាក់កាល និងការវាយតម្លៃបូកសរុប និងរំលឹកមេរៀនឡើងវិញ។ទោះជាយ៉ាងដូច្នេះក្តី ការបន្ថែមការងារនៅទីបញ្ចប់ថ្នាក់នីមួយៗអាចត្រូវបានលុបចោល ប្រសិនបើគ្រូកំណត់ថាចាំបាច់ត្រូវត្រឡប់ទៅរំលឹកមេរៀនដើមដែលសិស្សនៅមិនទាន់យល់ច្បាស់។ លទ្ធផលការសិក្សារបស់សិស្សថ្នាក់ទី៤ ទី៥ និងទី៦គឺពឹងផ្អែកទៅលើ the Common European Framework of Reference for Languages (CEF or CEFR) ដែលត្រូវបានដាក់ចេញដោយក្រុមប្រឹក្សាអឺរ៉ុបដែលជាវិធីមួយ ធ្វើឱ្យមានលក្ខណៈស្តង់ដានូវកម្រិតនៃការប្រឡងភាសាតាមតំបន់ផ្សេងៗគ្នា។ វាត្រូវបានប្រើយ៉ាងទូលំទូលាយជាអន្តរជាតិ ហើយគ្រប់ការប្រឡងសំខាន់ៗទាំងអស់គឺបង្កើតដោយ CEFR។ ស្រដៀងគ្នានេះដែរ ការប្រឡងថ្នាក់ជាតិសម្រាប់ថ្នាក់ទី៦ អាចផ្អែកលើCEFR លទ្ធផលការរៀនរបស់សិស្សបច្ចុប្បន្នសម្រាប់ថ្នាក់ទី៦កម្រិតA1របស់CEFR[17]។

### ២.៣.៣. លទ្ធផលរំពឹងទុកសម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៤

សម្រាប់ថ្នាក់ទី៤ នៅបញ្ចប់ឆ្នាំសិក្សានៃការបង្រៀនសៀវភៅគោលនេះ សិស្សមានសមត្ថភាពរាប់ចំនួនលេខរហូតដល់៥០ ហើយព្រមទាំងមានចំណេះដឹងមូលដ្ឋានគ្រឹះទៅលើប្រធានបទបន្តបន្ទាប់ ដូចជា អក្ខរក្រម សមាជិកគ្រួសារមួយចំនួន ផ្នែកផ្សេងៗនៃរាងកាយ អាយុ ទិដ្ឋភាពមួយចំនួននៃបរិស្ថានរបស់សិស្ស រួមមាន ភូមិស្រុក បរិបទថ្នាក់រៀន បរិបទសាលារៀន ឈ្មោះមុខរបរមួយចំនួន។ សិស្សមានចំណេះដឹងពាក្យជាមូលដ្ឋានគ្រឹះ និងរចនាសម្ព័ន្ធវេយ្យាករណ៍( ប្រយោគ និងសំណួរ) ហើយសិស្សអាចមានសមត្ថភាពចាប់ផ្តើមការសន្ទនាជាភាសាអង់គ្លេសជាមួយមនុស្សផ្សេងៗអំពី មនុស្ស គ្រួសារ និងទំនាក់ទំនងសាច់ញាតិ[18]។

[17] English Language Curriculum for Cambodian Primary Schools Grades 4,5, and 6 page 8
[18] English Language Curriculum for Cambodian Primary Schools Grades 4,5, and 6 page 3

## ២.៣.៤. លទ្ធផលរំពឹងទុកសម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៥

នៅថ្នាក់ទី៥ សិស្សចាប់ផ្តើមពង្រឹង និងកសាងលើមូលដ្ឋានភាសាអង់គ្លេសដែលគេបានរៀននៅក្នុងថ្នាក់ទី៤ដើម្បីអភិវឌ្ឍ និងសម្រេចបានជាបន្តបន្ទាប់។ នៅបញ្ចប់ឆ្នាំសិក្សានៃការបង្រៀនសៀវភៅគោលនេះ សិស្សមានសមត្ថភាពអាចរាប់ចំនួនដល់រាប់ពាន់ មានមូលដ្ឋានគ្រឹះលើប្រធានបទជាបន្តបន្ទាប់ដូចជា គ្រួសារ សាលារៀន កសិដ្ឋាន ហាង អាកាសធាតុ។ សិស្សមានសមត្ថភាពចេះវាក្យស័ព្ទពាក់ព័ន្ធពីមុនមក និងរចនាសម្ព័ន្ធវេយ្យាករណ៍(ប្រយោគ និង សំណួរ) ដែលពាក់ព័ន្ធ ហើយសិស្សអាចទំនាក់ទំនងពេញលេញបន្ថែមទៀតក្នុងការទំនាក់ទំនងជាភាសាអង់គ្លេសជាមួយមនុស្សដទៃទៀតអំពីមនុស្ស។

## ២.៣.៥. លទ្ធផលរំពឹងទុកសម្រាប់សៀវភៅសិក្សាគោលថ្នាក់ទី៦

នៅថ្នាក់ទី៦ សិស្សអាចពង្រឹង និងកសាងមូលដ្ឋានគ្រឹះភាសាអង់គ្លេសនៅថ្នាក់ទី៤ និងទី៥ ដើម្បីបំពេញតម្រូវការនៅកម្រិតថ្នាក់ទី៧។ ពួកគេគួរតែមានមូលដ្ឋានគ្រឹះភាសាអង់គ្លេសពិតប្រាកដ បង្កើននូវចំណេះដឹងនៅពេលឡើងថ្នាក់ទី៧។ សិស្សគួរតែមានសមត្ថភាពលើវាក្យស័ព្ទ និងសំណង់ប្រយោគដើម្បីបង្ហាញពីបំណងប្រាថ្នា និងគោលបំណងជាភាសាអង់គ្លេសដែលពាក់ព័ន្ធទៅនិងមិត្តភក្តិ សមាជិកគ្រួសារ តំបន់ នៅភូមិ ឃុំរបស់ពួកគេ សត្វពាហនៈ កសិដ្ឋាន ហាងលក់ទំនិញ ថ្ងៃខែឆ្នាំកំណើត និងអាកាសធាតុដោយប្រើប្រាស់ជំនាញទាំងបួនដូចជា៖ ការអាន ការស្តាប់ ការនិយាយ និង ការសរសេរ។ ជាងនេះទៅទៀត ពួកគេក៏អាចប្រើប្រាស់នូវគុណនាមមួយចំនួនបានត្រឹមត្រូវនិងតាមលំដាប់។ ទន្ទឹមនឹងនេះដែរ ពួកគេមានសមត្ថភាពនិយាយស្វាគមន៍ ពណ៌នា ផ្តល់ព័ត៌មាន សួរនិងឆ្លើយសំណួរដោយប្រើប្រាស់ Present Simple និងPresent Continuous រួមទាំងទម្រង់បដិសេធបានយ៉ាងត្រឹមត្រូវ។ ការផ្តោតយ៉ាងសំខាន់នៃភាសាអង់គ្លេសសម្រាប់បឋមសិក្សានៅកម្ពុជា (PEC) គឺដើម្បីកសាងទំនុកចិត្តទៅលើធាតុជាមូលដ្ឋាននៃភាសាអង់គ្លេស មានជាអាទិ៍ ការបញ្ចេញសំឡេង ការសរសេរអក្សរ ការសន្ទនា សំណួរ និងចម្លើយងាយៗ ជំនាញក្នុងការអាន និងសរសេរដោយផ្អែកទៅលើបរិបទដែលធ្លាប់បានជួបកន្លងមក។ ដើម្បីពង្រឹងចំណេះដឹងនិងភាពជឿជាក់ សិស្សនឹងសិក្សាបន្ថែមនូវពាក្យវាក្យស័ព្ទប្រហែល៧០០ពាក្យ ដែលពាក់ព័ន្ធក្នុងជីវិតរបស់ពួកគេដូចជា នៅផ្ទះ សាលារៀន ភូមិ មិត្តភក្តិ និងគ្រួសារ។

## ២.៣.៦ របាយមុខវិជ្ជា និងម៉ោងសិក្សាភាសាអង់គ្លេសនៅសាលាបឋមសិក្សា

ក្រសួងអប់រំ យុវជននិងកីឡា បានដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅកម្រិតបឋមសិក្សាចំណេះទូទៅពីថ្នាក់ទី៤ដល់ថ្នាក់ទី៦ ដើម្បីផ្តល់ឱកាសឱ្យសិស្សបានសិក្សាជាមូលដ្ឋានដំបូងនៃភាសាអង់គ្លេសសម្រាប់ជាគ្រឹះក្នុងការបន្តការសិក្សានៅកម្រិតមធ្យមសិក្សា។ដើម្បីអនុវត្តកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលភាសាអង់គ្លេសឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ យុវជននិងកីឡា សូមធ្វើការណែនាំដូចតទៅះ

១. ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស

គ្រប់គ្រឹះស្ថានសាលាបឋមសិក្សាចំណេះទូទៅសាធារណៈទាំងអស់ ត្រូវប្រើប្រាស់សៀវភៅភាសាអង់គ្លេស " English Grade 4, Grade 5 and Grade 6" ជាសៀវភៅសិក្សាគោលតែមួយគត់ក្នុងការបង្រៀន និងរៀននៅតាមសាលាបឋមសិក្សាទូទាំងប្រទេស។

២. ការប្រើប្រាស់ម៉ោងសិក្សា

ការបង្រៀន និងរៀនភាសាអង់គ្លេសនេះ ត្រូវបែងចែករបាយម៉ោងឱ្យបានច្បាស់លាស់ក្នុងកាលវិភាគប្រចាំសប្តាហ៍ ដោយអនុវត្ត២ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ហើយ១ម៉ោងមានរយៈពេល៤០នាទី។

តារាងទី២ះ របាយម៉ោងមុខវិជ្ជា និងម៉ោងសិក្សាថ្នាក់ទី១ដល់ថ្នាក់ទី៦

| ល.រ | មុខវិជ្ជា | កម្រិតថ្នាក់ | | | | | |
|---|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ | ៦ |
| ១ | ភាសាខ្មែរ | ១១ | ១១ | ១១ | ៩ | ៩ | ៩ |
| ២ | គណិតវិទ្យា | ៧ | ៧ | ៧ | ៦ | ៦ | ៦ |
| ៣ | វិទ្យាសាស្ត្រ | ៣ | ៣ | ៣ | ៣ | ៣ | ៣ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៤ | កុំព្យូទ័រ | ០ | ០ | ០ | ១ | ១ | ១ |
| ៥ | សិក្សាសង្គម | ៣ | ៣ | ៣ | ៣ | ៣ | ៣ |
| ៦ | អប់រំសិល្បៈ | ១ | ១ | ១ | ១ | ១ | ១ |
| ៧ | អប់រំកាយនិងកីឡា | ២ | ២ | ២ | ២ | ២ | ២ |
| ៨ | អប់រំសុខភាព | ១ | ១ | ១ | ១ | ១ | ១ |
| ៩ | ភាសាបរទេស | ២ | ២ | ២ | ២ | ២ | ២ |
| ១០ | បំណិនជីវិតតាមមូលដ្ឋាន | ០ | ០ | ០ | ២ | ២ | ២ |
| សរុបម៉ោងសិក្សាប្រចាំសប្តាហ៍ | | ៣០ | ៣០ | ៣០ | ៣០ | ៣០ | ៣០ |

សម្គាល់៖ ៦ថ្ងៃក្នុងមួយសប្តាហ៍ ៥ម៉ោងសិក្សាក្នុងមួយថ្ងៃ និងម៉ោងសិក្សាមានពេល៥០នាទី ២៤។

## ២.៣.៧ របៀបទូទៅនៃការរៀនភាសារបស់កុមារដើម្បីទទួលបានជំនាញភាសាអង់គ្លេស

កុមារជាអ្នករៀនបែបភាសាធម្មជាតិ( natural language acquirers)។ ពួកគេមានការជម្រុញខ្លួនឯងដើម្បីរៀនចាប់យកភាសាដោយមិនចាំបាច់ដឹងអំពីការរៀនសូត្រ( without conscious learning) ដែលមិនដូចជារបៀបរៀនរបស់មនុស្សពេញវ័យ ឬក្មេងជំទង់ទេ។ បញ្ហានេះ គឺដោយសារ កុមារកើតមកដោយមានសមត្ថភាពរៀនភាសាពីកំណើតបែបធម្មជាតិ ដែលពួកគេប្រើ ដើម្បីទៅយកភាសាជាបន្តបន្ទាប់។ មានទ្រឹស្តីផ្សេងៗគ្នាជាច្រើនត្រូវបានលើកឡើងអំពីរបៀបដែលកុមាររៀនភាសា។ អ្នកទ្រឹស្តីអាកប្បកិរិយានិយម ( Behaviorists) ជឿជាក់ថាខួរក្បាលរបស់កុមារគឺទទេហើយសង្គមទទួលខុសត្រូវការសរសេរនៅលើវា។ ផ្ទុយទៅវិញ អ្នកពុទ្ធិនិយម (Cognitivists) បានសង្កត់ធ្ងន់លើការពិតថា ទារកកើតមកមានសមត្ថភាពគិតដែលអាចឱ្យពួកគេយល់ (perceive) និងវិភាគ( analyze) ភាសាដែលពួកគេបានឮ។ អ្នកស្រាវជ្រាវ មានទស្សនៈថា កុមារមានសមត្ថភាពក្នុងការគិតហើយវាជាសមត្ថភាពដែលអាច

គិតថា ពួកគេអាចចាប់យកភាសាបាន។ ឧបករណ៍ចាប់យកភាសា (Language Acquisition Device)ក្នុងខួរក្បាលរបស់កុមារ បានជួយពួកគេឱ្យរៀនភាសាណាមួយក៏បានដែរ។ នេះមានន័យថា ខួរក្បាលរបស់មនុស្សត្រូវបានគេសរសេរកម្មវិធីដើម្បីឱ្យបុគ្គលម្នាក់ៗអាចរៀន និងប្រើប្រាស់ភាសាបាន។ ទារកបានចាប់ផ្ដើមទំនាក់ទំនងតាំងពីពេលដំបូងដូចជា ទារកអាចទំនាក់ទំនងតាមរយៈភ្នែកដែលតាមសម្លឹងមើលទៅលើពន្លឺជាដើម។ MOE (2001) និយាយថា នេះគឺជាការចាប់ផ្ដើមនៃការចែករំលែកភាសា។ កុមារកើតមកមានសមត្ថភាពក្នុងការធ្វើតាមការបញ្ចេញសម្លេង និងធ្វើការដោយគ្មានច្បាប់នៃភាសាដោយខ្លួនគេផ្ទាល់។ ដូចដែលបានរៀបរាប់ខាងលើ ទារកមានសមត្ថភាពក្នុងការដឹងក្បួននៃភាសាដែលពួកគេបានឮ។ ទោះជាយ៉ាងណា វាត្រូវបានគេនិយាយថា សមត្ថភាពនេះបានថយចុះនៅពេលដែលពួកគេធំឡើង។ ការត្រៀមខ្លួនរបស់កុមារក្នុងការប្រើភាសា ក៏ត្រូវបានទទួលឥទ្ធិពលពីការបណ្ដុះបណ្ដាល និងបទពិសោធន៍ផងដែរ។ កុមារទទួលបានភាសាទីមួយ ជាមូលដ្ឋានសម្រាប់ការរស់រានមានជីវិត ពីព្រោះថា ពួកគេត្រូវការវាដើម្បីធ្វើអន្តរកម្មជាមួយបរិស្ថាន។ កុមារទាំងអស់ អភិវឌ្ឍភាសាទីមួយតាមវិធីប្រហាក់ប្រហែលគ្នា។ យោងតាម Kimathi និង Ngungi (ឆ្នាំ2007) កុមារគ្រប់រូបចេះនិយាយភាសាតាមរយៈដំណាក់កាលខាងក្រោម៖

១. ការបន្លឺភាសានិយាយ មុន 0-3ខែ

២. និយាយកកេរកករពី 3-6ខែ

៣. ពាក្យមួយ (holophrastic)ពី 12 ទៅ 18ខែ

៤. ពីរពាក្យ (telegraphic) ពី 18-24ខែ

៥. រៀនចាប់យកឃ្លាតាមវេយ្យាករណ៍ ( Acquisition of grammar ) 2 - 6ឆ្នាំ។ MoEST បានដកស្រង់សម្ដី Stark (1996) បានលើកឡើងថា កុមារអភិវឌ្ឍភាសាតាមរយៈបួន ដំណាក់កាល ៖

(១) យំ (crying) 6-7សបាហ៍

(២) សម្លេងរោទ៍ និងសើច (cooing and laugher) 8 ទៅ 20សប្តាហ៍

(៣) និយាយសម្លេងដើមក (vocal plays) 16 ទៅ 30សប្តាហ៍

(៤) និយាយករកេរកករ (babbling) 25-30សប្តាហ៍

ក្មេងៗឆ្លងកាត់ដំណាក់កាលនៃការអភិវឌ្ឍភាសានេះបន្តិចម្តងៗ តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់កុមារដើម្បីរៀន និងការប្រាស្រ័យទាក់ទងគ្នានៅក្នុងភាសាថ្មីត្រូវបានជួបប្រទះជាញឹកញាប់ជាមួយនិងការកោតសរសើរជាច្រើនដោយម្តាយ និងអ្នកដទៃ ដោយសារតែ កុមារកំពុងខិតខំប្រឹងប្រែងទំនាក់ទំនងភាសា។ មិនមានការទាមទារសំខាន់នោះៗទេ នៅដើមឆ្នាំនៃដំណាក់កាលនៃការអភិវឌ្ឍន៍ភាសា នេះគឺដោយសារតែ មិនមានច្បាប់កំណត់ដើម្បីរៀនភាសាដំបូង ដូច្នេះ រាល់ការខិតខំប្រឹងប្រែងរបស់កុមារត្រូវបានទទួលការស្វាគមន៍។ Haynes (2005) យល់ស្របថា កុមារឆ្លងកាត់ដំណាក់កាលផ្សេងៗគ្នានៃដំណើរការនៃការរៀនភាសា។ គាត់និយាយថា ក្នុងអំឡុងពេលមុនផលិត(Pre-production) ឬអំឡុងពេលស្ងាត់ស្ងៀម( silent period) ក្មេងៗ មានរហូតដល់ 500ពាក្យ នៅក្នុងវាក្យស័ព្ទទទួល និងមិនត្រូវបានផលិតភាសានៅឡើយទេ។ នៅដំណាក់កាលនេះ កុមារអាចឆ្លើយតបទៅនឹងរូបភាព និង វត្ថុផ្សេងៗទៀត។ Dunn (ឆ្នាំ2005) បានបន្ថែមថា ក្នុងអំឡុងពេលស្ងៀមស្ងាត់( silent period) កុមារ មើល ស្តាប់ និងប្រាស្រ័យទំនាក់ទំនងតាមរយៈការបញ្ចេញទឹកមុខ ឬកាយវិការ មុនពេលពួកគេចាប់ផ្តើមនិយាយពាក្យដែលចងចាំ ទោះបីជាគេប្រើមិនបានត្រឹមត្រូវក៏ដោយ។ ប៉ុន្តែ បើយោងតាម Haynes (ឆ្នាំ2005) នៅពេលកុមារទទួលបានវាក្យស័ព្ទនៃពាក្យសកម្មចំនួន 6000ពាក្យ កុមារអាចប្រើប្រយោគស្មុគស្មាញបាន នៅពេលទំនាក់ទំនង។ ក្នុងអំឡុងពេលដំណាក់កាលនៃការអភិវឌ្ឍន៍ភាសា ឪពុកម្តាយចាំបាច់ត្រូវតែផ្តល់ឱ្យកូនរបស់ពួកគេ ជាមួយនឹងប្រតិកម្មត្រឹមត្រូវដើម្បីឱ្យពួកគេធ្វើតាម។ ឪពុកម្តាយអាចឆ្លើយតបទៅនឹងការយំរបស់កូនក្មេង និងសម្លេងស្រែករបស់កុមារ មតិយោបល់ផ្តល់ឱ្យកុមារមានអារម្មណ៍ថា វានៅលើផ្លូវត្រូវ។ ចាប់ពីពេលនោះមក កុមារបានរៀនសូត្រច្រើនពីបរិស្ថានតាមរយៈអន្តរកម្ម។ ពួកគេ ប្រើបទពិសោធន៍ទាំងនេះ ដើម្បីរៀនភាសាទីពីរនៅពេលពួកគេនៅក្មេង។ ការសិក្សានេះ បានគាំទ្រទិដ្ឋភាពធាតុចូលនៃភាសា( language input) ដែលកុមារទទួលបានពីឪពុកម្តាយ និងបទពិសោធន៍ដែលពួកគេទទួលបាននៅក្នុងបរិស្ថាន បានធ្វើឱ្យពួកគេ

រៀនភាសាលឿនជាងមុន។ Haynes (ឆ្នាំ2005) និយាយបន្ថែមទៀតថា វាត្រូវការពេល 4 ទៅ 10ឆ្នាំសម្រាប់កុមារ ដើម្បីសម្រេចបាននូវចំណេះដឹងខាងការយល់ដឹងផ្នែកភាសាជាភាសាទីពីរ។ ដូចដែលបានរៀបរាប់ខាងលើ នៅក្នុងការពិភាក្សានេះ កុមារបានឆ្លងកាត់ការប្រើប្រាស់ភាសាអង់គ្លេសជាប្រចាំជាលើកដំបូងនៅសាលារៀន។ ភាសាអង់គ្លេសត្រូវបានគេរៀននៅសាលាជាភាសាទីពីរ ដោយសារតែវាជាមុខវិជ្ជាសំខាន់ៗនៅក្នុងកម្មវិធីសិក្សា ដូចនេះ កុមារចាំបាច់ត្រូវនិយាយ និងសរសេរជាភាសាអង់គ្លេស។ Goodson និងPeters (1990) បានបន្ថែមថា ពីព្រោះតែ ភាសាអង់គ្លេសគឺជាមធ្យោបាយនៃការបង្ហាត់បង្រៀននៅក្នុងប្រព័ន្ធអប់រំ ហើយភាសាអង់គ្លេស ត្រូវបានអនុវត្តលើមុខវិជ្ជាផ្សេងៗទៀតជាមូលដ្ឋានគ្រឹះ វាក៏ជាមុខវិជ្ជាសំខាន់ផងដែរ ពីព្រោះវាត្រូវបានគេនិយាយទូទាំងពិភពលោកពោលគឺអង់គ្លេសជាភាសាយាន។ យោងតាមទៅតាម Manning (1997) ភាសាអង់គ្លេស គឺជាមធ្យោបាយដែលមិនអាចខ្វះបានសម្រាប់ការទំនាក់ទំនង។ តាមការប៉ាន់ប្រមាណ មានមនុស្សចំនួនប្រាំពីរលាននាក់នៅទូទាំងពិភពលោកនិយាយភាសានេះ ដោយសារតែសារៈសំខាន់របស់វា នៅក្នុងកម្មវិធីសិក្សា។ MOE (2001) បានបង្ហាញថា ការរៀនភាសាអង់គ្លេសមានការពាក់ព័ន្ធជាមួយការអភិវឌ្ឍន៍ជំនាញចំនួនបួននៃភាសាអង់គ្លេស ហើយបានបន្ថែមទៀតថា ភាសាអង់គ្លេសត្រូវបានរៀនជាប្រព័ន្ធ ហើយត្រូវបានគ្រប់ដណ្តប់ដោយក្បួនវេយ្យាករណ៍ និងជាទូទៅ ការទាមទារការប្រើប្រាស់បានត្រឹមត្រូវ។ ភាសាអង់គ្លេស មានរចនាសម្ព័ន្ធ នេះវាខុសពីភាសាកំណើតដែលកុមារទទួលបានតាមធម្មជាតិដោយគ្មានច្បាប់ផ្លូវការ ។ Kimathi និង Ngungi (2007) បានបង្ហាញថា កុមារទទួលបានភាសាអង់គ្លេសជាភាសាទីពីរៈ

(១) តាមរយៈអន្តរកម្មជាមួយអ្នកនិយាយ

(២) តាមរយៈការស្តាប់ និងការនិយាយភាសា

(៣) តាមរយៈការបង្រៀនជាផ្លូវការ

(៤) តាមរយៈការសិក្សាឯកជន ឬបុគ្គល

កុមារត្រូវចេះក្បួនច្បាប់ និងវេយ្យាករណ៍ ប្រសិនបើ ពួកគេត្រូវរៀនភាសាអង់គ្លេសជាភាសាទីពីរ។ នេះគឺជាកិច្ចការដ៏លំបាកមួយសម្រាប់កុមារ ដែលមានឥទ្ធិពលដោយភាសាកំណើតរបស់ពួកគេរួចហើយ។ Dunn (2005) បានកត់សម្គាល់ថា ការជ្រើសរើសភាសាទីបី ទីបួន ឬភាសាច្រើនជាងនេះ គឺងាយស្រួលជាងការជ្រើសរើសភាសាទីពីរ។ ដោយយោងទៅលើទៅ Stark (ឆ្នាំ1996) ពេលណាកុមាររៀនភាសាដំបូង ពួកគេបានឆ្លងកាត់ដំណាក់កាលដំបូងនៃភាសាទីមួយ ការអភិវឌ្ឍន៍ភាសានឹងមានភាពងាយស្រួល។ ប៉ុន្តែនៅក្នុងការអភិវឌ្ឍន៍ភាសាទីពីរ ក្មេងមិនអាចឆ្លងកាត់បានទេតាមរយៈការយំសម្លេងពេរ៍ និងកកេកករ ប៉ុន្តែផ្ទុយទៅវិញ ត្រូវប្រឈមនឹងបញ្ហានៃច្បាប់វេយ្យាករណ៍ និងឥទ្ធិពលនៃភាសាទីមួយ។ MOE (2001) បញ្ជាក់ថា កុមារនឹងជួបប្រទះនឹងបញ្ហាភាសាកំណើតនៅពេលពួកគេរៀនភាសាទីពីរ។ ភាសាកំណើតរបស់កុមារ មានឥទ្ធិពលលើការនិយាយ និងរចនាសម្ព័ន្ធអក្ខរាវិរុទ្ធ។ បញ្ហាទាំងនេះ នៅតែកើតមានលើកុមារមួយចំនួនធំច្រើនឆ្នាំមកហើយ ជាមូលហេតុចម្បងនៃវេយ្យាករណ៍មិនល្អនៅក្នុងការបង្កើតប្រយោគ ការសរសេរ និងការនិយាយភាសាអង់គ្លេស។ ឥទ្ធិពលនៃភាសាកំណើតចំពោះកុមារ បន្តការប៉ះពាល់ដល់គុណភាពនៃការតែងសរសេរ និងការសរសេរប្រយោគភាសាអង់គ្លេស។ ដោយសារតែ ពីការបង្រៀន និងការរៀនភាសាអង់គ្លេសនៅមានក្តីបារម្ភ។ ជាទូទៅ ការបង្រៀនជំនាញភាសាទាំងបួនត្រូវតែអនុវត្តឡើងដោយខានមិនបាន។ កុមារអាចបង្កើនសមត្ថភាពភាសាអង់គ្លេសប្រសិនបើ ពួកគេស្តាប់ និយាយ សរសេរ និងអានភាសាអង់គ្លេស។ គ្រូបង្រៀនជាដំបូង គួរតែអភិវឌ្ឍជំនាញស្តាប់ចំពោះសិស្សជាមុនសិន មុននឹងបន្តទៅជំនាញបន្ទាប់។ ការស្តាប់ គឺជាជំនាញមុនដំបូង មុននឹងឈានទៅរកជំនាញនិយាយ។ យោងទៅតាម MOE (2001) មូលដ្ឋានគ្រឹះនៃភាសាអង់គ្លេស គឺស្ថិតនៅក្នុងការស្តាប់ និងនិយាយ។ គ្រូបង្រៀនត្រូវការបង្កើតសកម្មភាពបង្រៀន និងរៀនដើម្បីបង្កើនជំនាញក្នុងការស្តាប់កុមារ។ គ្រូបង្រៀន អាចសុំឱ្យសិស្សនិទានរឿងខ្លះៗ ឯសិស្សដទៃទៀត ស្តាប់ ឬសិស្សដ៏ទៃ អានរឿងទៅថ្នាក់រៀន ផ្តល់ការបង្រៀនពាក្យ និងប្រើរូបភាពដើម្បីបំផុសការពិភាក្សា និងការនិទានរឿងដល់កុមារ។ សកម្មភាពស្តាប់ផ្សេងៗទៀត ដែលអាចធ្វើឱ្យកុមារចូលរួមក្នុងការស្តាប់ គឺការអធិប្បាយ ការស្តាប់វិទ្យុ ឬតន្ត្រី ខ្សែអាត់សំលេង កម្មវិធីទូរទស្សន៍ និងការនិទានរឿងផ្សេងៗ។ ជំនាញសំខាន់បន្ទាប់ គឺជំនាញនិយាយ។ ទាំងការស្តាប់ និងការនិយាយ មិនត្រូវបានបង្រៀនដាច់

ដោយឡែកពីគ្នាទេ។ Kimathi និង Ngungi (2007) បញ្ជាក់ថា កុមាររៀនភាសាទីពីរដោយការស្តាប់និងនិយាយភាសា។ Popp (1996) បានបង្ហាញថា គ្រូបង្រៀនចាត់ទុកការស្តាប់ និងការនិយាយជាឧបករណ៍សម្រាប់ការសិក្សា និងការអនុវត្តន៍ជំនាញទាំងនេះ ចំពោះកម្មវិធីសិក្សា ដោយសារ ពួកគេមានជំនឿថា សមត្ថភាពក្នុងការនិយាយ និងការស្តាប់មានប្រសិទ្ធភាពជួយដល់ការរៀនសូត្រទាំងអស់។ គ្រូបង្រៀន អាចជំរុញឱ្យកុមារនិយាយភាសាអង់គ្លេសតាមរយៈការពិភាក្សា។ កុមាររៀនទំនាក់ទំនងផ្ទាល់មាត់ នៅពេលនោះហើយ ដែលនាំឱ្យពួកគេឈានទៅរកទំនាក់ទំនងជាមួយអ្នកដទៃ។ ពួកគេ ត្រូវបានលើកទឹកចិត្តឱ្យនិយាយប្រសិនបើ ពួកគេចង់ក្លាយជាអ្នកទំនាក់ទំនងល្អ។ យោងតាម Hennings (1990) ការអនុញ្ញាតឱ្យសិស្សនិយាយ បង្កើនការនិយាយភាសាអង់គ្លេសរបស់ពួកគេ។ ភាសាផ្ទាល់មាត់មានសារៈសំខាន់ណាស់ ព្រោះវាបានជួយបង្កើនការអាន និងការសរសេរ។ គ្រូបង្រៀនអាចរៀបចំការពិភាក្សាក្នុងថ្នាក់ ដើម្បីបង្កើនភាពស្ទាត់ជំនាញផ្ទាល់មាត់របស់កុមារ។ គ្រូបង្រៀន អាចឱ្យកុមារចូលរួមក្នុងសកម្មភាពការងារដូចជាៈ ការសរសេរសន្ទនារវាងមនុស្សពីរឬបីនាក់។ កុមារ ក៏អាចត្រូវបានលើកទឹកចិត្តដើម្បីបង្ហាញពីអារម្មណ៍របស់ពួកគេ តាមរយៈការផ្លាស់ប្តូរព័ត៌មានប្រាប់រឿងរ៉ាវ និងនិយាយអំពីព្រឹត្តិការណ៍ ឬបទពិសោធន៍។ កុមាររៀនភាសាតាមរយៈការបន្សាំទៅនិងភាសា។ កុមារអាចត្រូវបានលើកទឹកចិត្តឱ្យស្តាប់អ្នកដទៃទៀត ហើយចូលរួមក្នុងការសន្ទនាប្រកបដោយគោលបំណង។ ការនិយាយ និងការស្តាប់ គឺជាគ្រឹះនៃការរៀនភាសាគ្រប់ភាសាទាំងអស់ ហើយជាមូលដ្ឋានសម្រាប់ការអាន និងការសរសេរ។ ដើម្បីលើកកម្ពស់សិស្សដែលនិយាយភាសាអង់គ្លេស គ្រូបង្រៀនអាចលើកទឹកចិត្តកុមារឱ្យប្រាប់រឿង ឬប្រាប់ពីអ្វីដែលពួកគេឃើញនៅក្នុងរូបភាព រៀបរាប់អំពីព្រឹត្តិការណ៍ និងអានបណ្ណពាក្យ និងឆ្លើយសំណួរយល់ដឹង។ នេះជួយកំណត់ពីរបៀបដែលកុមារយល់ដឹងអំពីអ្វីដែលគាត់បានឮ ឬអាន។ Holt, Rinehart និង Winston (2001) បានបង្ហាញថា មុនពេល ដឹកនាំកុមារឈានទៅរកការអាន ពួកគេគួរតែដឹងសំឡេងអក្សរនីមួយៗ និងបណ្តុំនៃអក្សរបង្កើតបានជាពាក្យ។ គ្រូបង្រៀន អាចរៀបចំសកម្មភាពអានដើម្បីបង្កើនជំនាញក្នុងការអានរបស់សិស្ស។ គ្រូបង្រៀន ផ្តល់ឱ្យអ្នកអាននូវពាក្យខ្លីៗ តាមរយៈបណ្ណពាក្យ សៀវភៅរឿង ល្បែងអានកាតជាដើម។ វិធីសាស្ត្រនៃការ "មើលហើយនិយាយ" ជួយអ្នករៀនបង្កើតបាននូវការមើលឃើញវាក្យស័ព្ទ និងសិស្សត្រូវ

បានបង្រៀនឱ្យចេះភ្ជាប់សូរសំឡេងនៃពាក្យ (phonemes) ជាមួយនិមិត្តសញ្ញាអក្សរ ដើម្បីធ្វើអានពាក្យ។ គ្រូបង្រៀន ក៏អាចប្រើវិធីសាស្ត្របង្កើតប្រយោគពីពាក្យដែលបានសរសេរនៅលើកាត។ គ្រូបង្រៀនអាចលើកទឹកចិត្តក្មេងៗឱ្យស្គាល់ពាក្យ តាមរយៈរូបរាងទាំងមូលជាជាងអក្សរនៃពាក្យដែលត្រូវបានបង្កើតឡើង។ នៅទីបំផុត កុមារបានរៀនពាក្យទាំងនោះ ហើយបង្កើតប្រយោគ ហើយក៏បានបង្កើតឡើងនូវសារមួយ។ ប៉ុន្តែ Holt, Rinehart និង Winston (2001) បានអះអាងបន្ថែមទៀតថា មុនពេលដែលអ្នកធ្វើឱ្យកុមារអាន មុនសកម្មភាពអាន ចូលឱ្យកុមារសរសេររឿងសាមញ្ញៗអំពីព្រឹត្តិការណ៍សិន។ ការអាន ដូចជាការសរសេរដែរ គឺជាដំណើរការដែលត្រូវបានបង្កើតឡើងដោយជំហានជាច្រើន ហើយវាត្រូវការការខិតខំប្រឹងប្រែងដើម្បីសំរេចវា។ នៅពេលដែលកុមារអាចអាន ពួកគេអាចត្រូវបានលើកទឹកចិត្តឱ្យសរសេរដោយសេរី និងប្រកបដោយភាពច្នៃប្រឌិត។ ការសិក្សានេះចង់បញ្ជាក់ថា សមត្ថភាពកុមារក្នុងការសរសេរ និងការអាន គឺមិនមែនគ្រប់គ្រាន់ដើម្បីមើលពួកគេតាមរយៈការអប់រំទេ ប៉ុន្តែត្រូវមើលតាមរយៈការបង្រៀន ជាមធ្យោបាយនៃការប្រើប្រាស់ភាសាក្នុងប្រព័ន្ធសាលា។ គ្រូស្ថិតនៅក្នុងទិដ្ឋភាពនេះ ត្រូវតែជាគំរូសរសេរដោយសរសេរឱ្យបានត្រឹមត្រូវបំផុត មុនផ្តល់ឱ្យពួកគេអាន ពេលបង្រៀនការស្តាប់ ការនិយាយ ការសរសេរ និងការអាន។ MOE ( 2001) ក្រើនរំលឹកថា ការបង្រៀនបំណិនភាសា ទាំងបួននេះ មិនគួរត្រូវបានបង្រៀនដាច់ដោយឡែកពីគ្នាទេ ផ្ទុយទៅវិញ គួរតែមានការបញ្ចូលគ្នាជំនាញទាំងនេះនៅពេលបង្រៀនជំនាញណាមួយ ក្នុងចំណោមជំនាញទាំងបួន។ គ្រូបង្រៀនត្រូវចេះច្នៃប្រឌិត ដើម្បីលើកកម្ពស់ការរៀនសូត្រចំពោះសិស្សរបស់ពួកគេ។

## ២.៣.៨ ជំនាញនិងចំណេះដឹងរបស់គ្រូបង្រៀនក្នុងការបង្រៀនភាសាអង់គ្លេស

យោងទៅតាម Genesis Framework, World Press (2014) សមត្ថភាពគ្រូបង្រៀនសំដៅទៅលើវិធីនៃការពាំនាំបណ្តុំនៃចំណេះដឹងអនុវត្ត និងជំនាញដល់សិស្ស។ វិធីត្រឹមត្រូវនៅទីនេះរួមបញ្ចូលចំណេះដឹងនៃខ្លឹមសារ ដំណើរការ វិធីសាស្ត្រ និងមធ្យោបាយនៃការបញ្ជូនខ្លឹមសារទៅដល់សិស្ស។ គ្រូបង្រៀនជាមនុស្សសំខាន់ដែលដឹកនាំឆ្ពោះទៅកាន់ការអភិវឌ្ឍន៍ចំណេះដឹងផ្នែកភាសាបរទេសរបស់សិស្ស។ គ្រូបង្រៀន គឺជាអ្នកសម្របសម្រួល និងជាគំរូមួយសម្រាប់សិស្សរបស់គាត់។ ក្រសួងអប់រំ យុវជន និងកីឡា (2013) បានបង្ហាញ

ថា គ្រូបង្រៀន គឺធនធានដ៏សំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។ ដូច្នេះ ពួកគាត់ត្រូវប្រើប្រាស់សម្ភារៈបង្រៀនផ្សេងៗ ដើម្បីជួយឱ្យកិច្ចការបង្រៀនរបស់ខ្លួនកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។ គ្រូបង្រៀនដែលមានប្រសិទ្ធិភាព បង្កើតឱ្យការបង្រៀនរបស់សិស្សឱ្យកាន់តែមានប្រសិទ្ធភាពភាព សម្រាប់ជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍន៍ប្រទេសជាតិ និងអនាគតរបស់ពួកគេ។ ដោយសារតែ គ្រូបង្រៀនដើរតួនាទីសំខាន់នៅក្នុងការបង្រៀន និងរៀនភាសាអង់គ្លេស ដូច្នេះ ពួកគាត់ចាំបាច់ត្រូវមានសមត្ថភាព ចំណេះ ដឹងជំនាញ ក្នុងការបង្រៀនភាសាអង់គ្លេសនៅក្នុងថ្នាក់រៀន។ ដើម្បីសម្រេចបាននូវថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព ការបង្រៀន និងការរៀនត្រូវការ គ្រូដែលមានសមត្ថភាពខ្ពស់ ឬមានសមត្ថភាពក្នុងការបង្រៀនភាសាអង់គ្លេស។ សមត្ថភាពរបស់គ្រូបង្រៀនម្នាក់ៗ មានសារៈសំខាន់ណាស់ ពីព្រោះថា ពួកគាត់បានជួយក្នុងការបង្កើនការចាប់យកភាសាអង់គ្លេសសម្រាប់សិស្សតាមរយៈការជ្រើសរើស និងការរៀបចំសកម្មភាពបង្រៀននិងរៀន ការរៀបចំ និងការប្រើប្រាស់សកម្មភាពបង្រៀននិងការរៀនក្នុងចំនោមផ្នែកដទៃទៀត ដែលគាំទ្រការរៀនភាសាអង់គ្លេសរបស់កុមារនៅសាលារៀន។ គ្រូបង្រៀន ចាំបាច់ត្រូវមានចំណេះដឹងខ្លឹមសារឱ្យបានត្រឹមត្រូវ ហើយអាចអនុវត្តខ្លឹមសារនេះ ជាមួយសិស្សដើម្បីឱ្យទទួលបាននូវចំណេះដឹង។ វាគឺជាតួនាទីរបស់គ្រូបង្រៀន ដែលបានកំណត់របៀបដាក់ចេញនៃខ្លឹមសារ ឬកម្រិតវិសាលភាពនៃការចូលរួមរបស់សិស្សចំពោះជម្រើសនៃសកម្មភាពសិក្សា និងសម្ភារៈរៀន។ Genesis Framework, World Press (2014) បានអះអាងបន្ថែមទៀតថា សមត្ថភាពគ្រូបង្រៀនមានគុណភាព អាស្រ័យលើការរួមផ្សំផ្សេងៗគ្នា ដូចជា ចំណេះដឹងខ្លឹមសារ ចំណេះដឹងការលើកទឹកចិត្តសិស្ស បទបង្ហាញ និងជំនាញពាក់ព័ន្ធផ្សេងៗ។ The Centre for Teaching Support and Innovation University of Toronto (2014) បានគូសបញ្ជាក់ផ្នែកសមត្ថភាពដែលគ្រូបង្រៀនគួរតែមាន គឺមានដូចតទៅ៖

១. ភាពទទួលបានជោគជ័យក្នុងការលើកទឹកចិត្ត និងជំរុញទឹកចិត្តសិស្ស និងលើកកម្ពស់ដល់ការអភិវឌ្ឍន៍ផ្នែកបញ្ញារបស់សិស្ស និងលទ្ធផលនៃការសិក្សារបស់ពួកគេ។

២. ជំនាញក្នុងការទំនាក់ទំនងល្អ។

៣. ភាពទទួលបានជោគជ័យក្នុងការអភិវឌ្ឍន៍ ការចេះស្ទាត់ជំនាញរបស់និស្សិតនិងការអភិវឌ្ឍន៍នៃការសិក្សាថ្មីៗរបស់សិស្សនៅក្នុងការសិក្សា។

៤. ការលើកកម្ពស់គុណភាពនៃការសិក្សា។

៥. ជំនាញបង្រៀនដ៏ល្អបំផុត។

៦. ការច្នៃប្រឌិត ប្រកបដោយជោគជ័យក្នុងវិស័យបង្រៀនរួមទាំងការបង្កើតថ្មី និងការបង្កើតថ្មីនៃដំណើរការបង្រៀន សម្ភារៈបង្រៀន និងទម្រង់នៃការវាយតម្លៃ។

៧. ការរួមចំណែកដ៏សំខាន់ចំពោះការផ្លាស់ប្តូរគរុកោសល្យក្នុងវិន័យ។

Brindley (1995) បញ្ជាក់ថា គ្រូបង្រៀនភាសាអង់គ្លេសល្អ ត្រូវដឹងអំពីខ្លឹមសារបង្រៀន។ គ្រូបង្រៀន ត្រូវតែចេះអំពីមុខវិជ្ជា យកល្អត្រូវចេះឱ្យលើសពីខ្លឹមសារដែលខ្លួនរំពឹងទុកថានឹងបង្រៀន។ គ្រូបង្រៀន គួរតែមានចំណេះដឹងជាសារវ័នដ៏រឹងមាំ នៅក្នុងមុខវិជ្ជាពាក់ព័ន្ធនឹងជំនាញរបស់ខ្លួន។ គ្រូបង្រៀន ដែលមិនមានជំនាញ ឬសមត្ថភាពក្នុងភាសាអង់គ្លេសមិនត្រូវបង្រៀនភាសាអង់គ្លេសទេ។ the American Speech Hearing Association (2014) ក្រើនរំលឹកថា ប្រសិនបើ អ្នកមិនអាចប្រើភាសាបានល្អ អ្នកមិនគួរបង្រៀនវាទេ។ ការបង្រៀន និងការរៀនភាសាអង់គ្លេស អាចជះឥទ្ធិពលលើការបង្រៀន និងមិនអាចសម្រេចបាននូវសមិទ្ធផល និងស្តង់ដារនៃមុខវិជ្ជាផ្សេងៗទៀតទាំងអស់ ប្រសិនបើ គ្រូបង្រៀន មិនមានសមត្ថភាព។ជំនាញរបស់គ្រូ ត្រូវបានពង្រឹងដោយគុណភាពអប់រំ និងការបណ្តុះបណ្តាលវិជ្ជាជីវៈរបស់គ្រូបង្រៀន។ Kembo-Sure (1992) បានមើលស្តង់ដាររបស់គ្រូបង្រៀន ដែលជាហេតុផលមួយក្នុងចំណោមហេតុផលសម្រាប់ការបង្រៀន និងការអនុវត្តន៍ភាសាអង់គ្លេសនៅសាលាបឋមសិក្សា។ Barasa (2005) បានលើកឡើងពីការស្រាវជ្រាវមួយ ដែលត្រូវបានគេរាយការណ៍ថា ការបង្រៀន និងការរៀនភាសាអង់គ្លេសកំពុងតែត្រូវបានទទួលរងបញ្ហាប្រឈម ដោយសារតែ កង្វះខាតគំរូសម្រាប់អ្នកសិក្សាភាសា។ ការប្រើប្រាស់ភាសាអង់គ្លេសនៅមានកម្រិតខ្សោយនៅតាមសាលារៀន ហើយត្រូវបានស្តីបន្ទោសទៅលើគ្រូបង្រៀន។ ថ្វីបើ មនុស្សជាច្រើនបានចូលប្រឡូកក្នុងអាជីបនៃការបង្រៀនក៏ដោយ គ្រូបង្រៀនភាគច្រើនកម្រយកចិត្តទុកដាក់ទៅលើអាជីបរបស់ខ្លួនណាស់។ គ្រូបង្រៀន មិនត្រូវយកមុខវិជ្ជាជីវៈ

បង្រៀនជារមណីយដ្ឋានចុងក្រោយរបស់ខ្លួន គឺដោយសារតែ មិនមានឱកាសផ្សេងទៅកន្លែងផ្សេងសម្រាប់ខ្លួនដើម្បីជ្រើសរើសឡើយ។ មានតែគ្រូបង្រៀន ដែលមានជំនាញភាសាអង់គ្លេសទេ ទើបអាចប្រើវិធីសាស្ត្របង្រៀន និងរៀនសមស្របជួយឱ្យសិស្សចេះរៀនបានល្អ។ គ្រូបង្រៀនទាំងនេះ បានផ្តល់ឱកាសក្នុងថ្នាក់រៀន ដើម្បីឱ្យសិស្សរបស់ពួកគេ ចូលរួមក្នុងទំនាក់ទំនងជាមួយជីវិតពិតរបស់ពួកគេ។ Kohli (1992) បានលើកឡើងថា ភាសាអង់គ្លេស គឺជាមុខជំនាញ ដែលក្នុងនោះ ទាំងអស់សិស្ស អាចទទួលបានជោគជ័យក្នុងការរៀនភាសាអង់គ្លេស ប្រសិនបើ ពួកគេបានចូលរួមយ៉ាងសកម្មដំណើរការបង្រៀននិងរៀនដែលគេបានរៀបចំ។ គ្រូបង្រៀនដែលមានជំនាញ និងចំណេះដឹងភាសាអង់គ្លេស អាចអនុវត្តជំនាញ ភាពជាអ្នកដឹកនាំដោយការទទួលខុសត្រូវផ្ទាល់ខ្លួន ចំពោះការរៀនសូត្ររបស់សិស្សគ្រប់រូបនៅក្នុងសាលារៀន ហើយពួកគាត់ ពិតជាមានទំនួលខុសត្រូវចំពោះទង្វើ និងការគ្រប់គ្រងចំពោះសិស្ស។ មិនមែនគ្រូបង្រៀន មិនចេះនិយាយភាសាអង់គ្លេសទេ សូម្បីតែនៅក្នុងថ្នាក់រៀន។ គ្រូបង្រៀនដែលមានសមត្ថភាព បានជម្រុញសិស្សទាំងអស់ឱ្យរៀន និងធ្វើឱ្យប្រាកដថា សិស្សត្រូវចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការបង្រៀននិងរៀន។ យោងតាម Quist (2000) ការសរសើរ និងលើកទឹកចិត្តពិតប្រាកដ គឺជាវិធីសាស្ត្រដែលអាចត្រូវបានប្រើ ដើម្បីលើកទឹកចិត្តអារម្មណ៍នៃទំនុកចិត្ត និងសមិទ្ធផលចំពោះអ្នកសិក្សា។ គាត់បាននិយាយថា ការធ្វើបែបនេះ ធ្វើឱ្យឥរិយាបថប្រសើរឡើង និងផ្លាស់ប្តូរអាកប្បកិរិយារបស់អ្នកសិក្សា។ គ្រូបង្រៀនដែលមានសមត្ថភាពភាសាអង់គ្លេស ចេះកំណត់ពីរបៀបបង្ហាញខ្លឹមសារប្រធានបទ និងវិសាលភាពនៃការចូលរួម និងជម្រើសរបស់អ្នកសិក្សានៃការបង្រៀន និងការរៀន។ វាគឺសំខាន់ណាស់ដែលត្រូវធ្វើការសម្រេចចិត្តទុកជាមុនថា ថាតើត្រូវប្រើវិធីសាស្ត្រដូចម្តេច ដើម្បីបង្រៀនត្រូវសិស្សឱ្យឆាប់យល់។ គ្រូបង្រៀន ត្រូវតែគិតអំពីចំណេះដឹងសិស្ស ខាងបរិស្ថាន និងគោលដៅសិក្សារបស់ពួកគេ ក៏ដូចជាកម្មវិធីសិក្សាស្តង់ដារដែលបានកំណត់ដោយក្រសួងអប់រំ ឬនាយកដ្ឋានបណ្តុះបណ្តាល ឬអាជ្ញាធរពាក់ព័ន្ធ។ យុទ្ធសាស្ត្រទាំងនេះ អាចជាត្រូវបានបង្កើតឡើង ដើម្បីលើកកម្ពស់ខ្លឹមសារ ចំណេះដឹង ការគិតដោយប្រឌិតញាណ បំណិនរកដោះស្រាយបញ្ហាចំពោះអ្នកសិក្សា។ គ្រូបង្រៀនដែលមានសមត្ថភាពភាសាអង់គ្លេស ក៏អាចកែប្រែយុទ្ធសាស្ត្របង្រៀននិងរៀនផងដែរ ទំនាក់ទំនងជាមួយភាពជោគជ័យរបស់សិស្ស កែប្រែផែនការ និងវិធីសាស្ត្របង្រៀនជាលំដាប់។ គ្រូជំនាញ

បានជួយបង្កើនការវាយតម្លៃ ប្រកបដោយប្រសិទ្ធភាពលើសិស្ស។ ជាទូទៅ គ្រូបង្រៀនបានដាក់ចេញនូវវិធីសាស្ត្រប្លែកៗគ្នា ដើម្បីវាយតំលៃអ្វីដែលសិស្សបានរៀន។ Kiato (1997) ទទួចថា ការវាយតម្លៃ អាចត្រូវបានប្រើដើម្បីដាក់ពិន្ទុ ពិនិត្យមើលលទ្ធផលនៃការរៀនសូត្ររបស់សិស្ស ផ្តល់មតិយោបល់ដល់សិស្ស និងកែលម្អការណែនាំដោយផ្តល់ព័ត៌មានត្រឡប់ទៅគ្រូ។ ក្រៅពីការវាយតំលៃសិស្សរបស់ពួកគេ គ្រូបង្រៀនទាំងនេះ ក៏អាចវាយតំលៃការងារបង្រៀនខ្លួនឯងបានដែរ។ គ្រូបង្រៀនម្នាក់ប្រកបដោយប្រសិទ្ធភាព គឺជាគ្រូបង្រៀនដែលចេះឆ្លុះបញ្ចាំងខ្លួនឯង។ គ្រូបង្រៀនដែលឆ្លុះបញ្ចាំង គឺជាគ្រូបង្រៀន ដែលចេះវាយតំលៃជំនាញនៃការបង្រៀនរបស់គាត់ ធនធាន និងការអនុវត្តន៍ ក្នុងការចែកចាយក្នុងថ្នាក់រៀន។ គ្រូបង្រៀនទាំងនេះ ឆ្លុះបញ្ចាំងអំពីការអនុវត្តន៍របស់ពួកគេ មានលក្ខណៈជាប្រព័ន្ធ អំពីអ្វី ដែលកើតឡើងនៅក្នុងថ្នាក់រៀន និងសាលារៀន។ ពួកគេ បន្តការស្វែងយល់ទៅលើមូលហេតុដែលជាព្រឹត្តិការណ៍កើតឡើង និងអ្វីៗដែលអាចធ្វើបាន ដើម្បីកែលម្អលើសមិទ្ធផលរបស់សិស្សនៅក្នុងថ្នាក់រៀន។ Davidson (2013) បានទទួចថា គ្រូបង្រៀន ដែលឆ្លុះបញ្ចាំងមានន័យថា គាត់បានបង្ហាញពីឆន្ទៈល្អរបស់ខ្លួនចំពោះសិស្ស។ ពួកគេជឿជាក់ថា កុមារទាំងអស់អាចរៀនសូត្របាន។ការឆ្លុះបញ្ចាំង ជួយឱ្យគ្រូបង្រៀន កំណត់ភាពខ្វះខាតក្នុងការធ្វើផែនការ និងជួយក្នុងការបង្កើតឡើងយុទ្ធសាស្ត្រអន្តរាគមន៍។ McGill និង Beaty (1995) អះអាងថា បើគ្មានការឆ្លុះបញ្ចាំង យើងជាធម្មតាបន្តធ្វើកំហុសដំដែលៗម្តងហើយម្តងទៀត។ គ្រូបង្រៀនដែលមានភាពស្ទាត់ជំនាញក្នុងភាសាអង់គ្លេស ធ្វើឱ្យការបង្រៀនមានភាពប្លែកៗសម្រាប់សិស្សរបស់ពួកគេ ភាពប្លែកៗ ក្នុងការបង្រៀននិងរៀនដែលបានគ្រោងទុកដែលមានលក្ខណៈសមរម្យសម្រាប់សិស្សសាលាចម្រុះ រួមទាំងកុមារ ដែលមានតំរូវការការអប់រំពិសេស និងពិការភាព។ ទោះជាយ៉ាងណាក៏ដោយ កត្តាផ្សេងៗទៀត ប៉ះពាល់ដល់សមត្ថភាពជំនាញរបស់គ្រូបង្រៀនក្នុងថ្នាក់។ មានបញ្ហាមួយចំនួន គួរឱ្យកត់សំគាល់ដូចជា ការខ្វះខាតសម្ភារៈធនធាន ការជ្រៀតជ្រែកភាសាកំណើតភាព ការខ្វះគ្រូបង្រៀន ឥរិយាបថខ្សោយក្នុងចំណោមគ្រូបង្រៀន ទៅលើភាសាអង់គ្លេសដែលខ្វះការហ្វឹកហ្វឺននៅក្នុងការងារ( lack of in-service training) គឺប៉ះពាល់លើការរៀនភាសាអង់គ្លេសនៅក្នុងសាលារៀន។ ការរិះគន់ក្នុងសាលារៀន ត្រូវបានគេកត់សម្គាល់ថា ជាមូលហេតុចំបង សម្រាប់សីលធម៌ទាប ដែលនាំឱ្យមានការបាត់បង់គ្រូបង្រៀននៅក្នុងសាលារៀន។ ប្រសិនបើ បញ្ហាប្រឈមមួយចំនួនមិន

ត្រូវបានដោះស្រាយទេ នោះសមត្ថភាពនៃការបង្រៀន និងការរៀនបានធ្វើឱ្យប៉ះពាល់ដល់គុណភាពនៃការអប់រំ។

## ២.៣.៩ វិធីសាស្ត្របង្រៀននិងរៀនជំនាញភាសាអង់គ្លេស

ការបង្រៀន គឺជាដំណើរការមួយនៃការផ្ទេរ ឬចែករំលែកចំណេះដឹង និងជំនាញដល់អ្នកសិក្សា។ វាជាការផ្តល់ជូនសិស្សតាមរយៈការបង្រៀន និងការណែនាំផ្សេងៗដែលជាប់ពាក់ទងគ្នាជាប្រព័ន្ធ។ វិធីសាស្ត្របង្រៀន ធ្វើឱ្យសិស្សរៀនសកម្មភាពទាំងឡាយដែលបានគ្រោងទុក។ យោងទៅលើ Ngaroga (2007) សកម្មភាពរៀនសូត្រ គឺជាភារកិច្ចដែលសិស្សត្រូវបានរំពឹងថានឹងអនុវត្តក្នុងអំឡុងពេលមេរៀនណាមួយ ដើម្បីសម្រេចបាននូវវត្ថុបំណងដែលបានកំណត់ដោយគ្រូ។ ទាំងនេះ រួមបញ្ចូលសកម្មភាពដូចជា ការសង្កេត ការថតសំលេង ចង្អុលបង្ហាញ ការពិសោធ ការតម្រៀបតាមលំដាប់ ការធ្វើបំណែងចែកចំណាត់ថ្នាក់ ការកត់ត្រា សរសេរ និងគូរគំនូរជាដើម។

វិធីសាស្ត្របង្រៀនធ្វើឡើង ក្នុងគោលបំណងដើម្បីធ្វើឱ្យអ្នករៀនសម្រេចបាននូវវត្ថុបំណងមេរៀន ដោយអនុញ្ញាតឱ្យពួកគេចូលរួមនៅក្នុងដំណើរការសិក្សារៀនសូត្រជាក់ស្តែង និងពិតប្រាកដ។ កុមារបានរៀនសូត្របានល្អ តាមរយៈអនុវត្តជាជាងការរៀននូវអ្វីៗដែលគ្រូបង្រៀនបានអនុវត្តដោយខ្លួនឯងក្នុងការបង្រៀន ដូចនេះ គ្រូបង្រៀនគួរលើកទឹកចិត្តសិស្សឱ្យបានជាប់ពាក់ព័ន្ធ និងចូលរួមយ៉ាងសកម្មតាមរយៈការប្រើឥន្ទ្រីយ៍ទាំងប្រាំរបស់អ្នករៀន ក្នុងការយល់ដឹងអំពីបរិស្ថានរបស់ពួកគេ។ សកម្មភាពបង្រៀន បានលើកទឹកចិត្តភាពច្នៃប្រឌិត និងការរកឃើញរបស់កុមារ។ វិធីសាស្ត្របង្រៀននិងការរៀន អាចធ្វើឱ្យសិស្សទទួលបានចំណេះដឹងនិងជំនាញជាភាសាអង់គ្លេស។ ការស្រាវជ្រាវបានបង្ហាញថា មិនមានវិធីសាស្ត្រណាប្រសើរជាងវិធីសាស្ត្រណាទេ តែសំខាន់ គឺគ្រូផ្លាស់ប្តូរវិធីសាស្ត្រផ្សេងៗគ្នាក្នុងការបង្រៀនភាសាអង់គ្លេសដើម្បីពង្រឹងការរៀនរបស់សិស្ស។ ប៉ុន្តែ មុននឹងជ្រើសរើសយកវិធីសាស្ត្របង្រៀនដែលត្រូវប្រើការសិក្សានេះ សង្កត់ធ្ងន់ថា ដំបូងគ្រូត្រូវការដើម្បីពិចារណាសិស្សសារតារ ចំណេះដឹង បរិស្ថាន ដែលពួកគេកំពុងតែនឹងរៀនសូត្រនិងគោលបំណងសិក្សារបស់គេ។ Githanga (2007) បានស្នើថា កុមារអាចរៀនភាសាតាមរយៈការបង្រៀនជាផ្លូវការ និងបង្រៀននៅក្នុងថ្នាក់រៀនដូចខាងក្រោមៈ

(១) តាមរយៈការសិក្សាដែលអាចយល់ដឹង និងការបង្រៀនដោយដឹងអំពីទិដ្ឋភាពជាផ្លូវការនៃភាសា។

(២) ការបង្រៀនក្បួនផ្លូវការនៃភាសា ដូចជា ការប្រកបអក្ខរាវិរុទ្ធ រចនាសម្ព័ន្ធវេយ្យាករណ៍ ការរៀនពីន័យធៀប ការអាន ការសរសេរ និងការអនុវត្តន៍តាមអ្វីដែលបានរៀន។ការធ្វើផែនការ គឺជាសកម្មភាពសំខាន់មួយដែលគ្រូត្រូវគិតមុនពេលបង្រៀន។ គ្រូបង្រៀន ដំបូងត្រូវមានផែនការសកម្មភាពដើម្បីបង្រៀន មុនពេលការបង្រៀនពិតប្រាកដត្រូវបានធ្វើឡើង។ MOE (2001) ស្នើសុំថា ការធ្វើផែនការ គឺជាដំណើរការមួយដែលអ្នកបានត្រៀមខ្លួនជាស្រេច ដើម្បីរៀន ឬបង្រៀន និងបានពិចារណាពីអ្វីដែលត្រូវបង្រៀន និងរបៀបបង្រៀនរបស់វា។ គ្រូបង្រៀនដែលបានរៀបចំផែនការ ការងាររបស់ពួកគេ បានធ្វើឱ្យសិស្សរបស់ពួកគេ សម្រេចនូវគោលបំណងមេរៀន។ នេះសកម្មភាពបង្រៀន និងការរៀនដែលបានផ្តល់ចំណេះដឹង និងជំនាញដល់សិស្សមានដូចជា៖

**២.៣.៩.១ សំណេរលើខ្នង** ( Back Writing)

គោលបំណង៖ ដើម្បីសរសេរ និងចំណាំអក្សរ និងពាក្យ។

១)សិស្សទី១៖ សរសេរអក្សរមួយតួរនៅលើខ្នងរបស់សិស្សទី២។

២)សិស្សទី២៖ ទាយអក្សរ ឬពាក្យនោះ។

**២.៣.៩.២ ល្បែងបោះបាល់** ( Ball Game)

គោលបំណង៖ ដើម្បីហាត់និយាយសំណង់ប្រយោគថ្មីៗ។សកម្មភាពនេះអាចធ្វើនៅខាងក្រៅថ្នាក់រៀនដោយប្រើបាល់ពិតប្រាកដ ឬធ្វើនៅក្នុងបន្ទប់រៀនដោយប្រើបាល់ធ្វើក្រដាស។

១) ក្រុមនីមួយៗ ឈរជារង្វង់។ឱ្យបាល់១ទៅសិស្សណាម្នាក់ក្នុងក្រុមនីមួយៗដើម្បីចាប់ផ្តើមសកម្មភាព។

២) សិស្សដែលបានបាល់និយាយថា Hello, my name is Ben (សំណង់ប្រយោគថ្មី) រួចសួរថា What is your name? (សំណង់ប្រយោគថ្មី )មុននឹងបោះបាល់ឱ្យសិស្សម្នាក់ទៀត។

៣) សិស្សដែលចាប់បានបាល់ ឆ្លើយថា Hello, my name is …….(សំណង់ប្រយោគថ្មី) និងបន្តសួរ(សំណង់ប្រយោគថ្មី) មុននឹងបោះបាល់ទៅឱ្យសិស្សផ្សេងទៀត។

**២.៣.៩.៣ សណ្ឋានពាក្យ** ( Body Shapes )

គោលបំណង៖ ដើម្បីស្គាល់បានថា អក្សមួយចំនួនខ្ពស់ ហើយអក្សរមួយចំនួនទៀត សរសេរទៅតាមបន្ទាត់។ពន្យល់ថា អក្សរមួយចំនួន គឺតូច a អក្សរមួយចំនួនទៀតខ្ពស់ t ហើយមួយចំនួនទៀតសរសេរនៅក្រោមបន្ទាត់ g។

១) ជ្រើសរើសពាក្យដែលអ្នកចង់យកមកអនុវត្ត។គូរសណ្ឋាននៃពាក្យនោះនៅលើក្ដារខៀន។

២) សិស្សសរសេរពាក្យនៅលើក្ដារឆ្នួនរៀងៗខ្លួន។

៣) ឱ្យសិស្សម្នាក់ឡើងលើក្ដារខៀនដើម្បីសរសេរអក្សរចូលក្នុងសណ្ឋានពាក្យដែលបានគូរ។

**២.៣.៩.៤ ល្បែងប្រាជ្ញាពាក្យ** ( Cross Word )

គោលបំណង៖ ដើម្បីអានព័ត៌មានជំនួយ ហើយប្រកបពាក្យជាចម្លើយឱ្យបានត្រឹមត្រូវ។ នៅក្នុងល្បែង ( Cross Word) ពាក្យទាំងអស់នេះត្រូវជាប់គ្នា។ ពាក្យខ្លះកាត់ទទឹង ពាក្យខ្លះទៀតចុះក្រោម។

១) នៅខាងដើមនៃពាក្យនីមួយៗតែងតែមានលេខ។ លេខនេះ ត្រូវជាប់ជាមួយគ្នា និងព័ត៌មានជំនួយ។

២)ចូរអានព័ត៌មានជំនួយ។ លេខបន្ទាប់ពីព័ត៌មានជំនួយ ប្រាប់ថាមានចំនួនប៉ុន្មានអក្សរនៅក្នុងចម្លើយ។

៣) ចូរសរសេរចម្លើយចូលក្នុងតារាង។ជួនកាលអាចមានចម្លើយលើសពីមួយ ប៉ុន្តែចម្លើយត្រូវតែជាពាក្យមួយ។

### ២.៣.៩.៥ លុប និងចងចាំ (Erase and Remember):

គោលបំណង៖ ដើម្បីចងចាំ និងសរសេរពាក្យថ្មីៗ ឬរំលឹកពាក្យដែលបានរៀនរួចហើយឡើងវិញ។

១) គូររូប ឬបិទរូបនៅលើក្ដារខៀន រួចសរសេរពាក្យនៅក្បែរនឹងរូបនោះ។

២) សិស្សហាត់អាន និងប្រកបពាក្យទាំងនេះទាំងអស់គ្នា។

៣) លុបពាក្យមួយចេញពីក្ដាខៀន។ ចង្អុលទៅរូបភាពមួយរួចសួរថា What is this? សិស្សនិយាយពាក្យនោះ និងសរសេរពាក្យនោះ នៅលើក្ដារឆ្នួនរបស់ពួកគេរៀងៗខ្លួន។

៤) ផ្ទៀងផ្ទាត់មើលថាតើត្រឹមត្រូវដែរ ឬទេ?

៥) ធ្វើដូចនេះរហូតដល់ពាក្យទាំងអស់ត្រូវបានលុបចេញពីក្ដារខៀន។

### ២.៣.៩.៦ ពាក្យអាថ៌កំបាំង (Hidden Words)

គោលបំណង៖ ដើម្បីអានពាក្យដោយការដោះស្រាយប្រស្នា។

១) ពន្យល់សិស្សថា ពួកគេត្រូវស្វែងរកពាក្យអាថ៌កំបាំង។

២) គូរតារាងមួយនៅលើក្ដារខៀន ហើយសរសេរអក្សរ ៩តួនៅក្នុងក្រឡានីមួយ ត្រូវជ្រើសរើសអក្សរដោយប្រុងប្រយ័ត្ន ព្រោះអក្សរទាំងនោះត្រូវតែអាចប្រកបបញ្ចូលគ្នា ដើម្បីបង្កើតជាពាក្យដែលសិស្សបានចេះរួចហើយ។

### ២.៣.៩.៧ ពាក្យ និងប្រយោគដែលមានអក្សរមិនត្រូវតាមលំដាប់ Jumbled Words and Sentences

គោលបំណង: ដើម្បីចំណាំលំដាប់អក្សរនៅក្នុងពាក្យមួយ និងចំណាំលំដាប់ពាក្យនៅក្នុងប្រយោគមួយឱ្យបានត្រឹមត្រូវ។

១)សរសេរពាក្យ ឬប្រយោគដែលមានអក្សរ ឬពាក្យមិនត្រូវតាមលំដាប់មួយចំនួននៅលើក្ដារខៀន។

២) សិស្សសរសេរនៅលើក្ដារខៀន ឬនៅក្នុងសៀវភៅសរសេររបស់គេឱ្យបានត្រឹមត្រូវឡើងវិញ។

៣) ផ្ទៀងផ្ទាត់។

### ២.៣.៩.៨ ការសម្ដែងល្ខោន ( Dramatization )

បន្ទាប់ពីការបង្រៀនមុខវិជ្ជាភាសា ថ្នាក់រៀន អាចត្រូវបានណែនាំឱ្យចេះសំដែងល្ខោន(dramatize) ដោយប្រើពាក្យដែលពួកគេបានរៀនក្នុងអត្ថបទ។ ក្មេងៗដែលមានវ័យប្រហាក់ប្រហែលគ្នា ចូលចិត្តចូលរួមក្នុងសកម្មភាពសំដែង។ ឧទាហរណ៍៖ រឿងល្ខោនដើរតួនាទីជាម្ដាយឬឪពុក។ ល្ខោន គឺជាប្រភេទនៃការដើរតួរ លេងតួរសំដែង។ Gutumbi និង Wasembe (2001) អះអាងថា ការសំដែងល្ខោន ជាទូទៅពាក់ព័ន្ធនឹងការប្រាស្រ័យទាក់ទងដោយផ្ទាល់មាត់ និងសកម្មភាពដែលជួយដល់អ្នកសិក្សាក្នុងការអភិវឌ្ឍន៍ជំនាញនិយាយ។ ការស្វែងមតិ គឺជាសកម្មភាពដែលកុមារផ្ដោតការយកចិត្តទុកដាក់លើការសិក្សា ព្រោះកុមាររៀនសូត្រតាមរយៈការធ្វើ ឬការអនុវត្តន៍ជាក់ស្ដែង។ តាមរយៈរឿងល្ខោន កុមារបានអភិវឌ្ឍជំនាញនិយាយ និងប្រើពាក្យថ្មី ដែលពួកគេបានរៀនក្នុងមេរៀន។ ការធ្វើត្រាប់តាម ការអនុវត្តន៍ដដែលៗ និងការហ្វឹកហាត់វិធីសាស្ត្របង្រៀនភាសាអង់គ្លេស អាចត្រូវបានពង្រឹងតាមរយៈការសំដែងរឿង។ មុនពេលដែលកុមារបានសំដែងសកម្មភាពរឿងមួយ គ្រូបង្រៀន រៀបចំថ្នាក់រៀនបានគ្រប់គ្រាន់សម្រាប់សកម្មភាព។ គ្រូបង្រៀន បានផ្ដល់នូវគំរូដ៏ល្អបំផុត សម្រាប់អ្នកសិក្សាដើម្បីធ្វើតាមឈុតឆាកនៃរឿងល្ខោន។

### ២.៣.៩.៩ វិធីនិទស្សន៍ ( Demonstration Method )

Ngaroga (2007) និយាយថា វិធីបែបនិទស្សន៍ គឺជាទម្រង់ជាក់ស្ដែងនៃការរៀនសូត្រតាមរយៈ ការត្រាប់តាមគ្រូបង្រៀន ផ្ដល់នូវការចង្អុលបង្ហាញជាច្រើនអំពីប្រតិបត្តិការពេញលេញជាមួយនឹងការពន្យល់។ វិធីសាស្ត្រនេះ ការរៀនសូត្រនេះគឺមាននិរន្តរភាពដើម្បីពង្រឹងអ្វីដែលសិស្សបានរៀន។ មុននឹងគ្រូបង្រៀនប្រាប់សិស្សឱ្យចង្អុលបង្ហាញអ្វីមួយ គ្រូបង្រៀន អាចផ្ដល់ឱ្យសិស្សនូវរូបភាពច្បាស់លាស់អំពីអ្វីដែលពួកគេអាចធ្វើបាននៅចុង

បញ្ចប់មេរៀន។ ការធ្វើត្រាប់តាម ការនិយាយឡើងវិញ និងការហ្វឹកហាត់វិធីសាស្ត្របង្រៀនភាសាអង់គ្លេស ក៏អាចត្រូវបានពង្រឹងតាមរយៈការចង្អុលបង្ហាញប្រាប់។

**២.៣.៩.១០ វិធីសាស្ត្រចោទសំណួរ** ( Questioning )

វិធីសាស្ត្រនៃការបង្រៀននេះ អាចត្រូវបានប្រើ ដើម្បីបំផុសការចាប់អារម្មណ៍លើអ្នកសិក្សា។ វាផ្តោតការយកចិត្តទុកដាក់របស់សិស្ស ទៅនឹងការរៀនសូត្រនៅដើមមេរៀនមួយ។ បច្ចេកទេសនៃការសួរសំណួរ គឺជាផ្នែកសំខាន់មួយក្នុងចំណោមវិធីសាស្ត្របង្រៀនដែលគ្រូបង្រៀនប្រើនៅក្នុងដំណើរការបង្រៀននិងរៀន។ វាបានធ្វើឱ្យការរៀននៃព័ត៌មានថ្មីកាន់តែមានន័យចំពោះអ្នកសិក្សា។ បច្ចេកទេសសាកសួរ ធ្វើឱ្យអ្នកសិក្សាចូលរួមយ៉ាងសកម្មនៅក្នុងមេរៀន និងជាទូទៅ បានកំណត់ភាពជោគជ័យនៃមេរៀនមួយ។

**២.៣.៩.១១ វិធីបែបស្រាវជ្រាវ** Discovery method of teaching

ដោយយោងទៅលើ Bruner (1961) វិធីសាស្ត្រនេះ បានជួយឱ្យកុមាររៀនសូត្រពីវិធីរៀនដោយខ្លួនឯង ព្រោះវាផ្តល់ដល់អ្នកសិក្សានូវ ការរៀនសូត្រដោយផ្សារភ្ជាប់ទៅនឹងបទពិសោធន៍ថ្មីរបស់ខ្លួន ក្នុងអំឡុងពេលការអនុវត្តន៍សកម្មភាព និងទំនាក់ទំនងជាមួយអ្នកដទៃកុមារ និងជាមួយមនុស្សពេញវ័យ កុមារបានរៀនវាក្យស័ព្ទភាសាអង់គ្លេសថ្មី ដែលពួកគេប្រើក្នុងជីវិតប្រចាំថ្ងៃរបស់ពួកគេ។

**២.៣.៩.១២ វិធីបែបគំរោង** ( Project Method )

Project Method គឺជាវិធីសាស្ត្របង្រៀនដ៏ទំនើបមួយ ដែលការបង្រៀនខ្លឹមសារផ្អែកទៅលើបទពិសោធន៍ និងស្ថានភាពនៃជីវិតជាក់ស្តែង ដើម្បីសម្រេចបាននូវចំណេះដឹងរបស់សិស្ស។ វិធីសាស្ត្រនេះ ផ្អែកទៅលើទស្សនៈវិទ្យា Pragmatism ហើយនិងគោលការណ៍ " ការរៀនដោយការអនុវត្តន៍ " ។ ដោយយោងទៅលើ William Heard Kilpatrick ( 1918) Project Method គឺ គោលបំណងសកម្មភាព ផ្តោតលើអ្វីដែលកើតមានក្នុងបរិស្ថានសង្គម និងបទពិសោធន៍របស់សិស្ស។ គ្រូបង្រៀន អាចបញ្ចូលការសិក្សាអំពីស្ថានភាពជាក់ស្តែងដោយក្រុមមួយ ហើយក្រុមនោះ ស្ថិតក្រោមការណែនាំរបស់គ្រូបង្រៀន។ ជាឧទាហរណ៍ ពេលយើងបង្រៀនអំពីផ្ទះរបស់យើង ស្នើសុំឱ្យសិស្សសរសេរអ្វីដែលពួកគេ

មាននៅផ្ទះរបស់ពួកគេ។ កុមារ អាចត្រូវបានស្នើសុំឱ្យបង្កើត និងរៀបចំផ្ទះរបស់ពួកគេឱ្យជាផ្ទះគំរូ។ រាល់របស់របរអ្វីៗដែលមាន ពួកគេនឹងសរសេរឈ្មោះ។ ទាំងនេះគួរតែរួមបញ្ចូលឧទាហរណ៍ សមាជិកគ្រួសារ និងអ្វីៗផ្សេងៗទៀតដូចជា សត្វគោ ផ្ទះ។ ដើមឈើ។ល។ តាមរយៈ Project Method កុមារអាចបង្កើនវាក្យស័ព្ទរបស់ពួកគេ។

### ២.៣.៩.១៣ វិធីឧទ្ទេស ( Lecture Method )

នេះពាក់ព័ន្ធនឹងការផ្តល់ព័ត៌មាន ដែលគ្រូបង្រៀនមានបំណងទំនាក់ទំនងទៅសិស្សរបស់គាត់ក្នុងថ្នាក់។ ថ្វីបើ គ្រូបង្រៀនដើរតួនាទីយ៉ាងសំខាន់ ក្នុងវិធីសាស្ត្របង្រៀនក៏ដោយ វិធីសាស្ត្រនេះ អាចមានប្រយោជន៍ ប្រសិនបើ គ្រូបង្រៀនសង្ឃឹមថា នឹងធ្វើឱ្យសិស្សមានភាពសាទរក្នុងការរៀនសូត្រទៅលើប្រធានបទដែលគ្រូផ្តល់ឱ្យ។ វិធីសាស្ត្រនេះ សំដៅលើការពន្យល់ ឬការធ្វើបទបង្ហាញខ្លឹមសារមេរៀន ឬប្រធានបទទៅកាន់សិស្សតាមរយៈកាយវិការ សម្ភារៈជំនួយងាយៗ ការលើកដាក់សំលេង ការផ្លាស់ប្តូរទីតាំងឈរ ការប្រើទឹកមុខជាដើម ហើយគ្រូ ព្យាយាមសួរសំណួរដើម្បីរក្សាការទាក់ទាញ ឬរក្សាបំរុងប្រយ័ត្នរបស់សិស្ស។

### ២.៣.៩.១៤ វិធីបែបចលនា ( Total Physical Response )

វិធីសាស្ត្របង្រៀននេះ ត្រូវបានបង្កើតឡើងដោយ Dr J. Asher។ វិធីសាស្ត្រនេះ វាមានប្រយោជន៍បំផុត សម្រាប់សិស្សនៅកម្រិតបឋមសិក្សា។ សិស្សស្តាប់ការបង្រៀនរបស់គ្រូ ហើយអនុវត្តតាមដោយការហ្វឹកហាត់ភ្លាមៗតាមរយៈការចង្អុលបង្ហាញ កាយវិការ និងចលនារាង្គកាយ។

### ២.៣.៩.១៥ វិធីត្រាប់ភាសា ( The Audio – Lingual Method )

ដោយយោងទៅលើ Fries (1945)និង Rivers (1964) វាគឺជាវិធីសាស្ត្របង្រៀនដែលមានឥទ្ធិពលបំផុតនៅក្នុងថ្នាក់រៀន។ វាមានគោលបំណងបង្កើតទម្លាប់ល្អ តាមរយៈការស្តាប់ដោយយកចិត្តទុកដាក់របស់សិស្ស ហើយអនុវត្តតាមគំរូសន្ទនាខ្លី និយាយឡើងវិញនូវអ្វីដែលបានឮ ថាតាមឡើងវិញ ហ្វឹកហាត់ ធ្វើត្រាប់តាម ពង្រឹងឡើងវិញ តាមរយៈការស្តាប់របស់សិស្ស ដោយគ្រូពន្យល់តិចតួចបំផុត។

### ២.៣.៩.១៦ ការច្រៀង ឬចំរៀង ( Singing  or Songs )

នេះគឺជាវិធីសាស្ត្រដ៏មានប្រយោជន៍មួយ ដើម្បីពង្រឹងនូវអ្វីដែលកុមារបានរៀន។ នេះគឺជាសកម្មភាពដ៏គួរឱ្យរំភើប  ជាពិសេសសម្រាប់កុមារនៅថ្នាក់បឋម។  ឧទាហរណ៍  កុមារអាចត្រូវបានធ្វើឡើងវិញ ដើម្បីច្រៀងផ្នែកខ្លះរាងកាយរបស់ពួកគេ ថ្ងៃនៃសប្តាហ៍  ខែនៃឆ្នាំជាដើម។

### ២.៣.៩.១៧ ការនិទានរឿង ( Story-telling )

សកម្មភាពនេះ       ក៏ទាក់ទាញចំណាប់អារម្មណ៍ដល់អ្នកសិក្សាផងដែរ។ គ្រូបង្រៀនអាចប្រាប់កុមារឱ្យនិទានរឿង ពីរឿងផ្សេងទៀតអំពីសង្គម ឬព្រៃណើ។ ការនិទានរឿង បានជួយអ្នករៀនបង្កើតវាក្យស័ព្ទជាភាសាអង់គ្លេស។

### ២.៣.៩.១៨ តួរសំដែង Role-play

Gutumbi និង Wasembe (2001) និយាយថា ការសម្តែង គឺជាសកម្មភាពមួយដែលពាក់ព័ន្ធនឹងកម្រិតនៃការអត់ធ្មត់។ វាពាក់ព័ន្ធនឹងអ្នកចូលរួមដែលធ្វើអន្តរកម្ម ដូចជា ខ្លួនឯង ឬមនុស្សដទៃទៀតក្នុងស្ថានភាពស្រមើលស្រមៃ។ ប៉ុន្តែ MoEST (2006) ព្រមានថា គ្មានគ្រូបង្រៀនណា បង្ខំក្មេងៗឱ្យធ្វើអ្វីដែលពួកគេមិនទាន់ត្រៀមខ្លួននៅឡើយទេ។ គ្រូបង្រៀន ត្រូវមានភាពច្នៃប្រឌិត និងប្រើវិធីសាស្ត្របង្រៀន ជាច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីលើកកម្ពស់ការរៀនសូត្រចំពោះសិស្សរបស់ពួកគេ។  គ្រូបង្រៀនដែលមានប្រសិទ្ធិភាពមិនអាស្រ័យលើវិធីសាស្ត្របង្រៀននិងការរៀនសូត្រទេ។ វិធីសាស្ត្របង្រៀនសមរម្យ គឺជាវិធីមួយដែលពាក់ព័ន្ធនឹងអ្នកសិក្សាក្នុងការរៀនពិត  និងធ្វើឱ្យកុមារ  សម្រេចបាននូវគោលដៅមេរៀន។ ទោះជាយ៉ាងណាក៏ដោយ Githanga (2007) ក៏ព្រមានថា ភាសាទីពីរ គឺល្អបំផុតរៀននៅក្នុងបរិយាកាសមួយដោយគ្មានភាពតានតឹង  ដែលមិនសង្កត់ធ្ងន់ទៅលើការប្រលងខ្លាំងនោះទេ។ លទ្ធផល ដែលឃើញមានគោលបំណងជ្រើសរើស និងរៀបចំសកម្មភាពរៀនសូត្រពីគ្រូបង្រៀនភាសាអង់គ្លេសក្នុងការបង្រៀនការសរសេរ       ជាដំណើរការនៅសាលាមធ្យមសិក្សា។ ខណៈពេល  លទ្ធផលដែលឃើញនៃការសិក្សានេះ  ផ្តល់នូវការយល់ដឹងទៅនឹងការសិក្សាដែលបានស្នើឡើងបានស្វះស្វែង ដើម្បីត្រួតពិនិត្យផលប៉ះពាល់នៃការបង្រៀនភាសាអង់គ្លេសនៅសាលារៀនបឋមសិក្សា។

## ២.៣.១០ ការវាយតម្លៃលើលទ្ធផលសិក្សាភាសាអង់គ្លេសរបស់សិស្សនៅបឋមសិក្សា

ការវាយតម្លៃលទ្ធផលសិក្សា គឺជាវិធីមួយដែលធ្វើឡើងក្នុងគោលបំណង ប្រមូលរាល់ព័ត៌មានជុំវិញការអនុវត្តន៍របស់សិស្សពាក់ព័ន្ធទៅនឹងការសិក្សា ដើម្បីវាស់ស្ទង់ការយល់ដឹងរបស់សិស្ស និងក្នុងគោលបំណង ឆ្លុះបញ្ចាំងត្រឡប់លើលទ្ធផលនៃវិធីសាស្ត្របង្រៀនរបស់គ្រូ។ ការវាយតម្លៃលទ្ធផលការសិក្សារបស់សិស្ស ត្រូវបានគេបែងចែងជាពី ការវាយតម្លៃជាដំណាក់ និងការវាយតម្លៃបូកសរុប[19]៖

### ២.៣.១០.១ ការវាយតម្លៃតាមដំណាក់កាល

ការវាយតម្លៃតាមដំណាក់កាល គឺជាការវាយតម្លៃធ្វើឡើងកំឡុងពេល ឬក្នុងតំណើរការនៃការបង្រៀនសិស្សក្នុងវគ្គសិក្សា ក្នុងគោលបំណងពង្រឹងសមត្ថភាព ជំនាញ និងការយល់ដឹងរបស់សិស្ស ដើម្បីឱ្យការសិក្សាកាន់តែរីកចំរើន។

### ២.៣.១០.២ ការវាយតម្លៃបូកសរុប

ការវាយតម្លៃបូកសរុប គឺជាវាយតម្លៃ ធ្វើឡើងនៅពេលបញ្ចប់មេរៀន ឬបញ្ចប់វគ្គសិក្សា ប្រចាំខែ ឬបញ្ចប់ឆ្នាំ ក្នុងគោលបំណងចង់ដឹងថា តើសិស្សសម្រេចបានតាមគោលបំណងនៃមេរៀននីមួយៗ ឬមេរៀនទាំងមូលដែលបានកំណត់ទុកក្នុងវគ្គសិក្សាឬទេ។

ការវាយតម្លៃនៃលទ្ធផលសិក្សាត្រូវបានធ្វើឡើង តាមរយៈការធ្វើតេស្តសរសេរ តេស្តសួរផ្ទាល់មាត់ ការប្រឡងប្រចាំខែ ប្រចាំឆមាស ប្រចាំឆ្នាំ ការសម្ភាសន៍ ផ្តល់ព័ត៌មានត្រឡប់ ការផ្តល់ពិន្ទុជាតួលេខ ឬនិទ្ទេស ការធ្វើការងារជាក្រុម ធ្វើកិច្ចការផ្ទះ កម្រងស្នាដៃសិស្ស កិច្ចការដែលបម្រើឱ្យការរៀនសូត្រផ្សេងៗ។

[19] Language Assessment: Principles and Classroom Practices ( Brown & Abeywickrama,2010)

នៅតាមសាលាបឋមសិក្សាចំណោះទូទៅ ការកំណត់ពិន្ទុ គឺត្រូវធ្វើការវាយតម្លៃលើសមាសភាគទាំងបួននៃភាសាអង់គ្លេសគឺ ការស្តាប់ ការនិយាយ ការអាន និងការសរសេរ ដែលពិន្ទុសរុបគឺ ១០ពិន្ទុដូចមុខវិជ្ជាដទៃទៀតដែរ។[20]

# ជំពូកទី៣
# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ដំណើរការនៃការសិក្សាស្រាវជ្រាវ

Chakraborty (2012) និយាយថា ការស្រាវជ្រាវ គឺជាមូលដ្ឋានគ្រឹះនៃវិទ្យាសាស្ត្រ និងការគ្រប់គ្រងការអប់រំ។ ការស្រាវជ្រាវ សំដៅទៅលើការរៀបចំរចនាសម្ព័ន្ធ និងការប៉ុនប៉ងដែលមានគោលបំណងដើម្បីរកឱ្យឃើញ បកស្រាយបង្កើតចំណេះដឹងរបស់មនុស្សនៅលើទិដ្ឋភាពផ្សេងគ្នានៃពិភពលោក ជាមួយនឹងគោលដៅនៃការបង្កើតចំណេះដឹងថ្មីៗ។ Blaikie (2000) និយាយថា ការរចនា គឺដើម្បីរៀបចំផែនការ ដោយហេតុថា ការរចនា គឺជាដំណើរការនៃការសម្រេចចិត្តមុនពេលស្ថានភាពកើតឡើង ហើយការសម្រេចចិត្តនោះ គឺត្រូវតែធ្វើ។ វាគឺជាដំណើរការនៃការប្រមើលមើលដោយចេតនា ដឹកនាំឆ្ពោះទៅរកការនាំមកនូវស្ថានការណ៍ដែលរំពឹងទុក និងការគ្រប់គ្រងលើស្ថានការណ៍នោះ។

ដើម្បីឆ្លើយតបទៅនឹងកម្រងសំណួរស្រាវជ្រាវ និងដើម្បីសម្រេចគោលបំណងនៃការសិក្សាស្រាវជ្រាវ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះ នឹងជ្រើសរើសវិធីសាស្ត្របរិមាណវិស័យ។

សម្រាប់ការសិក្សាស្រាវជ្រាវបរិមាណវិស័យ នឹងប្រើប្រាស់នូវកម្រងសំណួរ ជាទម្រង់ជាក់លាក់ និងតាមលំដាប់លំដោយ។

រាល់កម្រងសំណួរស្រាវជាវ ត្រូវបានរៀបចំឡើងសម្រាប់សមាសភាគគោលដៅដែលចូលរួមចំនួនបីក្រុមៈ ១) គណៈគ្រប់គ្រងសាលារៀន ២) លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សាចំណេះទូទៅនៅកម្រិតថ្នាក់ទី៤ ទី៥ និងទី៦ ៣) សិស្សានុសិស្សដែលរៀននៅសាលាបឋមសិក្សាគោលដៅ។ ការសិក្សាស្រាវជ្រាវ នេះត្រូវបានធ្វើឡើងនៅក្នុងខេត្តតាកែវ ដែលមានស្រុកគោលដៅចំនួន៣ ក្នុងចំនោមស្រុកទាំង ០៩ស្រុក នៅស្ថិតនៅក្នុងខេត្តទាំងមូល។ នៅក្នុងនោះដែរ មានសាលាបឋមសិក្សាចំណេះដឹងទូទៅគោលដៅចំនួន០៩ ដែលត្រូវជ្រើសរើសពីស្រុកនិងក្រុងចំនួន០៣ នៅក្នុងខេត្តតាកែវ។ ក្រុងដូនកែវ រួមមានសាលាបឋមសិក្សាតាកែវក្រុង សាលាបឋមសិក្សាអនុវត្ត និង សាលាបឋមសិក្សាក្រចាប់ ។ ស្រុកត្រាំកក់ រួមមានសាលាបឋមសិក្សាអង្គរុន សាលាបឋមសិក្សាអង្គស្លែង សាលាបឋមសិក្សាអង្គមន្ត្រី។ ស្រុកសំរោង រួមមាន សាលាបឋមសិក្សាអង្គប្រិយ៍ សាលាបឋមសិក្សាទួលទ្រា សាលាបឋមសិក្សាខ្សាច់សរ។

## ៣.២ ឧបករណ៍ស្រាវជ្រាវ

អ្នកស្រាវជ្រាវប្រើប្រាស់កម្រងសំណួរដើម្បីប្រមូលទិន្នន័យ។

## ៣.៣ កម្រងសំណួរ

អ្នកស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរដើម្បីប្រមូលទិន្នន័យ។ កម្រងសំណួរទាំងនេះ ត្រូវបានប្រគល់ទៅគ្រូបង្រៀនបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា គណៈគ្រប់គ្រងសាលារៀន និង សិស្សានុសិស្សរៀនថ្នាក់ទី៤ទី៥ទី៦។ Wadsworth (1997) កំណត់កម្រងសំណួរ ជាបណ្តុំនៃសំនួរ ដែលបានសរសេរជាលាយលក្ខណ៍អក្សរនៅក្នុងសន្លឹកក្រដាសតែមួយ។ យោងទៅតាម Muituria (2012) កម្រងសំណួរ គឺជាបណ្តុះនៃសំណួរបានបងាញឱ្យអ្នកឆ្លើយផ្តល់ចម្លើយ។ គាត់និយាយថា មានសំណួរជាមូលដ្ឋានចំនួនពីរ សំណួរបិទ(closed-ended questions ) និង សំណួរបើកចំហ ( opened-ended question)។ អ្នកស្រាវជ្រាវ បានផ្តល់ឱ្យអ្នកឆ្លើយ នូវកម្រងសំណួរ ដើម្បីបំពេញដោយខ្លួនឯង។ អ្នកស្រាវជ្រាវ ប្រគល់ជូនកម្រងសំណួរដល់អ្នកឆ្លើយ បន្ទាប់ពីពន្យល់ដល់ពួកគេពីគោលបំណងការនៃការសិក្សា និងមូលហេតុដែលពួកគាត់ចូលរួមនៅក្នុងការសិក្សា។ មុន

នឹងបំពេញកម្រងសំនួរ អ្នកស្រាវជ្រាវ បានធានាចំពោះអ្នកឆ្លើយសំណួរអំពីការរក្សាការសម្ងាត់នៃចម្លើយ។ អ្នកស្រាវជ្រាវ ស្នើសុំពេលវេលាដើម្បីបំពេញកម្រងសំណួរ និងប្រមូលបន្ទាប់ពីបំពេញវា។ អ្នកស្រាវជ្រាវ បានជ្រើសរើសប្រើកម្រងសំណួរ ដោយយោងទៅតាមសំណួរ Kothari (2003) មិនមានតំលៃថ្លៃពេកទេ ក្នុងការរៀបចំកម្រងសំណួរ ក៏មិនមានភាពលំអៀងពីអ្នកស្រាវជ្រាវដែរ ហើយអ្នកឆ្លើយសំណួរមានពេលវេលាដើម្បីផ្តល់យោបល់ល្អចេញពីចម្លើយរបស់ខ្លួន។ អ្នកស្រាវជ្រាវ អាចទាក់ទងអ្នកឆ្លើយសំណួរបាន ហើយការពិតថា កម្រងសំណួរ អាចធ្វើឱ្យលទ្ធផលដែលអាចទុកចិត្តបាន។ កម្រងសំណួរដោយខ្លួនឯងក៏សន្សំសំចៃផងដែរ ទាក់ទងនឹងពេលវេលា និងការខិតខំ។

ឧបករណ៍ស្រាវជ្រាវដែលត្រូវប្រើប្រាស់ដើម្បីប្រមូលទិន្នន័យ រួមមានកម្រងសំណួរ ។ កម្រងសំណួរ ត្រូវបានបែងចែកសម្រាប់ក្រុមគោលដៅចំនួន០៣ គឺៈ កម្រងសំណួរបម្រាប់ គណៈគ្រប់គ្រងសាលារៀន កម្រងសំណួរសម្រាប់គ្រូ ដែលកំពុងបង្រៀនភាសាអង់គ្លេស និងចុងក្រោយសម្រងសំណួរសម្រាប់សិស្ស។

## ៣.៣.១ កម្រងសំណួរសម្រាប់នាយក

គោលបំណងកម្រងសំណួរបម្រាប់នាយកសាលា គឺដើម្បីរកចង់ដឹងនូវព័ត៌មានជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងនិងការត្រួតពិនិត្យលើការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេសនៅតាមសាលាបឋមសិក្សារបស់ខ្លួនដូចតទៅៈ

១) តើសាលារៀន បានអនុវត្តតាមសេចក្តីណែនាំនៃការបង្រៀនភាសាអង់គ្លេសនៅថ្នាក់ទី៤ ទី៥ និងទី៦ឬទេ។

២) ការត្រួតពិនិត្យការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

៣) ការត្រួតពិនិត្យ ការបែងចែកម៉ោងសិក្សា ឬម៉ោងបង្រៀនភាសាភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

៤) ការគ្រប់គ្រង ការប្រើប្រាស់ធនធានគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦នៅតាមសាលារៀន។

៥)ការត្រួតពិនិត្យលើវិធីសាស្រ្តដែលគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦បាននិងកំពុងអនុវត្ត។

៦) ការត្រួតពិនិត្យ ការវាយតម្លៃលទ្ធផលសិក្សាដែលបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ ដែលគ្រូអនុវត្តកន្លងមក។

### ៣.៣.២ កម្រងសំណួរគ្រូបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦

គោលបំណងកម្រងសំណួរបម្រាប់បង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ គឺដើម្បីរកចង់ដឹងនូវព័ត៌មានជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធទៅនឹងការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ នៅតាមសាលាបឋមសិក្សារបស់ខ្លួនតាមស្ថានភាពជាក់ស្តែងមួយចំនួនដូចតទៅ៖

១) ការអនុវត្តន៍ការប្រើប្រាស់សៀវភៅគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

២) ការអនុវត្តន៍ម៉ោងបង្រៀនសៀវភៅគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

៣) ការបង្រៀននិងរៀននៃបំណិនភាសាអង់គ្លេសរបស់សិស្ស។

៤) បំណិន និងចំណេះដឹងរបស់គ្រូក្នុងការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ទី៥និងទី៦

៥) វិធីសាស្ត្រក្នុងការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

៦) ការវាយតម្លៃលទ្ធផលសិក្សា។

### ៣.៣.៣ កម្រងសំណួរសម្រាប់សិស្សានុសិស្សថ្នាក់ទី៤ ទី៥ និងទី៦

គោលបំណងកម្រងសំណួរបម្រាប់សិស្សានុសិស្សថ្នាក់ទី៤ ទី៥ និងទី៦ គឺដើម្បីរកចង់ដឹងនូវព័ត៌មានជាក់លាក់មួយចំនួន ដែលពាក់ព័ន្ធទៅនឹងការរៀនភាសអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ នៅតាមសាលាបឋមសិក្សារបស់ខ្លួនតាមស្ថានភាពជាក់ស្តែងមួយចំនួនដូចតទៅ៖

១)គណៈគ្រប់គ្រង និងគ្រូបង្រៀន បានផ្សព្វផ្សាយការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

២) ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦។

៣) ម៉ោងតាមកាលវិភាគដែលរៀនភាសាអង់គ្លេសនៅសាលារៀន។

៤) ធនធានគ្រូបង្រៀន (ចំណេះដឹង និងជំនាញ)។

៥) ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀន។

៦) ការវាយតម្លៃលទ្ធផលសិក្សា។

## ៣.៤ តំបន់គោលដៅ ក្រុមគោលដៅ និងសំណាក

តំបន់គោលដៅ ដែលត្រូវចុះទៅប្រមូលទិន្នន័យ គឺនៅក្នុងស្រុក និងក្រុងសរុបចំនួន ០៣ ក្នុងខេត្តតាកែវ គឺមាន ក្រុងដូនកែវ ស្រុកសំរោង ស្រុកត្រាំកក់។ ក្រុងដូនកែវ រួមមានសាលាបឋមសិក្សាតាកែវក្រុង សាលាបឋមសិក្សាអនុវត្ត និងសាលាបឋមសិក្សាក្រចាប់ ។ ស្រុកត្រាំកក់ រួមមានសាលាបឋមសិក្សាអង្គរុន សាលាបឋមសិក្សាអង្គស្លែង និងសាលាបឋមសិក្សាអង្គមន្ត្រី។ ស្រុកសំរោង រួមមាន សាលាបឋមសិក្សាអង្គប្រិយ៍ សាលាបឋមសិក្សាទួលទ្រា សាលាបឋមសិក្សាខ្សាច់សរ។ ចំពោះក្រុមគោលដៅ ការសិក្សាស្រាវជ្រាវនឹងសំដៅផ្តល់កម្រងសំណួរទៅក្រុមសិស្សានុសិស្សដែលរៀននៅថ្នាក់ទី៤ ទី៥ និងទី៦ សរុបចំនួន ១៧៨នាក់ រីឯគ្រូបង្រៀនភាសាអង់គ្លេស ដែលកំពុងរៀននៅថ្នាក់ទី៤ ទី៥ និងទី៦ សរុបទាំងអស់ចំនួន ២៤នាក់។ និងកិច្ចចុងក្រោយ ការស្រាវជ្រាវ នឹងផ្តល់កម្រងសំណួរដល់គណៈគ្រប់គ្រងសាលាបឋមសិក្សាសរុបចំនួន ៩នាក់។

ដូចនេះ សំណាកពាក់ព័ន្ធជាក់ស្តែងមានទាំងគណៈគ្រប់គ្រងសាលា ០៩នាក់ លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ចំនួន២៤នាក់ និងសិស្សានុសិស្សថ្នាក់ទី៤ ទី៥ និងទី៦ សរុបមានតែ ១៧៨នាក់។

### ៣.៤.១ ព័ត៌មានសាលាបឋមសិក្សា

តារាង០៣៖ ព័ត៌មានសាលាបឋមសិក្សា

| សាលាបឋមសិក្សា | ទីតាំង | នាយក/នាយករង | | គ្រូថ្នាក់ទី៤/៥/៦ | |
|---|---|---|---|---|---|
| | ស្រុក/ក្រុង | សរុប | ស្រី | សរុប | ស្រី |
| សាលាបឋមសិក្សា ៩ | ស្រុកសំរោង | ៣ | ០ | ៨ | ៥ |
| | ស្រុកត្រាំកក់ | ៣ | ១ | ៩ | ០ |
| | ក្រុងដូនកែវ | ៣ | ១ | ៧ | ១ |

សាលាបឋមសិក្សាសរុបចំនួនប្រាំបួន ដែលត្រូវបានជ្រើសរើសចេញពីស្រុកសរុបចំនួន ០៣ខាងលើ។ ក្នុងនោះដែរ នៅក្នុងស្រុកសំរោង សាលាបឋមសិក្សាដែលត្រូវបានជ្រើសរើសមានសាលាចំនួនបី ហើយគ្រូដែលបង្រៀនភាសាអង់គ្លេសចំនួន ៨នាក់ស្មើនឹង

៣៣.៣% រីឯ នៅក្នុងស្រុកត្រាំកក់ សាលាបឋមសិក្សាដែលត្រូវបានជ្រើសរើសមានចំនួន ០៣ ហើយគ្រូបង្រៀន ដែលបង្រៀនភាសាអង់គ្លេសចំនួន ៩នាក់ ស្មើនឹង ៣៧.៥% និង នៅក្នុងក្រុងដូនកែវ សាលាបឋមសិក្សាដែលត្រូវបានជ្រើសរើសមានចំនួន ០៣ផងដែរ រីឯគ្រូដែលបង្រៀនភាសាអង់គ្លេសចំនួន ៧នាក់ ស្មើនឹង ២៩.២% ។

### ៣.៤.២ ព័ត៌មានអ្នកចូលរួម

តារាង ០៤៖ អ្នកចូលរួមការស្រាវជ្រាវ

| នាយក/នាយករង | | គ្រូ | | សិស្ស | | សរុប | |
|---|---|---|---|---|---|---|---|
| ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី | ប្រុស | ស្រី |
| 7 | 2 | 18 | 6 | 63 | 115 | 88 | 123 |

តារាងខាងលើ បង្ហាញពីចំនួនអ្នកចូលរួមក្នុងតំណើរការនៃការស្រាវជ្រាវ។ គណៈគ្រប់គ្រងនៃសាលាសាលាបឋមសិក្សានីមួយៗដែលមានតួនាទីជានាយក និងនាយករង សរុបចំនួន ០៩នាក់ ស្មើនឹង ១០០% ភេទប្រុស ០៧នាក់ ស្មើនឹង ៧៧.៨% និង ស្រី ០២នាក់ ស្មើនឹង ២២.២%។ រីឯ លោកគ្រូអ្នកគ្រូ ដែលបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា សរុបចំនួន ២៤នាក់ ១០០% ភេទប្រុស ១៨នាក់ ស្មើនឹង ៧៥% និង ស្រីចំនួន ០៦នាក់ស្មើនឹង ២៥%។ចំណែកឯ សិស្សានុសិស្ស ដែលរៀននៅសាលាបឋមសិក្សាសរុបមានចំនួន ១៧៨នាក់ ស្មើនឹង ១០០% ភេទប្រុស ៦៣នាក់ ស្មើនឹង ៣៥.៤% ភេទស្រី ១១៥នាក់ ស្មើនឹង ៦៤.៦%។ ដូចនេះ ចំនួនអ្នកចូលរួមសរុបទាំងអស់ចំនួន ២១១នាក់១០០% ភេទប្រុស ៨៨នាក់ ៤១.៧% និង ភេទស្រី ១២៣នាក់ ស្មើនឹង ៥៨.៣%។

### ៣.៤.៣ ព័ត៌មានលំអិតរបស់នាយក និងនាយករង

តារាង៖ ០៥. ព័ត៌មានលំអិតរបស់នាយក និងនាយករង

| ចំនួនសរុប | ភេទ | អាយុ | សញ្ញាបត្រ | តួនាទី |
|---|---|---|---|---|

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 9 | ប្រុស | ស្រី | ចន្លោះអាយុ | ចំនួន | ប្រភេទសញ្ញាបត្រ | ចំនួន | នាយក | នាយករង |
| | | | [35-40[ | 2 | បរិញ្ញាបត្រ | 2 | 5 | 4 |
| | 7 | 2 | [40-45[ | 1 | បរិញ្ញាបត្ររង | 2 | | |
| | | | [45-50[ | 3 | សញ្ញាបត្រទុតិយភូមិ | 5 | | |
| | | | >50 | 3 | | | | |

នាយក និងនាយករង ដែលត្រូវបានជ្រើសរើសក្នុងចំណោមសាលាបឋមសិក្សាទាំងប្រាំបួន សរុបចំនួន ៩នាក់ ប្រុសចំនួន ០៧នាក់ ស្មើនឹង ៧៧.៨% និង ស្រីចំនួន ០២នាក់ ស្មើនឹង២២.២។ នៅក្នុងនោះដែរ នាយកសរុបចំនួន ៥នាក់ ស្មើនឹង ៥៥.៦% និង នាយករងសរុបចំនួន ០៤នាក់ ស្មើនឹង ៤៤.៤%។ ចំពោះអាយុ ចាប់ពី ៣៥ឆ្នាំ ដល់ ៤០ឆ្នាំ មានចំនួន ០២នាក់ស្មើនឹង២២.២% ។ រីឯ អាយុចាប់ពី ៤០ឆ្នាំ ដល់ ៤៥ឆ្នាំ មានចំនួន ១នាក់ ស្មើនឹង ១១.១% ។ ចំណែកឯ អាយុចាប់៤៥ ដល់ ៥០ឆ្នាំ មានចំនួន ០៣នាក់ ស្មើនឹង ៣៣.៣% និង អាយុចាប់ពី៥០ឆ្នាំឡើងទៅ មានចំនួន ០៣នាក់ ស្មើនឹង ៣៣.៣%។

### ៣.៤.៤ ព័ត៌មានលំអិតរបស់គ្រូ

តារាង ០៦៖ ព័ត៌មានលំអិតរបស់គ្រូ

| ចំនួនគ្រូ | ភេទ | | អាយុ | | សញ្ញាបត្រ | | ថ្នាក់ | |
|---|---|---|---|---|---|---|---|---|
| 24 | ប្រុស | ស្រី | ចន្លោះអាយុ | ចំនួន | សញ្ញាបត្រ | ចំនួន | កម្រិត | គ្រូ |
| | | | [25-30[ | 4 | បរិញ្ញាបត្រជាន់ខ្ពស់ | 1 | ទី4 | 9 |
| | 18 | 6 | [30-35[ | 2 | បរិញ្ញាបត្រ | 6 | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| | | | | | | | ទី៥ | 7 |
| | | | [35-40[ | 11 | បរិញ្ញបត្ររង | 5 | | |
| | | | [40-45[ | 7 | សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ? | 12 | ទី៦ | 8 |

តារាងខាងលើនេះ បង្ហាញពីចំនួនគ្រូបង្រៀនភាសាអង់គ្លេសសរុប ២៤នាក់ ភេទប្រុស ១៨នាក់ ស្មើនឹង ៧៥% និង ភេទស្រី ០៦នាក់ ស្មើនឹង ២៥%។ ចំពោះអាយុរបស់គ្រូនីមួយៗចាប់ពី ២៥ឆ្នាំ ដល់ ៣០ឆ្នាំ មានចំនួន ៤នាក់ ស្មើនឹង ១៦.៧ ។ រីឯ អាយុចាប់ពី ៣០ឆ្នាំ ដល់ ៣៥ឆ្នាំ មានចំនួន ០២នាក់ ស្មើនឹង ៨.៣% ។ ចំណែកឯ អាយុចាប់ពី ៣៥ឆ្នាំ ដល់ ៤០ឆ្នាំ មានចំនួន ១១នាក់ ស្មើនឹង ៤៥.៨% និង អាយុចាប់ពី ៤០ឆ្នាំ ដល់ ៤៥ឆ្នាំ មានចំនួន ៧នាក់ ស្មើនឹង ២៩.២%។

ចំពោះកម្រិតសញ្ញាបត្ររបស់គ្រូ ដែលបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សាមានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ចំនួន០១នាក់ ស្មើនឹង ៤.២% ។ សញ្ញាបត្របរិញ្ញាបត្រចំនួន ០៦នាក់ស្មើនឹង ២៥%។ សញ្ញាបត្របរិញ្ញាបត្ររងចំនួន ៥នាក់ ស្មើនឹង ២០.៨% និង សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំនួន ១២នាក់ ស្មើនឹង ៥០%។

ចំពោះចំនួនកម្រិតថ្នាក់របស់គ្រូ ដែលទទួលបន្ទុកបង្រៀននៅតាមថ្នាក់នីមួយៗមានកម្រិតដូចតទៅ៖ គ្រូបង្រៀនថ្នាក់ទី៤ ចំនួន ០៩នាក់ ស្មើនឹង ៣៧.៥% ។ ចំណែកឯ គ្រូបង្រៀនថ្នាក់ទី៥ ចំនួន ០៧នាក់ ស្មើនឹង ២៩.២% និង គ្រូបង្រៀនថ្នាក់ទី៦ ចំនួន ០៨នាក់ ស្មើនឹង៣៣.៣%។

## ៣.៤.៥ ព័ត៌មានលំអិតរបស់សិស្ស

តារាងទី០៧៖ . ព័ត៌មានលំអិតរបស់សិស្ស

| ចំនួនសរុប | ភេទ | | អាយុ | | ថ្នាក់ | | |
|---|---|---|---|---|---|---|---|
| 178 | ប្រុស | ស្រី | ចន្លោះអាយុ | ចំនួន | ទី4 | ទី5 | ទី6 |
| | | | [9-11] | 119 | 75 | 40 | 63 |
| | 63 | 115 | [12-14] | 59 | | | |

តារាងខាងលើ បង្ហាញពីព័ត៌មានលំអិតរបស់សិស្ស។ សិស្សានុសិស្សសរុបទាំងអស់ចំនួន ១៧៨នាក់ ស្មើនឹង ១០០% ។ ក្នុងនោះដែរ ប្រុសចំនួន ៦៣នាក់ ស្មើនឹង ៣៥.៤% និង ស្រីចំនួន ១១៥នាក់ ស្មើនឹង ៦៤.៦%។

ចំពោះអាយុរបស់សិស្ស ចាប់ពីចន្លោះអាយុ ៩ឆ្នាំ ដល់ ១១ឆ្នាំ មានចំនួនសរុប ១១៩នាក់ ស្មើនឹង ៦៦.៩% និង សិស្សចាប់ពីចន្លោះអាយុ ១២ឆ្នាំ ដល់ ១៤ឆ្នាំ មានចំនួនសរុប ៥៩នាក់ ស្មើនឹង ៣៣.១%។

នៅក្នុងនោះដែរ សិស្សកម្រិតថ្នាក់ទី៤ សរុបចំនួន ៧៥នាក់ ស្មើនឹង ៤២%។ រីឯសិស្សកម្រិតថ្នាក់ទី៥ សរុបចំនួន ៤០នាក់ ស្មើនឹង ២២.៥% និងសិស្សកម្រិតថ្នាក់ទី៦ សរុបចំនួន ៦៣នាក់ ស្មើនឹង ៣៥.៤%។

## ៣.៥ ដំណើរការនៃការប្រមូលទិន្នន័យ

ការប្រមូលទិន្នន័យ នឹងធ្វើឡើង បន្ទាប់ពីឧបករណ៍ស្រាវជ្រាវ ត្រូវបានរៀបចំឡើងជាស្ថាពរ និងត្រួតពិនិត្យកែសម្រួលរួចរាល់ និងធ្វើឡើងបន្ទាប់ការឯកភាពទាំងស្រុងពីសំណាក់សាស្ត្រាចារ្យដឹកនាំបង្គោល និងសាស្ត្រាចារ្យដឹកនាំរង រួមជាមួយនឹង គណៈគ្រប់គ្រងនៃវិទ្យាស្ថានជាតិអប់រំ រួមទាំងការចូលរួមសហការជាមួយប្រធានមន្ទីរ អប់រំ យុវជន និងកីឡាខេត្តតាកែវ និង គណៈគ្រប់គ្រងសាលាបឋមសិក្សានីមួយៗ។

មុននឹងចាប់ផ្តើមនៃកិច្ចការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ អ្នកស្រាវជ្រាវ ត្រូវមានលិខិតឧទ្ទេសនាមអនុញ្ញាតចាត់តាំងឱ្យចុះប្រមូលទិន្នន័យពីសំណាក់វិទ្យាស្ថានជាតិអប់រំ ហើយថែមទាំង ទទួលបានការអនុញ្ញាតពី មន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ និងព័ត៌មានលម្អិតបន្ថែមនានា អំពីការស្រាវជ្រាវ។ ការចុះប្រមូលទិន្នន័យនៅតាមសាលាគោលដៅ

ដែលបានជ្រើសរើស នឹងចាប់ផ្តើមនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។ បន្ទាប់ពីទទួលបានការអនុញ្ញាតរបស់វិទ្យាស្ថានជាតិអប់រំ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ អ្នកស្រាវជ្រាវ ក៏បានចុះទៅជួបផ្ទាល់ជាមួយគណៈគ្រប់គ្រងសាលានីមួយៗ ក្នុងចំណោមសាលាបឋមសិក្សាគោលដៅចំនួន០៩ ដើម្បីស្នើសុំការអនុញ្ញាតជួបជាមួយ នាយក នាយិការសាលា លោកគ្រូអ្នកគ្រូ ដែលបាននឹងកំពុងបង្រៀនភាសាអង់គ្លេស ថ្នាក់ទី៤ទី៥ និងទី៦ ព្រមទាំងក្រុមសិស្សានុសិស្សថ្នាក់ទី៤ទី៥និងទី៦។ អ្នកស្រាវជ្រាវ ស្នើសុំគណៈគ្រប់គ្រងសាលាបន្ថែមទៀត ដើម្បីជួយសម្របសម្រួល និងផ្តល់ឱកាសក្នុងដំណើរការជ្រើសរើសលោកគ្រូអ្នកគ្រូ ដែលកំពុងបង្រៀនថ្នាក់ទី៤ទី៥និងទី៦ និងក្រុមសិស្សានុសិស្ស ឱ្យចូលរួមក្នុងការបំពេញកម្រងសំណួរ។ អ្នកស្រាវជ្រាវ បានពន្យល់ពីគោលបំណងនៃការប្រមូលទិន្នន័យ និងស្នើសុំឱ្យអ្នកចូលរួមទាំងអស់ជួយបំពេញកម្រងសំណួរដែលបានរៀបចំសម្រាប់ក្រុមគោលដៅនីមួយៗ។

## ៣.៦ វិធីសាស្ត្រវិភាគទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងតាមបែបបរិមាណវិស័យ។ ដូចនេះ រាល់ទិន្នន័យ ដែលអ្នកស្រាវជ្រាវប្រមូលបាន គឺត្រូវយកមកវិភាគក្នុងកម្មវិធីកុំព្យូទ័រ កម្មវិធី (SPSS) និងកម្មវិធី (Microsoft Excel )

ចំពោះទិន្នន័យ ដែលទទួលបានពីក្រុមសិស្សានុសិស្ស លោកគ្រូអ្នកគ្រូ និងគណៈគ្រប់គ្រង និងត្រូវបានធ្វើចំណាត់ក្រុមថ្នាក់ ដើម្បីបញ្ចូលទិន្នន័យក្នុងកម្មវិធីវិភាគ ដើម្បីធានាបាននូវប្រសិទ្ធភាពនូវកម្រិតជឿជាក់លើលទ្ធផលនៃការសិក្សាស្រាវជ្រាវខាងលើ។ ដើម្បីបង្កើននូវភាពកាន់តែជឿជាក់ និងប្រសិទ្ធភាពខ្ពស់នៃការសិក្សា អ្នកសិក្សាស្រាវជ្រាវ នឹងធ្វើការផ្ទៀងផ្ទាត់ ទាំងនៅលើក្រដាស់ និងនៅក្នុងកម្មវិធីកុំព្យូទ័រ ឱ្យបានច្រើនដង ដើម្បីជៀសវាងនូវកំហុសឆ្គងកើតឡើងដោយអចេតនា។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ

# និង

# ជំពូកទី៤៖ លទ្ធផលស្រាវជ្រាវនិងការពិភាក្សា

## ៤. ១. គណៈគ្រប់គ្រងសាលា

### ៤.១.១ ការអនុវត្តន៍សៀវភៅសិក្សាគោល

### ៤.១.១.២ សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលានីមួយៗ

ក្រាហ្វិកទី០១៖ ចំនួនសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលានីមួយៗ




ក្រាហ្វិកខាងលើ បង្ហាញអំពីចំនួនសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលាបឋមសិក្សាចំនួនប្រាំបួន។ យោងតាម ក្រាហ្វិកខាងលើ សាលាបឋមសិក្សាចំនួន ០៨ ស្មើនឹង ៨៨.៩% មានសៀវភៅសិក្សាគោលភាសាអង់គ្លេសគ្រប់គ្រាន់។ ដោយឡែក គឺមានសាលាបឋមសិក្សាចំនួន ០១ ស្មើនឹង ១១.១% បានទទួលសៀវភៅសិក្សាគោលភាសាអង់គ្លេសពុំទាន់គ្រប់គ្រាន់នៅឡើយទេ។

ដូចនេះ ការប្រើប្រាស់សៀវភៅសិក្សាគោល មិនគ្រប់គ្រាន់នៅតាមសាលារៀននាំឱ្យជះឥទ្ធិពលដល់ការសិក្សារៀនសូត្ររបស់សិស្សទាំងក្នុងម៉ោង និង ក្រៅម៉ោងសិក្សា។

### ៤.១.១.៣ ការចែកសៀវភៅសិក្សាគោលភាសាអង់គ្លេស

ក្រាហ្វិកទី០២៖ ការចែកសៀវភៅសិក្សាគោលភាសាអង់គ្លេស



ក្រាហ្វិកខាងលើ បង្ហាញថា សាលាបឋមសិក្សាទាំង០៩ ស្មើនឹង ១០០% បានចែកសៀវភៅសិក្សាគោលភាសាអង់គ្លេសដល់សិស្ស សម្រាប់សិស្សរៀននៅ ថ្នាក់ទី៤ ទី៥ និងទី៦ ដោយគ្មានសាលាណាមួយអាក់ខាននោះទេ បើទោះបីជា សាលាជួបបញ្ហាយឺតយ៉ាវបន្តិចបន្តួច ក្នុងការប្រគល់សៀវភៅសិក្សាគោលភាសាអង់គ្លេសដល់ក៏ពិតមែន តែសាលានូវតែយកចិត្តទុកដាក់លើបញ្ហាការសិក្សារបស់សិស្ស ជាបញ្ហាចំបងរបស់សាលា ត្រូវដោះស្រាយជាមុន។

## ៤.១.១.៤ កម្រិតយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេស

ក្រាហ្វិកទី០៣៖ កម្រិតយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេស




ក្រាហ្វិកខាងលើ បង្ហាញថា គណៈគ្រប់គ្រងចំនួន ០៦នាក់ ស្មើនឹង ៦៦.៧% បានបង្ហាញថា គ្រូមានកម្រិតយល់ដឹងច្រើន លើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេស។ គ្រូដែលយល់ដឹងច្រើនទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេស ដោយសារ ហេតុផលទីមួយ គ្រូបានចូលរួមសិក្ខាសាលាវគ្គបណ្តុះបណ្តាលការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស ដែលត្រូវបានធ្វើឡើងនៅសាលាគរុកោសល្យ និងវិក្រឹតការខេត្តតាកែវ។ ហេតុផលទី២ គ្រូទទួលបាននូវឯកសាជំនួយការរៀន និងបង្រៀនភាសាអង់គ្លេស និងមានចំណេះដឹងលើសម្ភារៈ ដែលខ្លួនបានអនុវត្តជាក់ស្តែងក្នុងការផលិតក្នុងពេលសិក្ខាសាលា។ ហេតុផលទី៣ គ្រូបានសិក្សារៀនសូត្រភាសាអង់គ្លេសពីមុន។ រីឯ គណៈគ្រប់គ្រង ចំនួន ០៣

នាក់ ស្មើនឹង ៣៣.៣% បានបង្ហាញថា គ្រូយល់ដឹងតិចតួច ទៅលើសៀវភៅសិក្សាគោលភាសាអង់គ្លេស ដោយហេតុថា គ្រូមិនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេស។ មូលហេតុផ្សេងទៀត គឺដោយសារ ការស្នើសុំផ្លាស់ប្តូរទទួលបន្ទុកកម្រិតថ្នាក់ពីសំណាក់គ្រូ ជាហេតុនាំឱ្យ បាត់បង់គ្រូដែលមានចំណេះដឹងភាសាអង់គ្លេស។

ដូចនេះ គ្រូដែលកំពុងបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សារដ្ឋ ពុំទាន់មានសមត្ថភាពយល់ដឹងលើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេស បានទាំងអស់គ្នានៅឡើយទេ។

## ៤.១.២ ការអនុវត្តន៍ម៉ោងសិក្សា

តារាងទី០៨៖ ទស្សនៈរបស់នាយកលើការប្រើប្រាស់ម៉ោងសិក្សា

SD=មិនយល់ស្របទាំងស្រុង; D=មិនយល់ស្រប; A=យល់ស្រប; SA=យល់ស្របទាំងស្រុង

| ទស្សនៈរបស់នាយក និង នាយករង | | SD | D | A | SA |
|---|---|---|---|---|---|
| ១ | សាលាលោកគ្រូ អនុវត្តការបង្រៀនភាសាអង់គ្លេស ២ម៉ោង ក្នុងមួយសប្តាហ៍។ | 22.2% | 00.0% | 44.4% | 33.3% |
| ២ | សាលាលោកគ្រូ បានធ្វើបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស។ | 11.1% | 33.3% | 44.4% | 11.1% |
| ៣ | សាលាលោកគ្រូ បានអនុវត្តទាន់តាមបំណែងចែកកម្មវិធីសិក្សា។ | 11.1% | 44.4% | 33.3% | 11.1% |
| ៤ | សាលាលោកគ្រូ បានអនុវត្តការបង្រៀនភាសាអង់គ្លេសក្នុង ១ម៉ោងសិក្សារយៈពេល៤០នាទី។ | 11.1% | 11.1% | 33.3% | 44.4% |

យោងតាមតារាងខាងលើ បានបង្ហាញថា (លេខ១) នាយក/នាយករង ចំនួន ០៤នាក់ ស្មើនឹង(៤៤.៤%) បានយល់ស្របលើការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេសរបស់គ្រូ ដែល

មានចំនួន ០២ម៉ោង ក្នុងមួយសប្ដាហ៍។ (លេខ២) នាយក/នាយករង ចំនួន០៤នាក់ ស្មើនឹង (៤៥.៨%) បានយល់ស្រប លើការអនុវត្តន៍ការធ្វើបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស។ (លេខ៣) នាយក/នាយករង ចំនួន ០៤នាក់ ស្មើនឹង (៤៥.៨%) បានមិនយល់ស្របលើការអនុវត្តន៍ទាន់តាមបំណែងចែកកម្មវិធីសិក្សា។ (លេខ៤) នាយក/នាយករង ចំនួន ០៤នាក់ ស្មើនឹង (៤៥.៨%) បានយល់ស្របទាំងស្រុង លើការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេសក្នុង១ម៉ោងសិក្សារយៈពេល៤០នាទី។

ដូចនេះ នៅតាមសាលាបឋមសិក្សាទាំង៩ ពុំទាន់អនុវត្តបានទាំងស្រុងទៅលើ ការអនុវត្តន៍ម៉ោងបង្រៀន ការធ្វើបំណែងចែកកម្មវិធីសិក្សា និងការបង្រៀនឱ្យទាន់កម្មវិធីសិក្សា។

## ៤.២ គ្រូបង្រៀនភាសាអង់គ្លេស

### ៤.២.១ ការអនុវត្តន៍សៀវភៅសិក្សាគោល

### ៤.២.១.១ ការយល់ដឹងរបស់គ្រូចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេស

ក្រាហ្វិកទី០៤៖ ការយល់ដឹងរបស់គ្រូចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេស



ក្រាហ្វិកខាងលើ បង្ហាញពីការយល់ដឹងរបស់គ្រូចំពោះខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេសកម្រិតបឋមសិក្សា។ គ្រូដែលយល់ដឹងច្បាស់លើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេសចំនួន ១៣នាក់ ស្មើនឹង ៥៤.២%។ ចំណែកឯ គ្រូដែលយល់ដឹងតិចតួចលើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេសចំនួន ៥នាក់ ស្មើនឹង ២០.៨%។ រីឯគ្រូ ដែលយល់ដឹងមិនច្បាស់លើខ្លឹមសារសៀវភៅសិក្សាគោលភាសាអង់គ្លេសចំនួន ០៦នាក់ ស្មើនឹង ២៥%។

ដូចនេះ ការអនុវត្តន៍ ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសក្នុងការបង្រៀន ពុំទាន់ទទួលមានលទ្ធផលល្អនូវឡើយទេ ដោយហេតុថា គ្រូចំនួន១១នាក់ ស្មើនឹង ៤៥.៨% ពុំទាន់យល់ច្បាស់ លើខ្លឹមសារសៀវភៅសិក្សាគោល។

### ៤.២.១.២ ការយល់ដឹងរបស់គ្រូចំពោះឯកសារជំនួយការរៀននិងការបង្រៀន

ក្រាហ្វិកទី០៥៖ ការយល់ដឹងរបស់គ្រូចំពោះឯកសារជំនួយការរៀននិងការបង្រៀន




ក្រាហ្វិកខាងលើ បង្ហាញពីការយល់ដឹងរបស់គ្រូចំពោះឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេស។ គ្រូ ដែលយល់ដឹងច្បាស់លើឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេស ចំនួន ០៩នាក់ ស្មើនឹង ៣៧.៥%។ ចំណែកឯ គ្រូដែល

យល់ដឹងតិចតួច លើឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេស ចំនួន ០៨នាក់ ស្មើនឹង ៣៣.៣%។ រីឯ គ្រូដែលយល់ដឹងមិនច្បាស់ លើឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេសចំនួន ០៧នាក់ ស្មើនឹង ២៩.២%។

ដូចនេះ ការយល់ដឹងរបស់គ្រូ លើឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេស គឺនៅមានកម្រិតនៅឡើយ។ គ្រូចំនួន ១៥នាក់ ស្មើនឹង ៧០.៨% ពុំទាន់យល់ដឹងច្បាស់ លើឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេស។

### ៤.២.១.៣ ការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស

ក្រាហ្វិកទី០៦៖ការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស




ក្រាហ្វិកខាងលើ បង្ហាញពីការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស។ គ្រូបង្រៀនដែលយល់ដឹងច្បាស់ លើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសចំនួន ០៧នាក់ ស្មើនឹង ២៩.២%។ ចំណែកឯ គ្រូដែលយល់ដឹងតិចតួច លើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសចំនួន ០៦នាក់ ស្មើនឹង ២៥%។ រីឯ គ្រូដែលយល់ដឹងមិនច្បាស់ លើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសចំនួន ០៩នាក់ ស្មើនឹង ៣៧.៥%។ និងគ្រូ ដែលមិនដឹង លើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសចំនួន ០២នាក់ ស្មើនឹង ៨.៣%។

ដូចនេះ គ្រូបង្រៀនដែលយល់ដឹងមិនច្បាស់ លើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសមានចំនួន ០៧នាក់ ស្មើនឹង ២៩.២% ក្នុងចំណោមគ្រូចំនួន ២៤នាក់។ ចំណែកឯ ការយល់ដឹងនៅមានកំណត់ របស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសមានចំនួន ១៧នាក់ ស្មើនឹង ៧០.៨%។

## ៤.២.២ ការអនុវត្តន៍ម៉ោងសិក្សា

### ៤.២.២.១ ម៉ោងបង្រៀនសៀវភៅសិក្សាគោលក្នុងមួយសប្តាហ៍

ក្រាហ្វិកទី០៧៖ ម៉ោងបង្រៀនសៀវភៅសិក្សាគោលក្នុងមួយសប្តាហ៍




ក្រាហ្វិកខាងលើ បង្ហាញពីម៉ោងបង្រៀនសៀវភៅសិក្សាគោលក្នុងមួយសប្តាហ៍របស់គ្រូ។ គ្រូដែលបង្រៀនភាសាអង់គ្លេស ០២ម៉ោង ក្នុងមួយសប្តាហ៍ មានចំនួន ១៧នាក់ ស្មើនឹង ៧០.៨%។ រីឯ គ្រូដែលបង្រៀនភាសាអង់គ្លេស ១ម៉ោង ក្នុងមួយសប្តាហ៍ មានចំនួន ០៦នាក់ ស្មើនឹង ២៥%។ ចំណែកឯ គ្រូដែលបង្រៀនភាសាអង់គ្លេស លើសពី ២ម៉ោង ក្នុងមួយសប្តាហ៍មានចំនួន ០១នាក់ ស្មើនឹង ៤.២%។

ដូចនេះ គ្រូចំនួន ៧នាក់ ស្មើនឹង ២៩.១% ពុំទាន់អនុវត្តការប្រើប្រាស់ម៉ោងបង្រៀននីមួយៗតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំនៅឡើយទេ។

### ៤.២.២.២ បួនចំណុចក្នុងមួយមេរៀនដែលចំណុចនីមួយៗមានរយៈពេលដប់នាទី

ក្រាហ្វិកទី០៨៖ បួនចំណុចក្នុងមួយមេរៀនដែលចំណុចនីមួយៗមានរយៈពេលដប់នាទី




ក្រាហ្វិកខាងលើ បង្ហាញពីរបៀបដែលគ្រូត្រូវបង្រៀនចំនួន ០៤ចំណុច ក្នុងមួយមេរៀន ដែលចំណុចនីមួយៗ មានរយៈពេលដប់នាទី។ គ្រូបានអនុវត្តមានចំនួន ១៤នាក់ស្មើនឹង ៥៨.៣%។ រីឯ គ្រូដែលអនុវត្តមិនច្បាស់ចំនួន ០៥នាក់ ស្មើនឹង ២០.៨% និងគ្រូមិនបានអនុវត្តចំនួន ៥០នាក់ ស្មើនឹង ២០.៨%។

ដូចនេះ គ្រូបង្រៀនចំនួន ៤១.៧% ពុំទាន់យល់ច្បាស់ អំពីការប្រើប្រាស់រយៈពេលបង្រៀននៃចំណុចនីមួយ នៅឡើយទេ។

### ៤.២.២.៣ រយៈពេលបង្រៀនក្នុងមួយមេរៀន ៤០នាទី

ក្រាហ្វិកទី៩៖ រយៈពេលបង្រៀនក្នុងមួយមេរៀន ៤០នាទី




ក្រាហ្វិកខាងលើ បង្ហាញពីរយៈពេលបង្រៀនក្នុងមួយមេរៀន ៩០នាទី ដែលគ្រូបានអនុវត្តចំពោះសៀវភៅសិក្សាគោលភាសាអង់គ្លេស។ គ្រូចំនួន២១នាក់ ស្មើនឹង ៨៧.៥% បានអនុវត្តការបង្រៀនរយៈពេល ០១ម៉ោងមេរៀន បង្រៀនតែ៩០នាទី។ ចំណែកឯ គ្រូ ដែលមិនបានអនុវត្តមានចំនួន ០២នាក់ ស្មើនឹង ៨.៣% និង គ្រូមិនច្បាស់ ក្នុងការអនុវត្តន៍មានចំនួន ០១នាក់ស្មើ នឹង៤.២%។

ដូចនេះ គ្រូដែលបានអនុវត្ត ច្រើនជាង ៧៩.២% នៃគ្រូមិនបានអនុវត្ត និងច្រើនជាង ៨៣.៣% នៃគ្រូមិនច្បាស់។ ទោះបីជាយ៉ាងនេះក្តី គ្រូត្រូវអនុវត្តតាមសេចក្តីណែនាំឱ្យបានគ្រប់គ្រប់គ្នាទើបជាការប្រសើរលើការអនុវត្តន៍សៀវភៅសិក្សាគោល។

## ៤.២.៣ ការវាយតម្លៃសមត្ថភាពទាំងបួនរបស់សិស្ស

### ៤.២.៣.១ ការវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស

ក្រាហ្វិកទី១០៖ ការវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស




ក្រាហ្វិកខាងលើ បង្ហាញពីការវាយតម្លៃសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់សិស្ស ពីសំណាក់គ្រូបង្រៀន។ គ្រូដែលវាយតម្លៃសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់សិស្សមួយដងក្នុងមួយសប្តាហ៍មានចំនួន ០១៨នាក់ ស្មើនឹង ៧៥% រីឯគ្រូ ដែលវាយតម្លៃសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់របស់សិស្ស ពីរដងក្នុងមួយសប្តាហ៍ មានចំនួន ០៥នាក់ ស្មើនឹង ២០.៨% ចំណែកឯគ្រូ ដែលវាយតម្លៃសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់របស់សិស្ស លើសពី ពីរដងក្នុងមួយសប្តាហ៍មានចំនួន ០១នាក់ ស្មើនឹង ៤.២%។

ដូចនេះ ការវាយតម្លៃ ២ដង និង លើសពី២ដង ក្នុងមួយសប្តាហ៍ នាំឱ្យមានគម្លាតនៃការយល់ដឹង ការចងចាំរបស់សិស្ស និងបាត់បង់បំរុងប្រយ័ត្នលើមេរៀន។

### ៤.២.៣.២ វិធីសាស្ត្រវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស

ក្រាហ្វិកទី១១៖ វិធីសាស្ត្រវាយតម្លៃសមត្ថភាពស្តាប់របស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការវាយតម្លៃសមត្ថភាពស្តាប់ភាសាអង់គ្លេសរបស់គ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពស្តាប់ តាមដំណាក់កាល មានចំនួន ១៥នាក់ ស្មើនឹង ៦២.៥% រីឯគ្រូ ដែលវាយតម្លៃសមត្ថភាពស្តាប់ តាមបូកសរុបមានចំនួន ៥០នាក់ ស្មើនឹង ២០.៨%។ ចំណែកឯគ្រូ ដែលវាយតម្លៃសមត្ថភាពស្តាប់ តាមដំណាក់កាល និង វាយតម្លៃសមត្ថភាពស្តាប់ តាមបូកសរុបមានចំនួន ០៤នាក់ ស្មើនឹង ១៦.៧%។

ដូននេះ គ្រូគួរតែវាយតម្លៃសមត្ថភាពរបស់សិស្សជាប្រចាំ តាមដំណាក់ និង បូកសរុប ដើម្បីពង្រឹងសមត្ថភាពស្តាប់របស់សិស្សឱ្យបានកាន់តែប្រើឡើង។

### ៤.២.៣.៣ ការវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស

ក្រាហ្វិកទី១២៖ ការវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពី ការវាយតម្លៃសមត្ថភាពនិយាយ ភាសាអង់គ្លេសរបស់គ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពនិយាយ ១ដងក្នុងមួយសប្តាហ៍ ចំនួន ១២នាក់ស្មើនឹង ៥០% ។ រីឯគ្រូ ដែលវាយតម្លៃសមត្ថភាពនិយាយ ២ដងក្នុងមួយសប្តាហ៍ ចំនួន ១១នាក់ស្មើនឹង ៤៥.៨%។ ចំណែកឯគ្រូ ដែលវាយតម្លៃសមត្ថភាពនិយាយ ច្រើនជាង ២ដងក្នុងមួយសប្តាហ៍ ចំនួន ០១នាក់ ស្មើនឹង ៤.២% ។

ដូននេះ គ្រូត្រូវតែវាយតម្លៃសមត្ថភាពនិយាយ ភាសាអង់គ្លេស ១ដងក្នុងមួយសប្តាហ៍ ដើម្បីឱ្យសិស្សមានឱកាសទំនងទំនងភាសាអង់គ្លេសក្នុងថ្នាក់រៀន។

### ៤.២.៣.៤ វិធីសាស្ត្រវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស

ក្រាហ្វិកទី១៣៖ វិធីសាស្ត្រវាយតម្លៃសមត្ថភាពនិយាយរបស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការវាយតម្លៃសមត្ថភាពនិយាយ ភាសាអង់គ្លេសរបស់សិស្សតាមរយៈគ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពនិយាយ តាមដំណាក់កាលមានចំនួន ១០នាក់ ស្មើនឹង ៤១.៧%។ រីឯគ្រូ ដែលវាយតម្លៃសមត្ថភាពនិយាយ តាមបូកសរុបមានចំនួន ០៨នាក់ ស្មើនឹង ៣៣.៣% ។ ចំណែកឯ គ្រូដែលវាយតម្លៃសមត្ថភាពនិយាយតាមដំណាក់កាល និង តាមបូកសរុប មានចំនួន ០៦នាក់ ស្មើនឹង ២៥%។

ដូននេះ គ្រូគួរតែវាយតម្លៃសមត្ថភាពនិយាយ របស់សិស្សជាប្រចាំ តាមដំណាក់ និងបូកសរុប ដើម្បីពង្រឹងសមត្ថភាពនិយាយរបស់សិស្សឱ្យកាន់តែប្រើឡើង។

### ៤.២.៣.៥ ការវាយតម្លៃសមត្ថភាពអានរបស់សិស្ស

ក្រាហ្វិកទី១៤៖ ការវាយតម្លៃសមត្ថភាពអានរបស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការវាយតម្លៃសមត្ថភាពអាន ភាសាអង់គ្លេសរបស់សិស្សតាមរយៈគ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពអាន ១ដងក្នុងមួយសប្តាហ៍ ចំនួន ១១នាក់ ស្មើនឹង ៤៥.៨ % ។ រីឯ គ្រូដែលវាយតម្លៃសមត្ថភាពអាន ២ដងក្នុងមួយសប្តាហ៍ ចំនួន ១៣នាក់ ស្មើនឹង ៥៤.២%។ ចំណែកឯ គ្រូដែលវាយតម្លៃសមត្ថភាពអាន លើសពី ២ ដងក្នុងមួយសប្តាហ៍ ពុំមានទេ។

ដូចនេះ គ្រូត្រូវតែពង្រឹងសមត្ថភាពអានជាប្រចាំដើម្បីឱ្យសិស្សអានបានស្ទាត់ជំនាញលើសមត្ថភាពសម្ព័នភាសាអង់គ្លេស។

### ៤.២.៣.៦ វិធីសាស្ត្រវាយតម្លៃសមត្ថភាពអានរបស់សិស្ស

ក្រាហ្វិកទី១៥៖ វិធីសាស្ត្រវាយតម្លៃសមត្ថភាពអានរបស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការវាយតម្លៃសមត្ថភាពអាន ភាសាអង់គ្លេសរបស់សិស្សតាមរយៈគ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពអាន តាមដំណាក់កាលមានចំនួន ០៩នាក់ ស្មើនឹង ៣៧.៥% ។ រីឯ គ្រូដែលវាយតម្លៃសមត្ថភាពនិយាយ តាមបូកសរុបមានចំនួន ០៨នាក់ ស្មើនឹង ៣៣.៣%។ ចំណែកឯ គ្រូដែលវាយតម្លៃសមត្ថភាពអាន តាមដំណាក់កាល និង តាមបូកសរុប មានចំនួន ០៧នាក់ ស្មើនឹង ២៩.២%។

ដូចនេះ សមត្ថភាពអានភាសាអង់គ្លេសគឺមានសារៈសំខាន់ណាស់ គ្រូត្រូវតែវាយតម្លៃតាមដំណាក់និងបូកសរុបដើម្បីពង្រឹងគុណភាពសមត្ថភាពអានរបស់សិស្ស។

### ៤.២.៣.៧ ការវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស

ក្រាហ្វិកទី១៦៖ ការវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការវាយតម្លៃសមត្ថភាពសរសេរ ភាសាអង់គ្លេសរបស់សិស្សតាមរយៈគ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពសរសេរ ១ដងក្នុងមួយសប្តាហ៍ ចំនួន ១២នាក់ ស្មើនឹង ៥០ %។ រីឯ គ្រូដែលវាយតម្លៃសមត្ថភាពសរសេរ ២ដងក្នុងមួយសប្តាហ៍ ចំនួន ១១នាក់ ស្មើនឹង ៤៥.៨%។ ចំណែកឯ គ្រូដែលវាយតម្លៃសមត្ថភាពសរសេរ លើសពី ២ដងក្នុងមួយសប្តាហ៍ មានចំនួន ០១នាក់ ស្មើនឹង ៤.១% ។

ដូចនេះ សមត្ថភាពសរសេរភាសាអង់គ្លេសគឺមានសារៈសំខាន់ណាស់ គ្រូត្រូវតែវាយតម្លៃតាមដំណាក់និងបូកសរុបដើម្បីពង្រឹងសមត្ថភាពសរសេររបស់សិស្សឱ្យបានត្រឹមត្រូវ។

## ៤.២.៣.៨ វិធីសាស្ត្រវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស

ក្រាហ្វិកទី១៧៖ វិធីសាស្ត្រវាយតម្លៃសមត្ថភាពសរសេររបស់សិស្ស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការវាយតម្លៃសមត្ថភាពសរសេរ ភាសាអង់គ្លេសរបស់សិស្សតាមរយៈគ្រូនីមួយៗ។ គ្រូដែលវាយតម្លៃសមត្ថភាពសរសេរ តាមដំណាក់កាលមានចំនួន ១០នាក់ ស្មើនឹង ៤១.៧%។ រីឯ គ្រូដែលវាយតម្លៃសមត្ថភាពសរសេរ តាមបូកសរុបមានចំនួន ០៧នាក់ ស្មើនឹង ២៩.២%។ ចំណែកឯ គ្រូដែលវាយតម្លៃសមត្ថភាសរសេរ តាមដំណាក់កាល និង តាមបូកសរុប មានចំនួន ០៧នាក់ ស្មើនឹង ២៩.២%។

ដូចនេះ សមត្ថភាពសរសេរ ភាសាអង់គ្លេសគឺមានសារៈសំខាន់ណាស់ គ្រូត្រូវតែវាយតម្លៃតាមដំណាក់ និង បូកសរុបដើម្បីពង្រឹងសមត្ថភាពសរសេររបស់សិស្សឱ្យបានត្រឹមត្រូវ។

## ៤.២.៤ ការអនុវត្តន៍វិធីសាស្ត្របង្រៀន

តារាងទី០៩៖ ការអនុវត្តន៍វិធីសាស្ត្របង្រៀនផ្សេងៗ

មដ=ម្តងម្កាល; កម្រ; មម=ម្តងម្កាល; ញញ=ញឹកញាប់; ទទ=ទៀងទាត់

| ការអនុវត្តន៍វិធីសាស្ត្របង្រៀនផ្សេងៗ | | មដ | កម្រ | មម | ញញ | ទទ |
|---|---|---|---|---|---|---|
| ១ | សំណេរលើខ្នង Back Writing | 45.8% | 8.3% | 33.3% | 8.3% | 4.2% |
| ២ | ល្បែងបោះបាល់ Ball Game | 50% | 4.2% | 33.3% | 8.3% | 4.2% |
| ៣ | សណ្ឋានពាក្យ Body Shapes | 54.2% | 0% | 37.5% | 14.2% | 4.2% |
| ៤ | ល្បែងល្បងប្រាជ្ញាពាក្យ Cross Word | 33.3% | 0% | 50% | 12.5% | 4.2% |
| ៥ | លុបចេញ និងចងចាំ Erase and Remember | 25% | 8.3% | 20.8% | 37.5% | 8.2% |
| ៦ | ពាក្យអាថ៌កំបាំង Hidden Word | 50% | 4.2% | 33.3% | 8.3% | 4.2% |
| ៧ | ប្រយោគនិងពាក្យមិនតាមលំដាប់ Jumbled | 16.7% | 8.3% | 37.5% | 29.2% | 8.3% |
| ៨ | ការសម្តែងល្ខោន Dramatization | 66.7% | 8.3% | 8.3% | 12.5% | 4.2% |
| ៩ | សំដែងតួរ Role-Play | 33.3% | 0% | 37.5% | 20.8% | 8.3% |
| ១០ | ហ្វឹកហ្វឺន (Drill) ទាយប្រយោគខុស ឬត្រូវ | 16.7% | 16.7% | 33.3% | 25% | 8.3% |
| ១១ | ហ្វឹកហ្វឺន (Drill) អានជាបុគ្គលដៃគូរ ឬក្រុម | 8.3% | 0% | 8.3% | 58.3% | 25% |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | បង្ហាញវត្ថុពិត និង រូបភាពតំណាង | 16.7% | 4.2% | 16.7% | 45.8% | 16.7% |
| ១៣ | ដៅចំណុចដាច់ៗលើអក្សរ ឬពាក្យ | 25% | 4.2% | 29.2 | 33.3% | 8.3% |
| ១៤ | ចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាម (ALM=(Audio-Lingual Method) | 58.3% | 16.7% | 20.8% | 0% | 4.2% |
| ១៥ | កាយវិការគ្រាប់តាមពាក្យ (TPR= Total Physical Response) | 33.3% | 20.8% | 29.2% | 8.3% | 8.3% |

យោងលើការបង្ហាញនៃទិន្នន័យ គ្រូចំនួន ២៤នាក់ ស្មើនឹង ១០០% បានអនុវត្តវិធីសាស្រ្តបង្រៀនដោយមានចំនួនភាគរយខុសៗគ្នា។ វិធី ដែលគ្រូអនុវត្តបានញឹកញាប់បំផុតនៅខាងលើនោះគឺ (លេខ៥) គ្រូចំនួន ០៩នាក់ ស្មើនឹង ៣៧.៥% បានអនុវត្តវិធី " លុបចេញនិងចងចាំ Erase and Remember " ។ (លេខ១១) គ្រូចំនួន ១៤នាក់ ស្មើនឹង ៥៨.៣% បានអនុវត្តវិធី " ហ្វឹកហ្វឺន (Drill) អានជាបុគ្គលដៃគូរ ឬក្រុម " ។ (លេខ១២) គ្រូចំនួន ១១នាក់ស្មើនឹង ៤៥.៨% បានអនុវត្តវិធី " បង្ហាញវត្ថុពិត និង រូបភាពតំណាង " ។ (លេខ១៣) គ្រូចំនួន ៨នាក់ ស្មើនឹង ៣៣.៣% បានអនុវត្តវិធី " ដៅចំណុចដាច់ៗ/លើអក្សរ ឬពាក្យ " ។

ចំណែកឯ វិធីដែលគ្រូប្រើប្រាស់វិធីអនុវត្ត ម្តងម្កាល មានដូចតទៅ៖ (លេខ៤) គ្រូចំនួន ១២នាក់ ស្មើនឹង ៥០% បានអនុវត្តវិធី " ល្បែងល្បងប្រាជ្ញាដាក់ពាក្យ Word Cross " ។ (លេខ៧) គ្រូចំនួន ០៩នាក់ ស្មើនឹង ៣៧.៥% បានអនុវត្តវិធី " ប្រយោគនិងពាក្យមិនតាមលំដាប់ Jumbled " ។ (លេខ៩) ចំនួន ០៩នាក់ ស្មើនឹង ៣៧.៥% បានអនុវត្តវិធី " សំដែងតួរ Role-Play" ។ (លេខ១០) គ្រូចំនួន ០៨នាក់ ស្មើនឹង ៣៣.៣% បានអនុវត្តវិធី " ហ្វឹកហ្វឺន (Drill) ទាយប្រយោគខុស ឬត្រូវ" ។

ជាចុងក្រោយ វិធីដែលគ្រូប្រើប្រាស់ វិធីមិនដែលអនុវត្តមានដូចតទៅះ (លេខ១) ) គ្រូចំនួន ១១នាក់ ស្មើនឹង ៤៥.៨% បានអនុវត្តវិធី " សំណេរលើខ្នង Back Writing " ។ (លេខ២) ) គ្រូចំនួន ១២ នាក់ស្មើនឹង ៥០% បានអនុវត្តវិធី " ល្បែងបោះបាល់ Ball Game " ។(លេខ៣ ) គ្រូចំនួន ១៣នាក់ ស្មើនឹង ៥៤.២% បានអនុវត្តវិធី " សណ្ឋានពាក្យ Body Shapes " ។(លេខ៦ ) គ្រូចំនួន ១២នាក់ ស្មើនឹង ៥០% បានអនុវត្តវិធី " ពាក្យអាថ៌កំបាំង Hidden Word " ។ (លេខ៨) គ្រូចំនួន ១៦នាក់ ស្មើនឹង៦៦.៧% បានអនុវត្តវិធី " ការសម្តែងល្ខោន Dramatization " ។ (លេខ១៤ ) គ្រូចំនួន ១៤នាក់ ស្មើនឹង ១៦.៧% បានអនុវត្តវិធី " ចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាប់ ( ALM=(Audio-Lingual Method ) " ។ (លេខ១៥ ) គ្រូចំនួន ៨ នាក់ស្មើនឹង ៣៣.៣% បានអនុវត្តវិធី " កាយវិការគ្រាប់តាមពាក្យ (TPR= Total Physical Response) " ។

ដូចនេះ វិធីសាស្រ្តដែលគ្រូមិនដែលប្រើ មានសំណេរលើខ្នង (back writing) ល្បែងបោះបាល់ ( ball games) សណ្ឋានពាក្យ ( body shapes) ពាក្យអាថ៌កំបាំង ( hidden words) ចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាប់ (Audio Lingual Method) និង កាយវិការគ្រាប់តាមពាក្យ។ ( Total Physical Response) វិធីសាស្រ្តដែលប្រើម្តងម្កាល មានដូចជា ល្បងប្រាជ្ញាពាក្យ( Cross Word) សំដែងតួរ ( Role-play) ការទាយប្រយោគ ឬខុសត្រូវ ( True/ False guessing) ។ វិធីសាស្រ្តដែលគ្រូប្រើញឹកញាប់មាន ហ្វឹកហ្វឺនជាដៃគូរ( paired work ) បង្ហាញរូបភាព ( realia) ចំណុចដាច់ៗលើពាក្យឬអក្សរ( Tracing letters/words )។

## ៤.៣ សិស្សានុសិស្ស

### ៤.៣.១ ការអនុវត្តន៍សៀវភៅសិក្សាគោល

#### ៤.៣.១.១ ការអនុវត្តន៍បង្រៀនមុខវិជ្ជាភាសាអង់គ្លេស

ក្រាហ្វិក១៨៖ ការអនុវត្តន៍បង្រៀនមុខវិជ្ជាភាសាអង់គ្លេស




ក្រាហ្វិកខាងលើ បានបង្ហាញថា សិស្សចំនួន ១៧៨នាក់ ស្មើនឹង ១០០% បានទទួលការបណ្ដុះបណ្ដាលភាសាអង់គ្លេសនៅតាមសាលាបឋមសិក្សារដ្ឋ។

ដូចនេះ សាលាបឋមសិក្សាទាំងនេះបានអនុវត្តការបង្រៀនភាសាអង់គ្លេសតាមសេចក្ដីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៤.៣.១.២ ចំណង់ចំណូលចិត្តរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស

ក្រាហ្វិក១៩៖ ចំណង់ចំណូលចិត្តរបស់សិស្សចំពោះមុខវិជ្ជាភាសាអង់គ្លេស



ក្រាហ្វិកខាងលើបង្ហាញថា សិស្សចំនួន ១៧៩នាក់ ក្នុងចំនោមសិស្សសរុប ១៧៨នាក់ ស្មើនឹង ៩៧.៧៥% ចូលចិត្តរៀនភាសាអង់គ្លេស។ ចំណែកឯ សិស្សចំនួន ០៣នាក់ ស្មើនឹង ១.៧% មិនចូលចិត្តរៀនភាសាអង់គ្លេស។

ដូចនេះ សិស្សស្ទើរតែ ១០០%ចូលចិត្តមុខវិជ្ជាភាសាអង់គ្លេសនៅសាលាបឋមសិក្សារដ្ឋ។

## ៤.៣.២ ម៉ោងរៀនភាសាអង់គ្លេសក្នុងមួយសប្តាហ៍

ក្រាហ្វិកទី២០៖ ម៉ោងរៀនភាសាអង់គ្លេសក្នុងមួយសប្តាហ៍




ក្រាហ្វិកខាងលើ បង្ហាញពីម៉ោងរៀនភាសាអង់គ្លេសក្នុងមួយសប្តាហ៍។ សិស្សដែលរៀនភាសាអង់គ្លេស ០១ម៉ោង ក្នុងមួយសប្តាហ៍ មានចំនួន ៨៣នាក់ ស្មើនឹង ៤៦.៦%។ និងសិស្សដែលរៀនភាសាអង់គ្លេស ០២ម៉ោង ក្នុងមួយសប្តាហ៍មានចំនួន ៨៤នាក់ ស្មើនឹង ៤៧.២%។ ចំណែកឯ សិស្សដែលរៀនភាសាអង់គ្លេសលើសពី ០២ម៉ោងមានចំនួន ១១នាក់ ស្មើនឹង ១១.៦%។ ដូចនេះ សិស្សដែលរៀនភាសាអង់គ្លេសលើសពី ០២ម៉ោង មានចំនួនតិចជាងគេបំផុត។

ដូចនេះ ការអនុវត្តន៍ម៉ោងរៀន មិនទាន់ឆ្លើយតបទៅនឹងការកំណត់ក្នុងសេចក្តីណែនាំរបស់ក្រសួងនៅឡើយទេ។

### ៤.៣.២.១ វត្តមានរបស់គ្រូក្នុងការមកបង្រៀន

ក្រាហ្វិកទី២១៖ វត្តមានរបស់គ្រូក្នុងការមកបង្រៀន




ក្រាហ្វិកខាងលើ បង្ហាញពីវត្តមានរបស់គ្រូក្នុងការមកបង្រៀនភាសាអង់គ្លេស។ សិស្សចំនួន ១២៩នាក់ ស្មើនឹង ៧២.៥% បានបង្ហាញថា គ្រូបានបង្រៀនភាសាអង់គ្លេសទៀងទាត់។ ចំពោះសិស្សចំនួន ៤៩នាក់ ស្មើនឹង ២៧.៥% គ្រូបង្រៀនភាសាអង់គ្លេសមិនទៀងទៀត។

ដូចនេះ គ្រូពុំទាន់មាននិយតភាព ការងារបង្រៀនរបស់ខ្លួនក្នុងការបង្រៀនភាសាបរទេសទេ ដរាបណា គ្រូអវត្តមានញឹកញាប់ បណ្តាលលទ្ធផលការរៀនភាសាអង់គ្លេសរបស់សិស្សធ្លាក់ចុះ។

### ៤.៣.២.២ ការប្រឡងប្រចាំខែ និងឆមាស

ក្រាហ្វិកទី២២៖ ការប្រឡងប្រចាំខែនិងឆមាស




ក្រាហ្វិកខាងលើនេះ បង្ហាញពីការប្រឡង មុខវិជ្ជាភាសាអង់គ្លេសរបស់សិស្សនីមួយៗ។ តាមទិន្នន័យខាងលើបានបង្ហាញថា សិស្សានុសិស្សដែលបានប្រឡងមុខវិជ្ជាភាសាអង់គ្លេសមានចំនួន ១៣៥នាក់ ស្មើនឹង ៧៥.៨%។ ចំណែកឯ សិស្សដែលថាមិនបានប្រឡងចំនួន ៤៣នាក់ ស្មើនឹង ២៤.២%។

ដូចនេះ អនុវត្តការប្រឡងប្រចាំខែ និងឆមាសមិនទៀងទាត់ បណ្តាលឱ្យមានការធ្លាក់ចុះកិច្ចខិតខំប្រឹងប្រែងរៀនសូត្ររបស់សិស្ស។

### ៤.៣.២.៣ ពិន្ទុសរុបសម្រាប់មុខវិជ្ជាភាសាអង់គ្លេស ១០ពិន្ទុ

ក្រាហ្វិកទី២៣៖ ពិន្ទុសរុបសម្រាប់មុខវិជ្ជាភាសាអង់គ្លេស ១០ពិន្ទុ




ក្រាហ្វិកខាងលើនេះ បង្ហាញពីការដឹង និង ការមិនដឹងពីពិន្ទុសរុបនៃភាសាអង់គ្លេស ចំនួន ពិន្ទុ១០។ តាមទិន្នន័យខាងលើបានបង្ហាញថា សិស្សានុសិស្សដែលបានដឹងការប្រឡងមុខវិជ្ជាភាសាអង់គ្លេសបាន ពិន្ទុ១០ មានចំនួន ១៣៤នាក់ ស្មើនឹង ៧៥.៣%។ ចំណែកឯ សិស្សដែលថាមិនដឹង ចំនួន៤៤នាក់ ស្មើនឹង ២៤.៧%។

ដូចនេះ គ្រូគួរតែប្រាប់សិស្សឱ្យដឹងពីពិន្ទុសរុប និងលទ្ធផលពិន្ទុរបស់ពួកគេ ព្រោះវាជាលទ្ធផលបង្ហាញពីសមត្ថភាពពិតរបស់គេ។

## ៤.៣.៣ វិធីសាស្ត្រអនុវត្តក្នុងសៀវភៅសិក្សាគោលភាសាអង់គ្លេស

តារាងទី១០៖ ការអនុវត្តន៍វិធីសាស្ត្របង្រៀនភាសាអង់គ្លេសរបស់លោកគ្រូអ្នកគ្រូ

មដ=មិនដែល; កម្រ; មម=ម្តងម្កាល; ញញ=ញឹកញាប់; ទទ=ទៀងទាត់

| ការអនុវត្តន៍វិធីសាស្ត្របង្រៀនភាសាអង់គ្លេសរបស់លោកគ្រូអ្នកគ្រូ | ម.ដ | កម្រ | ម.ម | ញ.ញ | ទ.ទ |
|---|---|---|---|---|---|

| | | | | | | |
|---|---|---|---|---|---|---|
| ១ | គ្រូបង្រៀនពីរបៀបអានឈ្មោះអក្សរនិងសំលេងអក្សរ | 2.8% | 1.68% | 25% | 21.34% | 48.87% |
| ២ | គ្រូបង្រៀនពីរបៀបអានពាក្យឬប្រើផ្ទាំងរូបភាព | 12.35% | 10.11% | 36.51% | 22.47% | 18.53% |
| ៣ | គ្រូឱ្យសន្ទនាខ្លីៗក្នុងសៀវភៅនិងសំដែងតួរ | 11.23% | 12.35% | 33.14% | 16.29% | 26.96% |
| ៤ | គ្រូបង្រៀនច្រៀងចំរៀងភាសាអង់គ្លេស | 38.20% | 14.04% | 24.71% | 7.86% | 15.16% |
| ៥ | គ្រូឱ្យប្អូនៗអានតាម ឬអានបន្ទរតាមក្រោយ | 5.05% | 8.98% | 28.65% | 3.59% | 3.70% |
| ៦ | គ្រូបង្កើតលែងល្បែងសិក្សាផ្សេងៗ | 15.16% | 19.10% | 31.46% | 21.91% | 12.35% |
| ៧ | គ្រូបកប្រែពាក្យខ្លីៗ និងប្រយោគខ្លីៗជាភាសាខ្មែរ | 5.61% | 5.05% | 25.84% | 38.76% | 24.71% |
| ៨ | គ្រូបង្រៀនវេយ្យាករណ៍ខ្លីៗនៅក្នុងសៀវភៅអង់គ្លេស | 24.15% | 20.22% | 20.78% | 15.16% | 19.66% |
| ៩ | គ្រូបង្រៀនអានចំនួនលេខ | 8.98% | 1.12% | 21.34% | 29.77% | 38.76% |
| ១០ | គ្រូសរសេរប្រយោគអង់គ្លេសខ្លីៗ | 8.42% | 11.23% | 42.13% | 18.53% | 19.10% |
| ១១ | គ្រូឱ្យប្អូនៗអានភាសាអង់គ្លេសក្នុងសៀវភៅ | 5.05% | 10.11% | 23.03% | 32.58% | 29.21% |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | គ្រូឱ្យប្អូនៗទាយប្រយោគខុស ឬត្រូវ | 17.41% | 17.41% | 33.70% | 17.41% | 14.04% |
| ១៣ | គ្រូឱ្យប្អូនៗហ្វឹកហ្វឺនអានជាបុគ្គលដៃគូក្រុម | 10.67% | 12.92% | 30.33% | 21.91% | 24.15% |
| ១៤ | គ្រូបង្ហាញវត្ថុពិត រូបភាពតំណាង | 15.73% | 28.08% | 23.59% | 15.73% | 16.85% |
| ១៥ | គ្រូដៅចំណុចដាច់ៗលើអក្សរ ឬពាក្យ | 21.91% | 17.41% | 26.40% | 12.35% | 21.91% |
| ១៦ | គ្រូចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាប់ (Audio-Lingual Method ) | 56.74% | 19.10% | 13.48% | 8.98% | 1.68% |
| ១៧ | គ្រូធ្វើកាយវិការគ្រាប់តាមពាក្យ Total Physical Response | 32.58% | 16.29% | 28.65% | 15.73% | 6.74% |

យោងលើការបង្ហាញនៃទិន្នន័យ សិស្សចំនួន ៦៩នាក់ ស្មើនឹង ៣៨.៧៦% ក្នុងចំនោមសិស្សចំនួន ១៧៨នាក់ ស្មើនឹង១០០%។ វិធីដែលគ្រូអនុវត្តទៀតទាត់បំផុត នោះគឺ (លេខ៩) " គ្រូបង្រៀនអានចំនួនលេខ " ។

យោងតាមរយៈទិន្នន័យខាងលើ វិធីដែលគ្រូអនុវត្តញឹកញាប់ជាងគេ នៅពេលបង្រៀនភាសាអង់គ្លេសមានតែបួនវិធីប៉ុណ្ណោះ។ (លេខ១) សិស្ស ចំនួន៨៧នាក់ ស្មើនឹង ៤៨.៨៧% ក្នុងចំនោមសិស្សចំនួន ១៧៨នាក់ ស្មើនឹង ១០០% បានបង្ហាញថាៈ" គ្រូបង្រៀនពីរបៀបអានឈ្មោះអក្សរនិ ងសំលេងអក្សរ "។ (លេខ៥) ចំនួនសិស្ស ៦០នាក់ ស្មើនឹង ៣៣.៧០% ក្នុងចំនោមសិស្សចំនួន ១៧៨នាក់ ស្មើនឹង១០០% បានបង្ហាញថាៈ" គ្រូឱ្យប្អូនៗអានតាម ឬអានបន្ទរតាមក្រោយ "។ (លេខ៧) ចំនួនសិស្ស ៦៩នាក់ ស្មើនឹង ៣៨.៧៦% ក្នុងចំនោមសិស្សចំនួន ១៧៨នាក់ ស្មើនឹង ១០០% បានបង្ហាញថាៈ" គ្រូបកប្រែពាក្យខ្លីៗ និង

ប្រយោគខ្លីៗជាភាសាខ្មែរ”។ (លេខ១១) ចំនួនសិស្ស ៥៨នាក់ ស្មើនឹង ៣២.៥៨%ក្នុងចំនោមសិស្សចំនួន ១៧៨នាក់ ស្មើនឹង១០០% បានបង្ហាញថា៖ “គ្រូឱ្យប្អូនៗអានភាសាអង់គ្លេសក្នុងសៀវភៅ” ។

ចំណែកឯ វិធីដែលគ្រូប្រើប្រាស់វិធីអនុវត្តម្តងម្កាល មានដូចតទៅ៖ (លេខ២) គ្រូបង្រៀនពីរបៀបអានពាក្យ ឬប្រើផ្ទាំងរូបភាព (សិស្សចំនួន៦៥នាក់ ស្មើនឹង ៣៦.៥១%)។ (លេខ៣) គ្រូឱ្យសន្ទនាខ្លីៗក្នុងសៀវភៅនិងសំដែងតួរ។ (លេខ៦) គ្រូបង្កើតលែងល្បែងសិក្សាផ្សេងៗ (សិស្សចំនួន ៥៦នាក់ ស្មើនឹង ៣១.៤៦%)។ (លេខ៨) គ្រូបង្រៀនវេយ្យាករណ៍ខ្លីៗនៅក្នុងសៀវភៅអង់គ្លេស (សិស្សចំនួន ៣៧នាក់ ស្មើនឹង ២០.៧៨%)។ (លេខ១០)គ្រូសរសេរប្រយោគអង់គ្លេសខ្លីៗ (សិស្សចំនួន ៧៥នាក់ ស្មើនឹង ៤២.១៣%)។ (លេខ១២) គ្រូឱ្យប្អូនៗទាយប្រយោគខុសឬត្រូវ (សិស្សចំនួន ៦០នាក់ ស្មើនឹង ៣៣.៧០%) ។ (លេខ១៣) គ្រូឱ្យប្អូនៗហ្វឹកហ្វឺនអានជាបុគ្គលដៃគូក្រុម (សិស្សចំនួន ៥៤នាក់ ស្មើនឹង ៣០.៣៣%) ។ (លេខ១៥) គ្រូដៅចំណុចដាច់ៗលើអក្សរ ឬពាក្យ (សិស្សចំនួន ៤៧នាក់ ស្មើនឹង ២៦.៤០%) ។ (លេខ១៧) គ្រូធ្វើកាយវិការគ្រាប់តាមពាក្យ Total Physical Response (សិស្សចំនួន ៥៨នាក់ស្មើនឹង ៣២.៥៨%)

រីឯ វិធីដែលគ្រូប្រើប្រាស់វិធីកម្រអនុវត្ត មាន (លេខ១៤) គ្រូបង្ហាញវត្ថុពិត រូបភាពតំណាង(សិស្សចំនួន ៥០នាក់ ស្មើនឹង ២៨.០៨%)។

ជាចុងក្រោយ វិធីដែលគ្រូ មិនដែលអនុវត្ត មាន (លេខ៤) គ្រូបង្រៀនច្រៀងចំរៀងភាសាអង់គ្លេស (សិស្សចំនួន ៦៨ នាក់ ស្មើនឹង ៣៨.២០%)។ (លេខ១៦) គ្រូចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាប់ (Audio-Lingual Method ) (សិស្សចំនួន ១០១ នាក់ ស្មើនឹង៥៦.៥៨%)។

# ជំពូកទី៥

# សេចក្ដីសន្និដ្ឋាន

# និង

# សំណូមពរ

# ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និង សំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

ក្រោយពីអ្នកសិក្សាស្រាវជ្រាវ បានស្រាវជ្រាវប្រមូលទិន្នន័យ និងវិភាគទៅលើកត្តាសំខាន់មួយចំនួនៗ ដែលបានពាក់ព័ន្ធទៅនឹងការអនុវត្តន៍ ការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសថ្នាក់ទី៤ ទី៥ និងទី៦ ស្ថិតក្រោមប្រធានបទស្រាវជ្រាវ៖″ ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា ″ ករណីសិក្សា៖ ខេត្តតាកែវ សន្និដ្ឋានជារួមបានថា ការបង្រៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សាពុំទាន់ទទួលបានជោគជ័យនៅឡើយទេ។

យោងលើ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីអំពីការបង្រៀននិងរៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា ដើម្បីអនុវត្តកម្មវិធីសិក្សា និងអនុវត្តសៀវភៅសិក្សាគោលឱ្យមានប្រសិទ្ធភាព ក្រសួងអប់រំ បានធ្វើការណែនាំទៅលើ ការប្រើប្រាស់សៀវភៅសិក្សាគោល ការប្រើប្រាស់ម៉ោងសិក្សា ការប្រើប្រាស់ធនធានគ្រូ និង ការវាយតម្លៃសមត្ថភាពសិស្ស។

ដោយផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ បានរកឃើញ គម្លាតនៃកត្តាអនុវត្តការប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសនៅកម្រិតបឋមសិក្សារដ្ឋរវាងគ្រូនិងគ្រូ។ គម្រាតទាំងនោះ ពាក់ព័ន្ធទៅនឹង ការប្រើប្រាស់សៀវភៅគោល ការអនុវត្តន៍ម៉ោងសិក្សា ការវាយតម្លៃ និង វិធីសាស្ត្រអនុវត្ត នៅក្នុងសៀវភៅសិក្សាគោល។ ចំនួនសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅតាមសាលាមិនទាន់មានគ្រប់គ្រាន់ ការយល់ដឹងរបស់គ្រូចំពោះសៀវសិក្សាគោលភាសាអង់គ្លេស (ច្បាស់៥៤.២% ដឹងតិចតួច២០.៨% និង ដឹងមិនច្បាស់ ២៥.៥%)។ ការយល់ដឹងរបស់គ្រូ ចំពោះឯកសារជំនួយការរៀននិងការបង្រៀន(ច្បាស់ ៣៧.៥% ដឹងតិចតួច ៣៣.៣% និង ដឹងមិនច្បាស់ ២៩.២%)។ ការយល់ដឹងរបស់គ្រូលើខ្លឹមសារសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេស (ច្បាស់ ២៧.២% តិចតួច ២៥% មិនច្បាស់ ២៩.២% មិនដឹង៨.៣%) ការអនុវត្តន៍ម៉ោងបង្រៀនមិនស្មើគ្នា និង ការអនុវត្តន៍ការបង្រៀនមេរៀនលើចំណុចនីមួយៗ( A,B,C...) មិនស្មើគ្នា។ ការវាយតម្លៃសមត្ថភាពជំនាញទាំងបួន

មាន តាមដំណាក់ផង និង បូកសរុបផង តំណាក់និងបូកសរុប ខុសៗគ្នាតាមសប្តាហ៍។ វិធីសាស្ត្រដែលមានប្រសិទ្ធភាព បែរគ្រូពុំសូវសូវអនុវត្ត ដូចជា៖ គ្រូចំនួន ១៦.៧% បានអនុវត្តវិធី (ALM=(Audio-Lingual Method) និង គ្រូចំនួន៣៣.៣% បានអនុវត្តវិធី (TPR= Total Physical Response)។

លទ្ធផលខាងលើនេះ ឆ្លុះបញ្ចាំងឱ្យឃើញថា កត្តានៃការអនុវត្តន៍សៀវភៅសិក្សាគោលភាសាអង់គ្លេស ពុំទាន់ឆ្លើយតប ទៅនឹងលទ្ធផលពឹងទុកនៅក្នុងកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ដែលកំណត់នូវគោលបំណងរួម ទៅលើការអប់រំមូលដ្ឋានពាក់ព័ន្ធទៅការបង្រៀនភាសាបរទេសគឺ ក្នុងគោលបំណងផ្តល់ឱ្យសិស្សនូវសមត្ថភាពទំនាក់ទំនងជាមូលដ្ឋានគ្រឹះនៅក្នុងសមត្ថភាពទាំងបួនគឺ ស្តាប់ និយាយ អាន និង សរសេរ។ ហើយលទ្ធផលរំពឹងទុកនៃការសិក្សានោះគឺ ផ្តោតតែលើ ខ្លឹមសារ និង ប្រធានបទសំខាន់ៗ តាមកម្រិតថ្នាក់នីមួយៗដូចជា ស្រៈ ព្យញ្ជនៈ ពាក្យ ល្បះងាយៗ និង អត្ថបទខ្លីៗ....ក្នុងបរិបទគ្រួសារ សាលារៀន និងសហគមន៍ អំពីតម្រូវការជាក់ស្តែងរបស់សិស្សានុសិស្ស។

## ៥.២ សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សានេះ អ្នកសិក្សាស្រាវជ្រាវសុំផ្តល់នូវសំណូមពរមួយចំនួនដូចខាងក្រោម៖

- គ្រូបង្រៀនភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា ត្រូវតែស្វែងយល់បន្ថែមទៀត ទៅលើការអនុវត្តន៍កម្មវិធីសិក្សាលម្អិត និង ឯកសារជំនួយការរៀននិងការបង្រៀនលើសៀវភៅសិក្សាគោលថ្នាក់ទី៤ទី៥ និងទី៦។
- គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ត្រូវពង្រឹងទៅលើផ្នែកវិធីសាស្ត្របង្រៀនឱ្យបានសម្បូរបែបទៅតាមបរិបទនៃមេរៀននីមួយៗ។
- គ្រូបង្រៀនមុខវិជ្ជាភាសាអង់គ្លេស ត្រូវធ្វើការស្រាវជ្រាវបន្ថែម ដើម្បីឱ្យការអនុវត្តន៍សៀវភៅសិក្សាគោលភាសាអង់គ្លេស កាន់តែមានភាពល្អប្រសើរ និង ប្រកបដោយគុណភាពឆ្លើយតបទៅនឹងលទ្ធផលរំពឹងទុកទៅតាមកម្រិតថ្នាក់នីមួយៗ។

- គួរតែបញ្ចូលម៉ោងសិក្សាបន្ថែមទៀត បន្ថែមទៀតទៅលើម៉ោងសិក្សា ដែលមានស្រាប់ ដើម្បីអនុវត្តការបង្រៀនសៀវភៅសិក្សាគោលភាសាអង់គ្លេសនៅកម្រិតបឋមសិក្សាប្រកបដោយគុណភាព។
- សុំឱ្យមានគ្រូឯកទេសភាសាអង់គ្លេសនៅកម្រិតបឋមសិក្សា។

## ៥.៣ អនុសាសន៍សម្រាប់ការស្រាវជ្រាវបន្ថែម

ការសិក្សាស្រាវជ្រាវ សូមផ្តល់អនុសាស្ត្រឱ្យគ្រូបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា ស្វែងយល់បន្ថែម និងជួយបន្តការសិក្សាស្រាវជ្រាវ នឹងពង្រីកវិសាលភាព នៅតាមសាលាបឋមសិក្សារដ្ឋឱ្យបានច្រើន បន្ថែមទៀតនៅគ្រប់ស្រុកតាមដែលអាចធ្វើទៅបានក្នុងខេត្តតាកែវ ប្រសិនបើការអនុវត្តន៍នៅតែមិនទទួលបានប្រសិទ្ធភាព។

អាស្រ័យហេតុនេះ ប្រសិនបើ មានអ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ ចាប់អារម្មណ៍លើប្រធានបទនេះ សូមចូលរួមដោះស្រាយ រកវិធីឱ្យទូលំទូលាយជាងនេះដើម្បីលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។

# ឯកសារយោង


Asye KIZILDAG. (June, 2009). Teaching English in Turkey: Dialogues with teachers about challenges in public primary schools. International Electronic Journal of Elementary Education Vol.1,Issue3, 189-201.

Author Committee. (2013). Ministry of Education, Youth and Sport English Grade 5 Student's Book.

Author Committee. (2013). Ministry of Education, Youth and Sport English Grade 4 Student's Book.

Author Committee. (2013). Ministry of Education, Youth and Sport English Grade 6 Student's Book.

DAVIDE CAPPERUCCI. (2017). English Language Teaching and Learning in Primary School. Theoretical and Methodological Perspectives. OPEN ACCESS, 205-217.

Ece ZEHIR TOPKAYA. (2010). An Evaluation of 4th and 5th Grade English Language Teaching Program. Elementary Education Online, 52-65.

Elena Stakanova. (2014). Different Approaches to Teaching English as a Foreign Language to Young Learners. ScienceDirect, 456-460.

Jeremy Harmer. (2007). The Practice of English Language Teaching. Edinburgh Gate: Pearson Education Limited.

Koji Igawa. (January 2008). English Language and its Education in Cambodia, a Country in Transition. ResearchGate, 343-368.

Marie-Immaculee Ndayyimirije. (November,2015). THE ENGLISH LANGUAGE CURRICULUM FOR STATE PRIMARY SCHOOLS IN BURUDI: AN APPRAISAL OF ITS ADEQUECY AN IMPLEMENTATION.

Mukhlash Abrar. (October,2016). TEACHING ENGLISH PROBLEMS:AN ANALYSIS OF EFL PRIMARY SCHOOL TEACHERS IN KUALA TUNGKAL. *ResearchGate*, 94-101.

ODIMA LEO EKAPTEN. (March, 2015). *EFFECT OF TEACHING ON ACQUISITION OF ENGLISH LANGUAGE SKILLS IN PRIMARY SCHOOLS IN BUSIACOUNTY KENYA.*

Pamela Hugher. (គ្មានថ្ងៃ). *Basic English Language Level 1 (BELL1).* VSO Cambodia.

Pamela Hugher. (គ្មានថ្ងៃ). *Basic English Language Level 2 (BELL2).* VSO Cambodia.

Senem Seda Sahenk Erkan. (2012). Problems of English Language Instruction in Primary in Turkey and their suggestions. *SciVerse ScienceDirect*, 1117-1121.

Sooksil Prasongsook. (2010). *Teaching and Learning English at the Grade 3 Level of Primary School in Thailand: Evaluating the Effectiveness of Three Teaching Methods.*

Zuzana Strakova. (2015). Challenges of Teaching English at Primary Level. *ScienceDirect*, 2436-2443.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). *ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះដឹងទូទៅ និងអប់រំបច្ចេកទេស.*

ក្រសួងអប់រំ យុវជន និងកីឡា. (វិច្ឆិកា ២០១៩). *យុត្តិសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ២០១៨-២០២៣.*

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៤). *សេចក្តីណែនាំស្តីពី ការបង្រៀននិងរៀនភាសាអង់គ្លេសនៅសាលាបឋមសិក្សា លេខ: ២៥ អយក សណន.*

គណៈកម្មការនិពន្ធ. (២០១៨). *សេចក្តីព្រាង ឯកសារជំនួយការបង្រៀន និងរៀនភាសាអង់គ្លេសថ្នាក់ទី៦.* នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា.

គណៈកម្មការនិពន្ធ. (២០១៤). *សេចក្ដីព្រាង ឯកសារជំនួយការបង្រៀន និងរៀនភាសាអង់គ្លេសថ្នាក់ទី ៤.* នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា.

គណៈកម្មការនិពន្ធ. (២០១៦). *សេចក្ដីព្រាង ឯកសារជំនួយការបង្រៀននិងរៀនភាសាអង់គ្លេសថ្នាក់ទី ៥.* នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា.

គណៈកម្មការអភិវឌ្ឍកម្មវិធីសិក្សា. (២០១២). *កម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសសម្រាប់បឋមសិក្សា ថ្នាក់ទី៤ ទី៥ និងទី៦ .*

រាជរដ្ឋាភិបាលកម្ពុជា. (កញ្ញា ២០១៨). " *យុទ្ធសាស្ត្រចតុកោណ* " *ដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា.*

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់នាយក/នាយិកាសាលា

ខ្ញុំបាទឈ្មោះ **ខ៉ែត រ៉ាឌុធ** ជានិស្សិតកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំកំពុងធ្វើនិក្ខេបបទក្រោមប្រធានបទ៖ " **ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា** " អាស្រ័យហេតុនេះសូមលោក/លោកស្រីជួយឆ្លើយទៅនឹងកម្រងសំណួរទាំងនេះតាមស្ថានភាពជាក់ស្តែង។

ព័ត៌មានរបស់លោក/លោកស្រីនឹងត្រូវបានរក្សាការសម្ងាត់បំផុត។

<u>សូមមេត្តាគូសសញ្ញា √ ក្នុងប្រអប់ □ និងបំពេញចន្លោះខាងក្រោមតាមភាពជាក់ស្តែងរបស់លោក/លោកស្រី</u>

### ព័ត៌មាននាយក/នាយិកា

-ឈ្មោះសាលារៀន.......................................................

-ភូមិ..................ឃុំ/សង្កាត់...............ស្រុក/ក្រុង/ខណ្ឌ...............រាជធានី/ខេត្តតាកែវ

-មុខតំណែងបច្ចុប្បន្ន: □នាយក/□នាយករង ឬ□នាយិកា/□នាយិការង

អាយុចន្លោះពី.............................ឆ្នាំ

-រយៈពេលបំពេញការងារ៖ ចាប់ពីឆ្នាំ............ដល់..............ឆ្នាំ

- កម្រិតវប្បធម៌: □បរិញ្ញាបត្រជនខ្ពស់ □ បរិញ្ញាបត្រ □ បរិញ្ញាបត្ររង □ វិញ្ញាបនបត្រ □ ផ្សេងៗ.......................................................................

### I.ការអនុវត្តន៍សៀវភៅសិក្សាគោល

១-តើលោក លោកស្រីបានទទួលព័ត៌មានពីការដាក់បញ្ចូលមុខវិជ្ជាភាសាអង់គ្លេសក្នុងកម្មវិធីសិក្សានៅសាលាបឋមសិក្សាដែរឬទេ?

□ ក. បានដឹង □ ខ.មិនបានដឹង

២- តើសាលារៀនបានអនុវត្តការបង្រៀនអង់គ្លេសចាប់ពីឆ្នាំសិក្សាណា?

□ ក.បានអនុវត្ត:បញ្ជាក់□ ២០១៤-២០១៥ □ ២០១៥-២០១៦ □ ២០១៦-២០១៧

□ ខ. មិនបានអនុវត្ត បញ្ជាក់មូលហេតុ.........................................................

៣-តើសាលារៀនបានប្រើប្រាស់សៀវភៅសិក្សាគោលភាសាអង់គ្លេសតាមការណែនាំរបស់ក្រសួងដែរឬទេ?

□ ក.បាន □ ខ.មិនបាន បញ្ជាក់.....................................

៤-តើលោក/លោកស្រីបានរៀបចំគ្រូសម្រាប់បង្រៀនភាសាអង់គ្លេសដែរឬទេ?

□ ក.បាន □ ខ.មិនបាន □ គ.ផ្សេងៗ..............................

៥- តើអ្នកពាក់ព័ន្ធ ដូចជាសាលារៀនកម្រង ការិយាល័យអប់រំស្រុក និងការិយាល័យជំនាញមន្ទីរអប់រំ បានចូលរួមជម្រុញការអនុវត្តន៍ការបង្រៀនភាសាអង់គ្លេសនៅសាលាលោក/លោកស្រីដែរឬទេ?

□ ក.បាន □ ខ.មិនបាន □ គ.ផ្សេងៗ.................................

៦-តើសាលារៀន មានសៀវភៅសិក្សាគោលភាសាអង់គ្លេសគ្រប់គ្រាន់ដែរឬទេ?

□ ក.គ្រប់គ្រាន់ □ ខ.លើស □ គ.មិនគ្រប់គ្រាន់ □ ឃ.គ្មាន

៧- លោក/លោកស្រីបាន ចែកសៀវភៅសិក្សាគោលភាសាអង់គ្លេសដល់សិស្សដែរឬទេ?

□ ក.បាន □ ខ.មិនបាន □ គ.ផ្សេងៗ.................................

៨- តើលោក/លោកស្រីទទួលបានព័ត៌មានពីការប្រើប្រាស់សៀវភៅសិក្សាភាសាអង់

គ្លេសដោយរបៀបណា?

□ ក.សិក្ខាសាលា □ ខ.របាយការណ៍ប្រជុំបច្ចេកទេស □គ.ផ្សេងៗ ...............

៩-តើលោក/លោកស្រីដឹងថាគ្រូបង្រៀនភាសាអង់គ្លេសយល់ដឹងពីខ្លឹមសារនៅក្នុងសៀវភៅសិក្សាគោលដែរឬទេ?

□ ក.បានដឹង □ខ.មិនបានដឹង □ គ.ដឹងតិចតួច

១០-តើលោកលោកស្រីមានឯកសារជំនួយសម្រាប់ការបង្រៀននិងរៀនភាសាអង់គ្លេស ដែរឬទេ?

□ ក.មាន □ ខ.មិនមាន □ គ.មានមិនគ្រប់គ្រាន់

១១- តើបណ្ណាល័យសាលាលោក/លោកស្រីមានឯកសារដែលបម្រើឱ្យការបង្រៀននិងរៀនភាសាអង់គ្លេសដែរឬទេ?

□ក.មាន □ខ.មិនមាន □គ.មានមិនគ្រប់គ្រាន់

១២- តើលោក/លោកស្រីបានដឹងថាលោកគ្រូអ្នកគ្រូមានសៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសដែរឬទេ?

□ក.បានដឹង □ខ.មិនបានដឹង □គ.មិនដឹងសោះ

## II. ការប្រើប្រាស់ម៉ោងសិក្សា

| ទស្សនៈផ្ទាល់ខ្លួនរបស់លោកនាយក/លោកស្រីនាយិកា | | មិនយល់ស្របទាំងស្រុង | មិនយល់ស្រប | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| ១ | សាលារបស់លោក/លោកស្រីបានអនុវត្តការបង្រៀនភាសាអង់គ្លេសចំនួន២ម៉ោងក្នុង១សប្តាហ៍។ | □ | □ | □ | □ |

| | | | | | |
|---|---|---|---|---|---|
| ២ | សាលារបស់លោក/លោកស្រីបានធ្វើបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេស | ☐ | ☐ | ☐ | ☐ |
| ៣ | សាលារបស់លោក/លោកស្រីបានអនុវត្តទាន់តាមបំណែងចែកកម្មវិធីសិក្សា។ | ☐ | ☐ | ☐ | ☐ |
| ៤ | លោក/លោកស្រីបានអនុវត្តការបង្រៀនភាសាអង់គ្លេសក្នុង១ម៉ោងសិក្សាប្រើរយៈពេល៤០នាទី។ | ☐ | ☐ | ☐ | ☐ |

## III. ការវាយតម្លៃលទ្ធផលសិក្សារបស់គ្រូ

១. តើលោក/លោកស្រីបានធ្វើការណែនាំលើការវាយតម្លៃលទ្ធផលសិក្សាដល់គ្រូបង្រៀនភាសាអង់គ្លេសដែរឬទេ?

☐ក.បាន ☐ខ.មិនបាន ☐គ.មិនច្បាស់

២. តើសាលារៀនរបស់លោក/លោកស្រី បានធ្វើការប្រឡងប្រចាំខែ ឆមាស មុខវិជ្ជាភាសាអង់គ្លេស ទៀងទាត់ដែរឬទេ?

☐ក.បានប្រឡង ☐ខ.មិនបានប្រឡង បញ្ជាក់............................................

៣. តើលោកគ្រូអ្នកគ្រូវាយតម្លៃលើសមត្ថភាពទាំងបួន (ស្តាប់ និយាយ អាន សរសេរ) របស់សិស្សដែរឬទេ?

☐ក.បាន ☐ខ.មិនបាន ☐គ.មិនច្បាស់

## IV. វិធីសាស្រ្តបង្រៀន

១. តើលោក/លោកស្រីដឹងថាគ្រូបង្រៀនភាសាអង់គ្លេសប្រើវិធីសាស្រ្តបង្រៀនអ្វីខ្លះ?

..................................................................................................................................................................................

..................................................................................................................................................................................

..................................................................................................................................................................................

សំណូមពរផ្សេងៗ៖(ទាក់ទងនិងការបង្រៀននិងរៀនភាសាអង់គ្លេស)៖

..................................................................................................................................................................................

កាលបរិច្ឆេទប្រគល់....................../........................../...............................

កាលបរិច្ឆេទទទួល:....................../........................../...............................

**ឧបសម្ព័ន្ធទី២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

# **កម្រងសំណួរសម្រាប់គ្រូបង្រៀន**

ខ្ញុំបាទឈ្មោះ **ខ៉ែត រ៉ាឆុធ** ជានិស្សិតកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំកំពុងធ្វើនិក្ខេបបទក្រោមប្រធានបទ៖ " **ស្ថានភាពនៃការបង្រៀនភាសារអង់គ្លេសនៅបឋមសិក្សា** " អាស្រ័យហេតុនេះសូមលោកគ្រូអ្នកគ្រូជួយឆ្លើយទៅនិងកម្រងសំណួរទាំងនេះតាមស្ថានភាពជាក់ស្តែង។

ព័ត៌មានរបស់លោកគ្រូអ្នកគ្រូនឹងត្រូវបានរក្សាការសម្ងាត់បំផុត។

សូមមេត្តាគូសសញ្ញា √ ក្នុងប្រអប់ □ និងបំពេញចន្លោះខាងក្រោមតាមភាពជាក់ស្តែងរបស់លោកគ្រូអ្នកគ្រូ

## **ព័ត៌មានគ្រូបង្រៀន**

-ឈ្មោះសាលារៀន.................................................

-ភូមិ.......................ឃុំ /សង្កាត់...............ស្រុក.../ក្រុង/ខណ្ឌ...................... ខេត្តតាកែវ

- ភេទ: □ប្រុស □ស្រី ៖ អាយុចន្លោះពី.....................................ឆ្នាំ

- បង្រៀនថ្នាក់ទី:□៤ □ទី៥ □ទី៦ ៖ សិស្សសរុប............នាក់ ស្រី.............នាក់

-រយៈពេលបំពេញការងារៈចាប់ពីឆ្នាំ ................ដល់......................ឆ្នាំ

- កម្រិតវប្បធម៌: □បរិញ្ញាបត្រជនខ្ពស់ □ បរិញ្ញាបត្រ □ បរិញ្ញាបត្ររង □ វិញ្ញាបនបត្រ □ ផ្សេងៗ.....................................................................

## I. **ការអនុវត្តន៍សៀវភៅសិក្សាគោល**

១. តើលោកគ្រូ អ្នកគ្រូយល់ដឹងខ្លឹមសារ សៀវភៅសិក្សាគោលភាសាអង់គ្លេសដែរឬទេ?

☐ក. យល់ដឹងច្បាស់ ☐ខ.ពុំសូវយល់ដឹង ☐គ.ដឹងតិចតួច ☐ឃ. មិនដឹងសោះ

២. តើលោកគ្រូ អ្នកគ្រូយល់ដឹងពីរបៀបប្រើ ឯកសារជំនួយការរៀននិងការបង្រៀនភាសាអង់គ្លេសដែរឬទេ?

☐ក. យល់ដឹងច្បាស់ ☐ខ.ពុំសូវយល់ដឹង ☐គ.ដឹងតិចតួច ☐ឃ. មិនដឹងសោះ

៣. តើលោកគ្រូអ្នកគ្រូយល់ដឹងខ្លឹមសារ សៀវភៅកម្មវិធីសិក្សាលម្អិតភាសាអង់គ្លេសដែរឬទេ?

☐ក. យល់ដឹងច្បាស់ ☐ខ.ពុំសូវយល់ដឹង ☐គ.ដឹងតិចតួច ☐ឃ. មិនដឹងសោះ

## II. ការអនុវត្តន៍ម៉ោងសិក្សា

១.តើលោកគ្រូអ្នកគ្រូ បានធ្វើបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេសដែរឬទេ?

☐ ក.បាន ☐ ខ.មិនបាន ☐ គ.មិនច្បាស់

២. តើលោកគ្រូអ្នកគ្រូ បានអនុវត្តទាន់តាមបំណែងចែកកម្មវិធីសិក្សាភាសាអង់គ្លេសដែរឬទេ?

☐ ក.ទាន់ ☐ ខ.មិនទាន់ ☐ គ.មិនច្បាស់

៣. តើក្នុងមួយសប្តាហ៍ លោកគ្រូ/អ្នកគ្រូ បង្រៀនភាសាអង់គ្លេសរយៈពេលប៉ុន្មានម៉ោង?

☐ក.១ម៉ោង ☐ខ.២ម៉ោង ☐គ.លើសពីរម៉ោង:បញ្ជាក់...................

៤. តើក្នុងមួយមេរៀនសិក្សា លោក/អ្នកគ្រូបានបង្រៀន៤ចំនុចនិងក្នុងមួយចំនុច១០នាទីដែរឬទេ?

☐ក.១. បាន ☐ខ.មិនបាន ☐គ.មិនច្បាស់

៥. តើលោកគ្រូអ្នកគ្រូបានប្រើរយៈពេលបង្រៀន៤០នាទីក្នុងរយៈពេល១ម៉ោងសិក្សាដែរឬទេ?

☐ ក.បាន ☐ខ.មិនបាន ☐គ. មិនច្បាស់

## III. ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

១.តើលោកគ្រូអ្នកគ្រូវាយតម្លៃសមត្ថភាពស្តាប់របស់សិស្សជាញឹកញាប់ដែរ ឬទេ?

☐ក. ១ដង/សប្តាហ៍ ☐ខ. ២ដង/សប្តាហ៍ ☐គ.លើសពី២ដង/សប្តាហ៍

២. តើលោក/អ្នកគ្រូបានវាយតម្លៃលើសមត្ថភាពស្តាប់របស់សិស្សដោយវិធីណា?

☐ក.វាយតម្លៃតាមតំណាក់ ☐ខ.វាយតម្លៃបូកសរុប ☐គ.តាមដំណាក់និងបូកសរុប

៣.តើលោកគ្រូអ្នកគ្រូវាយតម្លៃសមត្ថភាពនិយាយរបស់សិស្សជាញឹកញាប់ដែរ ឬទេ?

☐ក. ១ដង/សប្តាហ៍ ☐ខ. ២ដង/សប្តាហ៍ ☐គ.លើសពី២ដង/សប្តាហ៍

៤. តើលោក/អ្នកគ្រូបានវាយតម្លៃលើសមត្ថភាពនិយាយរបស់សិស្សដោយវិធីណា?

☐ក.វាយតម្លៃតាមតំណាក់ ☐ខ.វាយតម្លៃបូកសរុប ☐គ.តាមដំណាក់និងបូកសរុប

៥.តើលោកគ្រូអ្នកគ្រូវាយតម្លៃសមត្ថភាពអានរបស់សិស្សជាញឹកញាប់ដែរឬទេ?

☐ក. ១ដង/សប្តាហ៍ ☐ខ. ២ដង/សប្តាហ៍ ☐គ.លើសពី២ដង/សប្តាហ៍

៦. តើលោក/អ្នកគ្រូបានវាយតម្លៃលើសមត្ថភាពអានរបស់សិស្សដោយវិធីណា?

☐ក.វាយតម្លៃតាមតំណាក់ ☐ខ.វាយតម្លៃបូកសរុប ☐គ.តាមដំណាក់និងបូកសរុប

៧.តើលោកគ្រូអ្នកគ្រូវាយតម្លៃសមត្ថភាពសរសេររបស់សិស្សជាញឹកញាប់ដែរឬទេ?

☐ក. ១ដង/សប្តាហ៍ ☐ខ. ២ដង/សប្តាហ៍ ☐គ.លើសពី២ដង/សប្តាហ៍

៨. តើលោក/អ្នកគ្រូបានវាយតម្លៃលើសមត្ថភាពសរសេររបស់សិស្សដោយវិធីណា?

☐ក.វាយតម្លៃតាមតំណាក់ ☐ខ.វាយតម្លៃបូកសរុប ☐គ.តាមដំណាក់និងបូកសរុប

## I. វិធីសាស្ត្រអនុវត្តក្នុងម៉ោងភាសាខ្មែរ

| តើលោកគ្រូ/អ្នកគ្រូបានអនុវត្តវិធីសាស្ត្របង្រៀនផ្សេងៗខាងក្រោមដែរឬទេ? | | ទៀងទាត់ | ញឹកញាប់ | ម្តងម្កាល | កម្រ | មិនដែល |
|---|---|---|---|---|---|---|
| ១ | សំណេរលើខ្នង Back-Writing | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | ល្បែងបោះបាល់ Ball Game | ☐ | ☐ | ☐ | ☐ | ☐ |
| ៣ | សណ្ឋានពាក្យ Body Shapes | ☐ | ☐ | ☐ | ☐ | ☐ |
| ៤ | ល្បែងល្បងប្រាជ្ញាដាក់ពាក្យ Word Cross | ☐ | ☐ | ☐ | ☐ | ☐ |
| ៥ | លុបចេញ និងចងចាំ Erase and Remember | ☐ | ☐ | ☐ | ☐ | ☐ |
| ៦ | ពាក្យអាថ៌កំបាំង Hidden Word | ☐ | ☐ | ☐ | ☐ | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧ | ប្រយោគនិងពាក្យមិនតាលំដាប់(Jumbled) | ☐ | ☐ | ☐ | ☐ | ☐ |
| ៨ | ការសម្តែងល្ខោន Dramatization | ☐ | ☐ | ☐ | ☐ | ☐ |
| ៩ | សំដែងតួរ Role-play | ☐ | ☐ | ☐ | ☐ | ☐ |
| ១០ | ហ្វឹកហ្វឺនdrillទាយប្រយោគខុសឬត្រូវ | ☐ | ☐ | ☐ | ☐ | ☐ |
| ១១ | ហ្វឹកហ្វឺន(drill)អានជាបុគ្គលដៃគូក្រុម | ☐ | ☐ | ☐ | ☐ | ☐ |
| ១២ | បង្ហាញវត្ថុពិត/ រូបភាពតំណាង | ☐ | ☐ | ☐ | ☐ | ☐ |
| ១៣ | ដៅចំណុចដាច់ៗលើអក្សរ ឬពាក្យ | ☐ | ☐ | ☐ | ☐ | ☐ |
| ១៤ | ចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាប់(ALM) | ☐ | ☐ | ☐ | ☐ | ☐ |
| ១៥ | កាយវិការ ត្រាប់តាមពាក្យ( TPR) | ☐ | ☐ | ☐ | ☐ | ☐ |

១៦តើមានវិធីសាស្ត្រអ្វីខ្លះទៀតដែលលោកគ្រូអ្នកគ្រូបានអនុវត្តក្នុងការបង្រៀនភាសាអង់គ្លេស?

...........................................................................................................................

...........................................................................................................................

...........................................................................................................................

សំណូមពរផ្សេងៗ(ទាក់ទងនិងការបង្រៀនភាសាអង់គ្លេស)...........................................

កាលបរិច្ឆេទប្រគល់...................../......................../...............................

កាលបរិច្ឆេទទទួល:...................../......................../...............................

**ឧបសម្ព័ន្ធទី៣**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**វិទ្យាស្ថានជាតិអប់រំ**

## កម្រងសំណួរសម្រាប់សិស្ស

ខ្ញុំបាទឈ្មោះ **ខែត រ៉ាវុធ** ជានិស្សិតកម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៃវិទ្យាស្ថានជាតិអប់រំកំពុងធ្វើនិក្ខេបបទក្រោមប្រធានបទៈ"**ស្ថានភាពនៃការបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា**" អាស្រ័យហេតុនេះសូមប្អូនៗជួយឆ្លើយទៅនិងកម្រងសំណួរទាំងនេះតាមស្ថានភាពជាក់ស្តែង។

ព័ត៌មានរបស់ប្អូនៗ នឹងត្រូវបានរក្សាការសម្ងាត់បំផុត។

សូមមេត្តាគូសសញ្ញា √ ក្នុងប្រអប់ ☐ និងបំពេញចន្លោះខាងក្រោមតាមភាពជាក់ស្តែងរបស់ប្អូនៗ

## ព័ត៌មានសិស្ស

- ឈ្មោះសាលារៀន.............................................................
- ភេទៈ ☐ប្រុស ☐ស្រី អាយុចន្លោះពី.............ទៅ................ឆ្នាំ
- រៀនថ្នាក់ទីៈ ☐ថ្នាក់ទី៤ ☐ថ្នាក់ទី៥ ☐ថ្នាក់ទី៦

## I. ការអនុវត្តន៍សៀវភៅសិក្សាគោល

១. តើលោកគ្រូ/អ្នកគ្រូរបស់ប្អូន បានបង្រៀនមុខវិជ្ជាភាសាអង់គ្លេសឬទេ?

☐ក.បាន ☐ខ.មិនបាន

២. តើប្អូនៗបានទទួលសៀវភៅសិក្សាគោលភាសាអង់គ្លេសពីសាលារៀនដែរឬទេ?

☐ ក. បាន ☐ ខ.មិនបាន

៣. តើប្អូនចូលចិត្តរៀនភាសាអង់គ្លេសដែរទេ?

☐ ក. ចូលចិត្ត ☐ ខ. មិនចូលចិត្ត

| តើលោកគ្រូ/អ្នកគ្រូរបស់ប្អូនបាន ***<u>អនុវត្តវិធីសាស្ត្របង្រៀន</u>*** ផ្សេងៗខាងក្រោមដែរឬទេ? | | ទៀងទាត់ | ញឹកញាប់ | ម្ដងម្កាល | កម្រ | មិនដែល |
|---|---|---|---|---|---|---|
| ១ | គ្រូបង្រៀនពីរបៀបអានឈ្មោះអក្សរ និងសំលេងអក្សរ | ☐ | ☐ | ☐ | ☐ | ☐ |
| ២ | គ្រូបង្រៀនពីរបៀបអានពាក្យ ឬប្រើបណ្ណពាក្យ ឬប្រើផ្ទាំងរូបភាព | ☐ | ☐ | ☐ | ☐ | ☐ |
| ៣ | គ្រូឱ្យសន្ទនាខ្លីៗក្នុងសៀវភៅ និងសំដែងតួរ | ☐ | ☐ | ☐ | ☐ | ☐ |
| ៤ | គ្រូបង្រៀនច្រៀងចំរៀងភាសាអង់គ្លេស | ☐ | ☐ | ☐ | ☐ | ☐ |
| ៥ | គ្រូឱ្យប្អូនៗអានតាម ឬអានបន្ទរតាមក្រោយ | ☐ | ☐ | ☐ | ☐ | ☐ |
| ៦ | គ្រូបង្កើតលែងល្បែងសិក្សាផ្សេងៗ | ☐ | ☐ | ☐ | ☐ | ☐ |
| ៧ | គ្រូបកប្រែពាក្យខ្លីៗ និងប្រយោគខ្លីៗជាភាសាខ្មែរ | ☐ | ☐ | ☐ | ☐ | ☐ |
| ៨ | គ្រូបង្រៀនវេយ្យាករណ៍(ទំរង់ឬរូបមន្ត)ខ្លីៗនៅក្នុងសៀវភៅសាអង់គ្លេស | ☐ | ☐ | ☐ | ☐ | ☐ |
| ៩ | គ្រូបងៀនអានចំនួនលេខ | ☐ | ☐ | ☐ | ☐ | ☐ |
| ១០ | គ្រូសរសេរប្រយោគអង់គ្លេសខ្លីៗ | ☐ | ☐ | ☐ | ☐ | ☐ |
| ១១ | គ្រូឱ្យប្អូនៗអានភាសាអង់គ្លេសក្នុងសៀវភៅ | ☐ | ☐ | ☐ | ☐ | ☐ |
| ១០ | គ្រូឱ្យប្អូនៗហ្វឹកហ្វឺន ទាយប្រយោគខុសឬត្រូវ | ☐ | ☐ | ☐ | ☐ | ☐ |
| ១១ | គ្រូឱ្យប្អូនៗហ្វឹកហ្វឺន អានជាបុគ្គលដៃគូ ក្រុម | ☐ | ☐ | ☐ | ☐ | ☐ |

| | | | | | | |
|---|---|---|---|---|---|---|
| ១២ | គ្រូបង្ហាញវត្ថុពិត/រូបភាពតំណាង | ☐ | ☐ | ☐ | ☐ | ☐ |
| ១៣ | គ្រូដៅចំណុចដាច់ៗលើអក្សរ ឬពាក្យ | ☐ | ☐ | ☐ | ☐ | ☐ |
| ១៤ | គ្រូចាក់ខ្សែអាត់សំលេងឱ្យសិស្សស្តាប់(ALM) | ☐ | ☐ | ☐ | ☐ | ☐ |
| ១៥ | គ្រូធ្វើកាយវិការ ត្រាប់តាមពាក្យ | ☐ | ☐ | ☐ | ☐ | ☐ |

## II. ការអនុវត្តន៍ម៉ោងសិក្សា

១.តើប្អូនរៀនភាសាអង់គ្លេសប៉ុន្មានម៉ោងក្នុងមួយសប្តាហ៍?

☐ ក.មួយម៉ោង ☐ ខ.ពីរម៉ោង ☐ គ.លើសពីរម៉ោង

២. តើគ្រូបង្រៀនរបស់ប្អូនបង្រៀនភាសាអង់គ្លេសបាន ទៀងទាត់ដែរឬទេ ?

☐ ក.ទៀងទាត់ ☐ ខ.មិនទៀងទាត់

## III. ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស

១.តើលោកគ្រូអ្នកគ្រូរបស់ប្អូនៗបានធ្វើការប្រឡងប្រចាំខែឆមាសលើមុខវិជ្ជាភាសាអង់គ្លេសដែរឬទេ?

☐ ក.បាន ☐ ខ.មិនបាន

២. តើប្អូនដឹងថាពិន្ទុសរុបនៃមុខវិជ្ជាភាសាអង់គ្លេសចំនួន ១០ពិន្ទុដែរឬទេ?

☐ ក. ដឹង ☐ ខ.មិនដឹង

សំណូមពរផ្សេងៗ(ទាក់ទងនិងរៀនភាសាអង់គ្លេស)៖..........................................................................

កាលបរិច្ឆេទប្រគល់...................../........................./..............................

កាលបរិច្ឆេទទទួល:...................../........................./..............................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ [illegible] អយក.[illegible]

*ថ្ងៃព្រហស្បតិ៍ ១៤កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦២*
*រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩*

**ជម្រាបមក**
**លោកនាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ**
**លោកនាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី-ខេត្ត**

**កម្មវត្ថុ** ៖ ការចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦។

**យោង** ៖ កម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ឆ្នាំសិក្សា២០១៨-២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោកនាយក និងលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ចំនួន៩១នាក់ ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ នៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្ត ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩។

អាស្រ័យហេតុនេះ សូមលោកនាយក និងលោកប្រធានជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូមលោកនាយក និងលោកប្រធានទទួលនូវការរាប់អានពីខ្ញុំ ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន

**ចម្លងជូន៖**
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី-ខេត្តពាក់ព័ន្ធ
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក
  "ដើម្បីជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ៖ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ : ១១៩ ខជអ.ភក

## លិខិតឧទ្ទេសនាម

**យោង៖** ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩

និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ នៅវិទ្យាស្ថានជាតិអប់រំដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញនិងបាត់ដំបង សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម និងតាមរាជធានី-ខេត្តនានា ចាប់ពីថ្ងៃទី២២ ខែឧសភា ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩៖

| ល.រ | គោត្តនាម និងនាម | ភេទ | សាលាគរុកោសល្យ និង រាជធានី-ខេត្ត |
|---|---|---|---|
| ១ | កុយ វ៉ាឡង់ទីណា | ប | ខេត្តកំពង់ធំ |
| ២ | គុជ សំអែល | ប | ខេត្តស្វាយរៀង |
| ៣ | ឃិន សម្បត្តិ | ប | ខេត្តតាកែវ |
| ៤ | ឯន ណារី | ប | រាជធានីភ្នំពេញ |
| ៥ | ង៉ែត វ៉ាវុធ | ប | ខេត្តតាកែវ |
| ៦ | ងួន ផល្លី | ស | ខេត្តបាត់ដំបង |
| ៧ | ឆន ឈាង | ប | សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម |
| ៨ | ឆាយ បូនី | ស | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ និងបាត់ដំបង |
| ៩ | ជា តត | ប | ខេត្តតាកែវ |
| ១០ | ជា វណ្ណារ៉ា | ប | ខេត្តកំពង់ឆ្នាំង |
| ១១ | ញ៉ែត សំអុល | ប | ខេត្តតាកែវ |
| ១២ | ទឹម ពិន្ទុ | ប | រាជធានីភ្នំពេញ ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង ពោធិ៍សាត់ កំពង់ស្ពឺ កំពង់ធំ ស្ទឹងត្រែង ឧត្តរមានជ័យ និងខេត្តមណ្ឌលគិរី |
| ១៣ | ទុយ សុវណ្ណារិទ្ធ | ប | រាជធានីភ្នំពេញ ខេត្តកំពង់ចាម បាត់ដំបង និងខេត្តសៀមរាប |
| ១៤ | ធាម ហេង | ប | ខេត្តក្រចេះ |
| ១៥ | ប៉ុម សូគ៌ា | ប | ខេត្តកណ្ដាល |
| ១៦ | ផុន វណ្ណៈ | ប | ខេត្តកណ្ដាល |
| ១៧ | ផូ សុវណ្ណ | ប | រាជធានីភ្នំពេញ |



អាសយដ្ឋានលេខ ១២៣ មហាវិថី ព្រះនរោត្តមភ្នំពេញ កម្ពុជា ទូរស័ព្ទ៖ (៨៥៥-២៣) ២១៥/៥៨៤ គេហទំព័រ៖ www.nie.edu.kh

| | | | |
|---|---|---|---|
| ១៨ | ពុត ពិសិ | ប | ខេត្តកំពត |
| ១៩ | ពេជ្រ វល្សី | ស | ខេត្តត្បូងឃ្មុំ |
| ២០ | ភោគ តុលា | ប | ខេត្តស្វាយរៀង |
| ២១ | លី កុសល | ប | ខេត្តកំពង់ចាម |
| ២២ | លឹម សេងហុត | ប | ខេត្តបាត់ដំបង |
| ២៣ | លុន ហ៊ាប | ប | ខេត្តកំពង់ចាម |
| ២៤ | លុយ គីមសាន | ប | ខេត្តកណ្ដាល |
| ២៥ | វ៉ា សុភក្តិ | ប | ខេត្តព្រៃវែង |
| ២៦ | សន តារាស្មី | ប | ខេត្តកណ្ដាល |
| ២៧ | ស៊ើយ វង្សស៊ី | ប | ខេត្តស្ទឹងត្រែង |
| ២៨ | សាម សុនិត | ប | ខេត្តកំពង់ចាម |
| ២៩ | សុទ្ធ ស្រីនាង | ស | ខេត្តកំពង់ស្ពឺ |
| ៣០ | សៀង គីមឈៀន | ប | ខេត្តកណ្ដាល |
| ៣១ | ស្រី មៅ | ប | រាជធានីភ្នំពេញ |
| ៣២ | ហៃល ម៉ូណា | ប | រាជធានីភ្នំពេញ |
| ៣៣ | ហៃយ ចម្លង | ស | រាជធានីភ្នំពេញ |
| ៣៤ | ឡាយ វីរៈ | ប | ខេត្តឧត្តរមានជ័យ |
| ៣៥ | ឡុង ចំណាន | ប | ខេត្តកំពង់ចាម |
| ៣៦ | អ៊ុន ចាន់ថា | ប | ខេត្តស្វាយរៀង |
| ៣៧ | អ៊ីវ សុធិ | ប | រាជធានីភ្នំពេញ |
| ៣៨ | អ៊ឹម សិរីវឌ្ឍ | ប | ខេត្តតាកែវ |
| ៣៩ | អ៊ុក រិទ្ធិ | ប | ខេត្តសៀមរាប |
| ៤០ | អុន សេងទ្រី | ប | ខេត្តកំពង់ធំ |
| ៤១ | អៀង គីមឈាន | ប | ខេត្តកំពង់ចាម |

ថ្ងៃសុក្រ ១៤កើត ខែពិសាខ ឆ្នាំកុរ ឯកស័កព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុខន្ធរា

**កន្លែងទទួល៖**

-សាលារាជធានី-ខេត្តពាក់ព័ន្ធ

-អង្គភាពពាក់ព័ន្ធនានាក្រោមឱវាទក្រសួង អ.យ.ក

-មន្ទីរ អ.យ.ក រាជធានី-ខេត្តពាក់ព័ន្ធ

"ដើម្បីសហការ"

-សាមីជន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ

-ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៦៧២៥ **អយក.** ខក
(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម **យក់ ឌី** | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម **លាង សេងហាក់** | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម **ម៉ក់ ងយ** | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកដឹកនាំវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារៈវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:** ៩៧២៩ **អយក.** ១៩
(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖** -បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-ឯ.ឧ បណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯ.ឧបណ្ឌិត សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តម លឹម សុធា | អគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | សមាជិក |
| ៤-លោកបណ្ឌិត នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោកជំទាវបណ្ឌិត យួន វិច្ឆិកា | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៧-លោក ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯ.ឧបណ្ឌិត ម៉ុក សារ៉ុម | អគ្គនាយកដ្ឋានអប់រំ | សមាជិក |
| ៩-ឯ.ឧបណ្ឌិត ឌី ខាំបូលី | អគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១០-ឯ.ឧ បណ្ឌិត ស៊ន សេងហុក | នាយកដ្ឋាននីតិកម្ម | សមាជិក |
| ១១-លោកបណ្ឌិត សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១២-លោកបណ្ឌិត ឈូក ច័ន្ទឆាយា | នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ | សមាជិក |
| ១៣-លោកបណ្ឌិត នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោកជំទាវ អស់លោក ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅនៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១ រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ - ឯកសារវិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ:** ៩៦៣១ **អយក.** ៦៧

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

**យោង ៖**-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ និងទី៧ ឆ្នាំសិក្សា២០១៨-២០១៩ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៨។

មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការកណ្តាល** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៦ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១០-១១ ខែធ្នូ ឆ្នាំ២០១៩ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១-លោកស្រី ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-លោក ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោក សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវមកបំពេញភារកិច្ចនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩ និងថ្ងៃបន្តបន្ទាប់ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ សុក្រ ១១រោច ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២២ខែវិច្ឆិកា ឆ្នាំ២០១៩

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអយក

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ

"ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ - ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ: www.moeys.gov.kh